ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# កម្មវិធីវិនិយោគខេត្ត

## (២០១៣_២០១៥)

## ខេត្តព្រះវិហារ



ខែ ធ្នូ ឆ្នាំ ២០១២

# មាតិកាអត្ថបទ


មាតិកាអត្ថបទ............ i

សេចក្តីសម្រេចស្តីពីការដាក់ឲ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត............ iii

អារម្ភកថា............ ១

សេចក្តីផ្តើម............ ២

ផែនទីខេត្ត............ ៣

**ជំពូកទី១: ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច............ ៤**

**១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច............ ៤**

**១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម............ ៧**

**១.២.១ ស្ថានភាពសេដ្ឋកិច្ច............ ៨**

១.២.១.១ វិស័យកសិកម្ម............ ៨

១.២.១.២ វិស័យជលផល............ ១០

១.២.១.៣ វិស័យធនធានទឹក និងឧតុនិយម............ ១១

១.២.១.៤ វិស័យទេសចរណ៍............ ១២

១.២.១.៥ វិស័យសាធារណៈការ និងដឹកជញ្ជូន............ ១៦

១.២.១.៦ វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍............ ១៧

១.២.១.៧ វិស័យពាណិជ្ជកម្ម............ ១៩

១.២.១.៨ វិស័យឧស្សាហកម្ម រ៉ែ និងថាមពល............ ២០

១.២.១.៩ វិស័យអភិវឌ្ឍន៍ជនបទ............ ២១

**១.២.២ ស្ថានភាពសង្គមកិច្ច............ ២៥**

១.២.២.១ វិស័យអប់រំយុវជន និងកីឡា............ ២៥

១.២.២.២ វិស័យសុខាភិបាល............ ២៨

១.២.២.៣ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ............ ២៩

១.២.២.៤ វិស័យព័ត៌មាន............ ៣០

១.២.២.៥ វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា............ ៣១

១.២.២.៦ វិស័យធម្មការ និងសាសនា............ ៣២

១.២.២.៧ វិស័យយេនឌ័រ............ ៣៤

១.២.២.៨ វិស័យទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច............ ៣៥

**១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន............ ៣៧**

១.២.៣.១ វិស័យគ្រប់គ្រងដីធ្លី សុរិយោដី............ ៣៨

១.២.៣.២ វិស័យបរិស្ថាន គ្រប់គ្រងធនធានធម្មជាតិ............ ៣៨

១.២.៣.៣ វិស័យរដ្ឋបាលព្រៃឈើ........................................................................... ៤០
១.២.៣.៤ ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ.......................................... ៤០
**១.២.៤ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ**........................ ៤២
**១.២.៥ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ**.................... ៤៣

**ជំពូកទី២: គម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល** ........................................................................ ៤៦
**២១ គម្រោងវិនិយោគ**.................................................................................................... ៤៦
-តារាងសង្ខេបគម្រោងវិនិយោគបីឆ្នាំរំកិល......................................................................... ៤៦
-តារាងសង្ខេបគម្រោងគាំទ្រដោយក្រសួងស្ថាប័ន និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត............ ៥១
-តារាង**២.១** គម្រោងវិនិយោគបីឆ្នាំរំកិលខេត្ត.................................................................... ៥៤
ក-គម្រោងវិនិយោគកំពុងដំណើរការ.................................................................... ៥៤
ខ-គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ........................................................ ៦៥
គ-គម្រោងវិនិយោគអាទិភាពដែលមិនទាន់មានការសន្យាគាំទ្រ........................... ៦៨
-តារាង**២.២** មូលនិធិគាំទ្រតាមប្រភព.................................................................................. ១៣៦
**២.២ ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម**.................................................................................. ១៣៧
**២.៣ ផែនការសកម្មភាពសម្រាប់អនុវត្តគម្រោង**......................................................................... ១៣៧
**ឧបសម្ព័ន្ធ**
១-តារាង**១.២ ខ** គម្រោងគាំទ្រដោយក្រសួងស្ថាប័ន និងទីភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត.................. ១៤០
ក-គម្រោងវិនិយោគកំពុងដំណើរការ........................................................................ ១៤០
ខ-គម្រោងវិនិយោគដែលមានការសន្យាគាំទ្រ.......................................................... ១៦២
២- សេចក្តីសម្រេចស្តីពីគោលការណ៍ណែនាំផ្នែកគោលនយោបាយសម្រាប់ការកសាងផែនការ
អភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត......................................................................... ១៩៤
៣- ប្រតិទិនការងារសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត២០១៣-២០១៥....................... ២០៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះវិហារ**

លេខ : ០១៨ សសរ.[illegible]

# សេចក្ដីសម្រេច
## ស្ដីពី
## ការដាក់ឱ្យប្រើប្រាស់កម្មវិធីវិនិយោគបីឆ្នាំរំកិល
## ខេត្តព្រះវិហារ

## ប្រធានក្រុមប្រឹក្សាខេត្ត

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៤ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៩ ស្ដីពីការទទួលស្គាល់ សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារអាណត្តិទី ១ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៩/៧៥២ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៩ ស្ដីពីការតែងតាំងជាអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពី ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ១៦អនក្រ.បក ចុះថ្ងៃទី ២០ខែធ្នូឆ្នាំ១៩៩៧ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីតួនាទី ភារកិច្ច និង ទំនាក់ទំនងការងារ របស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- យោងតាមប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្ដីពីការបង្កើតការិយាល័យ ចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការ នៃសាលាស្រុក និងការកំណត់តួនាទី ភារកិច្ច របៀបរបបការងារ នៃការិយាល័យទាំងនោះ។
- យោងអនុក្រឹត្យលេខ ២១៩ អនក្រ.បកចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្តក្រុងស្រុកខណ្ឌ។
- យោងអនុក្រឹត្យលេខ១៥២អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្ដីពីការកែសម្រួលមាត្រា១២នៃអនុក្រឹត្យស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានីខេត្តក្រុងស្រុក ខណ្ឌ។
- យោងប្រកាសអន្តរក្រសួងលេខ២៤១៧ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ស្ដីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- យោងសេចក្តីណែនាំលេ០៧៧សណន/គជអប ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១២ ស្តីពីការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសម្រាប់ឆ្នាំ២០១៣-២០១៥។
- យោងលិខិតលេខ ០០៣ លផ/ក្រុប្រ/ទផវិ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១២ ស្តីពីការអនុម័តប្រតិទិនការងារ សម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត២០១៣-១០១៥ តាមស្មារតីនៃអង្គប្រជុំសាមញ្ញលើកទី៤០ របស់ ក្រុមប្រឹក្សាខេត្តព្រះវិហារ អាណត្តិទី១។

## សម្រេច

**ប្រការ ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវកម្មវិធីវិនិយោគបីឆ្នាំរំកិលសម្រាប់ឆ្នាំ២០១៣-២០១៥ របស់ខេត្តព្រះវិហារ ដែលត្រូវបានអនុម័តដោយក្រុមប្រឹក្សាខេត្តព្រះវិហារ នាកិច្ចប្រជុំសាមញ្ញលើកទី៤៤របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី១ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១២។

**ប្រការ ២.-**

គណៈអភិបាលខេត្តព្រះវិហារត្រូវចាត់ចែងផ្សព្វផ្សាយកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះដល់ប្រជាពលរដ្ឋ និង អ្នកពាក់ព័ន្ធនានានៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តព្រះវិហារ។

គណៈអភិបាលខេត្តព្រះវិហារត្រូវចាត់ចែង សម្របសម្រួល និងកៀរគរធនធាននានាក្នុងការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនេះ ប្រកបដោយការចូលរួម តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។

**ប្រការ ៣.-**

គណៈអភិបាលខេត្ត ត្រូវរៀបចំយន្តការ និងប្រព័ន្ធសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តកម្មវិធីវិនិយោគនេះ ដោយមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធនានា ដើម្បីបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធី។

គណៈអភិបាលខេត្ត ត្រូវរៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគនេះ និងរាយការណ៍ជូនអង្គប្រជុំក្រុមប្រឹក្សាខេត្ត អំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគនេះទៅតាមកាលកំណត់។

គណៈអភិបាលខេត្ត ត្រូវរៀបចំ និងដាក់ជូនក្រុមប្រឹក្សាខេត្ត អំពីរបាយការណ៍ប្រចាំឆ្នាំស្តីពីការអនុវត្តកម្មវិធីវិនិយោគនេះ។

**ប្រការ ៤.-**

គណៈអភិបាលខេត្ត ត្រូវធ្វើការវាយតម្លៃការអនុវត្តកម្មវិធីវិនិយោគនេះ មួយឆ្នាំម្តង នៅរាល់ចុងឆ្នាំ ដើម្បីវាយតម្លៃអំពីលទ្ធផលសម្រេចបានធៀបនឹង គោលដៅ និងគោលបំណង ដែលបានកំណត់នៅក្នុងកម្មវិធីវិនិយោគខេត្ត។

**ប្រការ ៥.-**

គណៈអភិបាលខេត្ត នាយករដ្ឋបាល នាយកទីចាត់ការទាំង៥ចំណុះរចនាសម្ព័ន្ធសាលាខេត្ត លោក លោកស្រីប្រធានមន្ទីរអង្គភាពជុំវិញខេត្ត រដ្ឋបាលក្រុង ស្រុក ក្នុងខេត្តព្រះវិហារ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ព្រះវិហារ, ថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ២០១២

ជ.ក្រុមប្រឹក្សាខេត្តព្រះវិហារ

ប្រធាន

ឡុង-សុវណ្ណ

ចម្លងជូន :
- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- លេខាធិការដ្ឋាន គ.ជ.អ.ប
  "ដើម្បីជ្រាប"
- ដូចប្រការ៥
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ

# អារម្ភកថា

ក្រុមប្រឹក្សាខេត្តព្រះវិហារ រៀបចំកម្មវិធីវិនិយោគខេត្តបីឆ្នាំរំកិល (២០១៣-២០១៥) ដោយផ្ដល់ឱកាសឱ្យមានការចូលរួមដោយផ្ទាល់ពីមន្ទីរអង្គភាព ក្រុង ស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានានៅក្នុងដំណើរការនៃការរៀបចំ និងកសាងកម្មវិធីវិនិយោគនេះ។ កម្មវិធីវិនិយោគខេត្តបីឆ្នាំរំកិលដែលបានបង្កើតឡើងផ្អែកលើគោលការណ៍ណែនាំផ្នែកគោលនយោបាយ និងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ដើម្បីឆ្លើយតបទៅនឹងអាទិភាពរបស់ខេត្ត សម្រាប់តម្រូវការជំនួយវិនិយោគទុន និងជំនួយបច្ចេកទេសក្នុងការអនុវត្តផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខេត្ត ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនៅមូលដ្ឋាន និងលើកកម្ពស់គុណភាពសេវា សំដៅរួមចំណែកកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារ។

កម្មវិធីវិនិយោគខេត្តបីឆ្នាំរំកិល ត្រូវបានប្រើប្រាស់ជាមូលដ្ឋានដ៏សំខាន់សម្រាប់ធ្វើឱ្យសម្រេចបាននូវផែនការអភិវឌ្ឍន៍ខេត្តប្រាំឆ្នាំ ដើម្បីធានាថាការធ្វើគម្រោងរបស់មន្ទីរ អង្គភាព ជុំវិញខេត្ត អង្គការសង្គមស៊ីវិល វិស័យឯកជន និងបណ្ដារដ្ឋបាល ក្រុង ស្រុក ព្រមទាំងអ្នកពាក់ព័ន្ធទាំងអស់ សម្រាប់រៀបចំកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិលបានឆ្លើយតបទៅនឹងអាទិភាពរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣។

ក្នុងនាមក្រុមប្រឹក្សាខេត្តព្រះវិហារអាណត្តិទី១ ខ្ញុំសូមថ្លែងអំណរគុណដល់គណៈអភិបាលខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រីនិងកុមារខេត្ត គណៈកម្មាធិការនានា ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ខេត្តរបស់ក្រុមប្រឹក្សាខេត្ត មន្ទីរ អង្គភាព ក្រុង ស្រុក អង្គការសង្គមស៊ីវិល វិស័យឯកជន ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាក្នុងខេត្ត ដែលបានជួយគាំទ្រដឹកនាំ សម្របសម្រួល និងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការកសាងកម្មវិធីវិនិយោគខេត្តនេះ ជាមួយគ្នានេះក៏អំពាវនាវដល់វិស័យឯកជន អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍និងសប្បុរសជននានាជួយគាំទ្រគម្រោងសកម្មភាព ឬ សេវាជាអាទិភាពនានាដែលឆ្លើយតបទៅនឹងក្របខ័ណ្ឌអភិវឌ្ឍន៍ខេត្ត ដែលបានកំណត់។

ខ្ញុំសង្ឃឹមជឿជាក់ថា កម្មវិធីវិនិយោគខេត្តបីឆ្នាំរំកិល នឹងធ្វើឱ្យការអនុវត្តគម្រោងនានាទទួលបានជោគជ័យប្រកបដោយប្រសិទ្ធិភាព និងតម្លាភាព នាំមកនូវភាពរុងរឿង សំបូរ សប្បាយសំរាប់ខេត្ត និងប្រជាពលរដ្ឋរបស់យើង ដើម្បីកាត់បន្ថយភាពក្រីក្រនៅតាមមូលដ្ឋាន។

ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ២០១២

ជ.ក្រុមប្រឹក្សាខេត្ត

ប្រធាន

ឡុង-សុវណ្ណ

# សេចក្តីផ្តើម

អនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នៅខែឧសភា ឆ្នាំ២០០៩ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានធ្វើឡើងប្រកបដោយជោគជ័យ។ ក្រុមប្រឹក្សាខេត្ត រួមជាមួយគណៈអភិបាលខេត្ត បានអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីអភិបាលកិច្ច និង អភិវឌ្ឍន៍សេដ្ឋកិច្ចមូលដ្ឋាន ស្របតាមច្បាប់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងលិខិតបទដ្ឋានគតិយុត្តិនានា។

យោងមាត្រា៣៨ និងមាត្រា៣៩នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យលេខ ២១៩អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យលេខ១៥២អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា ១២នៃ អនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង បន្ទាប់ពីបានរៀបចំផែនការអភិវឌ្ឍន៍ខេត្ត សម្រាប់ឆ្នាំ២០១១-២០១៥ រួចមក ក្រុមប្រឹក្សាខេត្តព្រះវិហារ អាណត្តិទី១ រៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ដើម្បីធានាបានការអភិវឌ្ឍមូលដ្ឋានប្រកបដោយប្រសិទ្ធិភាព តម្លាភាព គណនេយ្យភាព និងឆ្លើយតបតាមតម្រូវការជាអាទិភាពមូលដ្ឋាន សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅក្នុងខេត្ត។

កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តព្រះវិហារបានរៀបចំឡើងស្របតាមផែនការអភិវឌ្ឍន៍ខេត្ត និងសេចក្តីណែនាំ ដោយមានការចូលរួម និង ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ក្រុមតំណាងអ្នកទទួលផលពិសេសក្រុមយុវជន ស្ត្រី និងកុមារ រដ្ឋបាលក្រុង ស្រុក មន្ទីរជំនាញជុំវិញខេត្ត ទីចាត់ការចំណុះសាលាខេត្ត អង្គការសង្គមស៊ីវិល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានាក្នុងដែនសមត្ថកិច្ចរបស់ខេត្តក្នុងការវិភាគស្ថានភាពសក្តានុពល បញ្ហាប្រឈម និងតម្រូវការនានារបស់មូលដ្ឋាន។

កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត គឺដើម្បីបំលែងខ្លឹមសារនៃផែនការអភិវឌ្ឍន៍ខេត្ត ឱ្យទៅជាសកម្មភាព ឬសេវាជាក់ស្តែង សំដៅលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍខេត្តសម្រាប់រយៈពេលបីឆ្នាំ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ដើម្បីអភិវឌ្ឍន៍សេដ្ឋកិច្ច និងលើកកម្ពស់គុណភាពសេវា សំដៅឆ្លើយតបតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ។

កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តនេះចែកចេញជាពីរជំពូកៈ

- ជំពូកទី១ បរិយាយអំពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច
- ជំពូកទី២ បរិយាយអំពីគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល។


ផែនទីខេត្តព្រះវិហារ
N
0
10
20
kilometers
កំណត់សំគាល់
ព្រំប្រទល់ខេត្ត
ព្រំប្រទល់ស្រុក
ព្រំប្រទល់ឃុំ
ផ្លូវជាតិ
ផ្លូវខេត្ត
ផ្លូវរថភ្លើង
ទន្លេ ស្ទឹង ព្រែក
ទីរួមស្រុក
សាលា
មណ្ឌលសុខភាពឃុំ
មន្ទីរពេទ្យបង្អែក

# ជំពូកទី១

## ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច

## ១.១ សេចក្តីសង្ខេបទិន្នន័យសេដ្ឋកិច្ច សង្គមកិច្ច

ព័ត៌មានសំខាន់ៗក្នុងខេត្ត

| បរិយាយ | ឯកតា | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|
| **ទិន្នន័យទូទៅ** | | | | |
| ផ្ទៃដីខេត្ត | គ.ម² | 14,031 | 14,031 | 14,031 |
| ចំនួនក្រុង | ក្រុង | 1 | 1 | 1 |
| ចំនួនស្រុក | ស្រុក | 7 | 7 | 7 |
| ចំនួនសង្កាត់ | សង្កាត់ | 2 | 2 | 2 |
| ចំនួនឃុំ | ឃុំ | 47 | 49 | 49 |
| ចំនួនភូមិ | ភូមិ | 209 | 228 | 229 |
| ចំនួនប្រជាជនសរុប | នាក់ | 175,500 | 191,246 | 204,009 |
| ចំនួនស្ត្រីសរុប | នាក់ | 88,746 | 97,347 | 102,730 |
| កំណើនប្រជាជនប្រចាំឆ្នាំ | % | 4.59 | 8.97 | 6.67 |
| ចំនួនគ្រួសារសរុប | គ្រួសារ | 37,456 | 41,532 | 46,184 |
| ទំហំគ្រួសារជាមធ្យម | នាក់ | 4.69 | 4.60 | 4.42 |
| ដង់ស៊ីតេប្រជាជនក្នុងមួយគីឡូម៉ែត្រក្រឡា | នាក់ | 13 | 14 | 14.54 |
| **ទិន្នន័យផ្នែកសេដ្ឋកិច្ច** | | | | |
| ភាគរយមនុស្សប្រកបមុខរបរធ្វើកសិកម្មជាចំបង | % | | | 71.91 |
| ធ្វើស្រែ | % | | | 63.08 |
| ធ្វើចំការ | % | | | 7.98 |
| នេសាទ | % | | | 0.12 |
| ចិញ្ចឹមសត្វ | % | | | 0.21 |
| អនុផលព្រៃឈើ | % | | | 0.51 |
| ភាគរយមនុស្សប្រកបមុខរបរធ្វើសិប្បកម្មជាចំបង | % | | | 0.33 |
| ត្បាញរវៃ | % | | | 0 |
| ផលិតពីផ្តៅ ឫស្សី វល្លិ៍ | % | | | 0.03 |
| គ្រឿងសង្ហារឹម(តុ ទូ កៅអី ...) | % | | | 0.23 |
| ចម្លាក់ពីស្ពាន់ ថ្ម ស្បែក | % | | | 0.01 |
| ផលិតពីដែក អាលុយមីញ៉ូម កញ្ចក់ | % | | | 0.04 |
| ផលិតពីជ័រផ្លាស់ស្ទិក | % | | | 0.01 |

| បរិយាយ | ឯកតា | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|
| កែឆ្នៃឬវិចខ្ចប់គ្រាប់ធញ្ញជាតិ | % | | | 0.01 |
| ភាគរយមនុស្សប្រកបមុខរបរធ្វើសេវាកម្មជាចំបង | % | | | 2.46 |
| លក់ដូរឬធ្វើជំនួញ | % | | | 2.05 |
| ជាងជួសជុល | % | | | 0.28 |
| វិស័យដឹកជញ្ជូន | % | | | 0.13 |
| **ទិន្នន័យផ្នែកសង្គមកិច្ច** | | | | |
| ភាគរយកុមារអាយុ៣-៥ឆ្នាំបានចូលរៀនក្នុងមត្តេយ្យសាលា | % | 10.81 | 13.52 | 21.94 |
| សរុបកុមារអាយុ៦-១១ឆ្នាំបានចូលរៀនក្នុងសាលាបឋមសិក្សា | នាក់ | | | 26,410** |
| ភាគរយកុមារអាយុ៦-១១ឆ្នាំមិនបានទៅរៀន | % | | | 7.16** |
| ភាគរយអ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | % | 26.13 | 23.79 | 21.48 |
| ភាគរយស្ត្រីមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | % | 13.23 | 12.38 | 10.95 |
| ចំនួនស្ត្រីបានសំរាលកូនក្នុងឆ្នាំ | នាក់ | 3,224* | 3,340* | 3,722* |
| ភាគរយស្ត្រីសំរាលកូនដោយឆ្មបបុរាណ | % | 36* | 36* | 23* |
| អត្រាមរណៈមាតាក្រោយពេលសំរាល(0-១ខែ)ក្នុង១000កំណើត | នាក់ | 4* | 6* | 6* |
| ចំនួនទារកបានស្លាប់ក្រោយពេលកើត0-១ខែ | នាក់ | 17* | 32* | 22* |
| អត្រាមរណៈទារកអាយុពី0-១ខែក្នុង១000កំណើតរស់ | នាក់ | 6* | 8* | 6* |
| មរណភាពកុមារអាយុក្រោម៥ឆ្នាំ | នាក់ | 21* | 20* | 13* |
| ភាគរយមរណភាពបណ្តាលមកពីជម្ងឺផ្សេងៗ(អេដស៍ គ្រុនឈាម របេង គ្រុនចាញ់) | នាក់ | 7* | 6* | 2* |
| ភាគរយកុមារអាយុពី៩-១២ខែមិនបានចាក់ថ្នាំបង្ការគ្រប់ចំនួន | % | 9.51 | 8.34 | 3.35 |
| **ទិន្នន័យផ្នែកដីធ្លី ធនធានធម្មជាតិនិងបរិស្ថាន** | | | | |
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ | គ្រួសារ | | | 1,722 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ | នាក់ | | | 7,115 |
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីព្យុះ | គ្រួសារ | | | 12 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីព្យុះ | នាក់ | | | 44 |
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះរាំងស្ងួត | គ្រួសារ | | | 286 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះរាំងស្ងួត | នាក់ | | | 919 |
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះអគ្គីភ័យ | គ្រួសារ | | | 31 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះអគ្គីភ័យ | នាក់ | | | 129 |
| ចំនួនគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | គ្រួសារ | 287 | 492 | 370 |
| សរុបចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុល បរិស្ថាន | គ្រួសារ | 114 | 19 | 16 |
| ភាគរយគ្រួសារប្រើប្រាស់ជីគីមី | % | 1.15 | 3.96 | 2.17 |
| ភាគរយគ្រួសារប្រើប្រាស់ជីសរីរាង្គ | % | | | 8.02 |

| បរិយាយ | ឯកតា | ២០០៩ | ២០១០ | ២០១១ |
|---|---|---|---|---|
| ភាគរយគ្រួសារប្រើប្រាស់ថ្នាំគីមីសំលាប់សត្វល្អិត ស្មៅ | % | 1.11 | 1.75 | 4.86 |
| ភាគរយគ្រួសារប្រើប្រាស់ថ្នាំសរីរាង្គសំលាប់សត្វល្អិត ស្មៅ | % | | | 0.78 |
| ភាគរយគ្រួសារប្រើប្រាស់ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត | % | 3.22 | 4.00 | 2.86 |
| ភាគរយគ្រួសារប្រើប្រាស់ទឹកអណ្តូងស្នប់ឬអណ្តូងចំរុះ | % | 57.52 | 60.94 | 56.80 |
| ភាគរយគ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | % | 8.89 | 11.31 | 18.58 |
| **ទិន្នន័យផ្នែករដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់** | | | | |
| ភាគរយកុមារបានមកចុះបញ្ជីសំបុត្រកំណើត | % | 26.31 | 36.22 | 28.15 |
| ភាគរយគូស្រករដែលបានមកចុះលិខិតអាពាហ៍ពិពាហ៍ | % | | | 37.37 |
| ភាគរយមនុស្សបានចុះបញ្ជីមរណភាព | % | | | 20.60 |
| ចំនួនគ្រួសាររស់នៅលើដីសាធារណៈ | គ្រួសារ | 462 | 331 | 216 |
| ចំនួនមនុស្សចាស់ជរាគ្មានទីពឹង | នាក់ | 222 | 220 | 159 |
| សរុបចំនួនជនរងគ្រោះដោយការចាប់រំលោភ | នាក់ | | | 11 |
| សរុបចំនួនជនរងគ្រោះដោយការជួញដូរ | នាក់ | | | 9 |
| ចំនួនករណីលួច | ករណី | 174 | 209 | 167 |
| ចំនួនករណីទំនាស់ដីធ្លី | ករណី | 508 | 480 | 543 |
| ចំនួនគ្រួសារមានអំពើហឹង្សាក្នុងគ្រួសារ | គ្រួសារ | 1,085 | 863 | 1,006 |
| ផលធៀបចំនួនគ្រួសារមានអំពើហឹង្សាក្នុង១០០០គ្រួសារ | នាក់ | 28.97 | 21.65 | 21.78 |
| ចំនួនករណីអំពើហឹង្សាក្នុងគ្រួសារពាក់ពន្ធ័ដល់អាជ្ញាធរ | ករណី | | | 412 |
| ចំនួនជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ | នាក់ | | | 764 |
| ភាគរយស្ត្រីអាយុ១៨ឆ្នាំឡើងរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ | % | | | 35.08 |
| ចំនួនអ្នកស្លាប់ដោយអំពើហឹង្សាក្នុងគ្រួសារ | នាក់ | | | 32 |
| ភាគរយមរណភាពបណ្តាលមកពីអំពើហឹង្សា | % | | | 2.18 |
| ភាគរយមរណភាពបណ្តាលមកពីគ្រោះថ្នាក់ចរាចរ | % | | | 6.14 |
| ភាគរយមរណភាពបណ្តាលមកពីគ្រោះធម្មជាតិ (ទឹកជំនន់ ខ្យល់ព្យុះ រន្ទះ) | % | | | 1.23 |
| ភាគរយមរណភាពបណ្តាលមកពីជម្ងឺផ្សេងៗ | % | 2* | 1.5* | 1* |
| ចំនួនករណីផ្ទុះមីនសល់ពីសង្គ្រាមក្នុងឆ្នាំ | ករណី | | | 6 |
| ចំនួនអ្នកស្លាប់ដោយសារការផ្ទុះមីនសល់ពីសង្គ្រាម | នាក់ | | | 2 |
| ចំនួនជនរងរបួសដោយសារការផ្ទុះមីនសល់ពីសង្គ្រាម | នាក់ | | | 7 |
| ចំនួនករណីផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម | ករណី | | | 8 |
| ចំនួនអ្នកស្លាប់ដោយសារផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម | នាក់ | | | 3 |
| ចំនួនអ្នករងរបួសដោយសារផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម | នាក់ | | | 16 |
| ចំនួនផ្ទៃដីដែលបានសំអាតមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម | ហិកតា | | | 185 |

ប្រភព: ទិន្នន័យមូលដ្ឋានឃុំ សង្កាត់ឆ្នាំ២០១១ (CDB) , * ព័តិមានពីមន្ទីរសុខាភិបាល , ** ព័តិមានពីមន្ទីរអប់រំ

## ១.២ ស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម

ខេត្តព្រះវិហារស្ថិតនៅតំបន់ខ្ពង់រាបប៉ែកឧត្តរនៃព្រះរាជាណាចក្រកម្ពុជា ដែលសំបូរទៅដោយធនធានធម្មជាតិដូចជា ព្រៃឈើ រ៉ែ ទន្លេ ស្ទឹង អូរ ដីមានជីជាតិ ដែលអំណោយផលយ៉ាងខ្លាំងដល់ប្រជាកសិករ ក្នុងការប្រកបមុខរបរកសិកម្ម។ លើសពីនេះទៀត ខេត្តមានប្រាសាទបុរាណជាច្រើនដូចជា ប្រាសាទព្រះវិហារ ក្រុមប្រាសាទកោះកែរ ក្រុមប្រាសាទព្រះខ័ន្ធ និងប្រាសាទជាច្រើនទៀត ដែលមានឈ្មោះល្បីល្បាញ។ ខេត្តព្រះវិហារស្ថិតនៅចំងាយប្រមាណ ២៩៨គ.ម ពីរាជធានីភ្នំពេញ ដោយធ្វើដំណើរតាមផ្លូវជាតិលេខ៦ មកដល់ទីរួមខេត្តកំពង់ធំ និងផ្លូវជាតិលេខ៦២ ពីទីរួមខេត្តកំពង់ធំដែលមានចំងាយ១២៨គ.ម មកទីរួមខេត្តព្រះវិហារដែលស្ថិតនៅក្នុងក្រុងព្រះវិហារ។ ខេត្តមានព្រំប្រទល់ខាងជើងទល់នឹងប្រទេសថៃ និងប្រទេសឡាវ ខាងកើតទល់នឹងខេត្តស្ទឹងត្រែង ខាងត្បូងទល់នឹងខេត្តកំពង់ធំ និងខាងលិចទល់នឹងខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ។

ខេត្តព្រះវិហារមានផ្ទៃដីសរុបចំនួន១៤.០៣១គ.ម$^{២}$ ចែកចេញជា៧ស្រុក និង១ក្រុង។ មាន៤៩ឃុំ ២សង្កាត់ ២២៩ភូមិ មាន៤៦.១៨៤គ្រួសារ ដែលមានប្រជាជនសរុប២០៤.០០៩នាក់ ក្នុងនោះស្រី១០២.៧៣០នាក់ ស្មើ ៥០,៣៥%)។ ដង់ស៊ីតេប្រជាពលរដ្ឋជាមធ្យមចំនួន១៤.៥៣នាក់ ក្នុងមួយគីឡូម៉ែត្រក្រឡា។ ប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារមានការកើនឡើងដោយកំណើនរបស់ប្រជាពលរដ្ឋផ្ទាល់ក្នុងខេត្ត និងកំណើនដោយសារការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋមកពីខេត្តផ្សេងៗចូលមកតាំងទីលំនៅ។ កំណើនប្រជាពលរដ្ឋ និងលំហូរចូលរបស់ប្រជាពលរដ្ឋពីខេត្តដទៃទៀតជាកត្តាមួយនៃការរួមចំណែកធ្វើឱ្យមានការបាត់បង់ដីព្រៃដែលធ្វើឱ្យមានការ ប៉ះពាល់ដល់បរិស្ថាន ធនធានធម្មជាតិ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ។

**តារាង៖ ស្ថិតិប្រជាជន** (ប្រភព : ទិន្នន័យឃុំឆ្នាំ២០១១ )

| | ឆ្នាំ2009 | ឆ្នាំ2010 | ឆ្នាំ2011 |
|---|---|---|---|
| ចំនួនគ្រួសារសរុប | 37,456 គ្រួសារ | 41,532 គ្រួសារ | 46,184 គ្រួសារ |
| កើន/ថយ | 7% | 11% | 11% |
| ចំនួនប្រជាជនសរុប | 175,500 នាក់ | 191,246 នាក់ | 204,009 នាក់ |
| កើន/ថយ | 5% | 9% | 7% |
| ចំនួនគ្រួសារដែលស្ត្រីជាមេគ្រួសារ | 3,612 គ្រួសារ | 4,261 គ្រួសារ | 7,242 គ្រួសារ |

**តារាង៖ ចំនួនប្រជាជន ទំហំគ្រួសារ និងចំនួនស្ត្រីជាមេគ្រួសារ** ( ប្រភព : ទិន្នន័យឃុំឆ្នាំ២០១១ )

| ស្រុក | ចំនួនឃុំ | ចំនួនភូមិ | ចំនួនគ្រួសារ | ចំនួនប្រជាជន | | ទំហំគ្រួសារ | ចំនួនស្ត្រីជាមេគ្រួសារ | |
|---|---|---|---|---|---|---|---|---|
| | | | | សរុប | ស្រី | | សរុប | % |
| ជ័យសែន | 6 | 21 | 4,814 | 22,203 | 11,429 | 4.61 | 311 | 6.46 |
| ឆែប | 8 | 26 | 3,750 | 18,518 | 9,440 | 4.94 | 415 | 11.07 |
| ជាំក្សាន្ត | 8 | 46 | 12,086 | 48,052 | 24,403 | 3.98 | 3,531 | 29.22 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| គូលែន | 6 | 23 | 6,821 | 30,459 | 15,095 | 4.47 | 697 | 10.22 |
| រវៀង | 12 | 57 | 8,054 | 37,790 | 18,938 | 4.69 | 748 | 9.29 |
| សង្គមថ្មី | 5 | 24 | 3,995 | 17,995 | 9,207 | 4.50 | 680 | 17.02 |
| ត្បែងមានជ័យ | 4 | 12 | 2,287 | 9,042 | 4,307 | 3.95 | 210 | 9.18 |
| ក្រុងព្រះវិហារ | 2 | 20 | 4,377 | 19,950 | 9,911 | 4.56 | 650 | 14.85 |
| **សរុប** | **51** | **229** | **46,184** | **204,009** | **102,730** | **4.42** | **7,242** | **15.68** |

### ១.២.១ ស្ថានភាពសេដ្ឋកិច្ច

#### ១.២.១.១ វិស័យកសិកម្ម

បច្ចុប្បន្ននេះ ប្រជាពលរដ្ឋក្នុងខេត្តព្រះវិហារភាគច្រើន (៩៤.៣៣ភាគរយ) រស់នៅពឹងផ្អែកលើរបរកសិកម្ម ក្នុងនោះ ធ្វើស្រែ ៦៩.៣៧ភាគរយ ធ្វើចំការ ១៩.៧៥ ភាគរយ នេសាទ ០.២៧ ភាគរយ ចិញ្ចឹមសត្វ ២.៤៦ ភាគរយ និងអនុផលព្រៃឈើ ២.៤៨ ភាគរយ។ ក្រៅពីនោះប្រកបមុខរបរធ្វើសិប្បកម្ម ០.៥២ ភាគរយ និងប្រកបមុខរបរធ្វើសេវាកម្ម ៣.០៩ ភាគរយ ។ ផ្ទៃដីដែលអាចធ្វើការងារកសិកម្មបានមានចំនួន ១១៨.៣៤៨ហ.ត ។ ប៉ុន្តែមកទល់បច្ចុប្បន្ន ការដាំដុះដំណាំស្រូវបានចំនួន ៥៦.១៨៣ហ.ត ស្មើ១០១,១៨%នៃផ្ទៃដីផែនការ ៥៥.៥២៦ហ.ត និងដំណាំផ្សេងៗ ទៀតបាន៦២.១៦៥ហ.ត ស្មើ៩៥,៩១%នៃផ្ទៃដីផែនការ៦៤.៨១៨ហ.ត (ចំពោះផ្ទៃដីដាំដំណាំកសិករដាំដុះបាន២ដង ក្នុង១ឆ្នាំ) ។ ទិន្នផលស្រូវសរុប នៅឆ្នាំ២០១១មានចំនួន ១៤៣.៥០៧តោន លើផ្ទៃដីប្រមូលផលសរុប ៤៤.៨៧៧ហ.ត ដោយឡែកនៅឆ្នាំដដែលនេះ ផ្ទៃដីរងផលប៉ះពាល់ និងខូចខាតមានចំនួន២០១៨ហ.ត។ ស្រូវសល់ជាចំណីមានចំនួន ១២៤.៨៥១ តោន បើគិតលើទិន្នផលជាអង្ករក្នុងអត្រា ៦៤% ស្មើ៧៩.៩០៥តោន។ ចំពោះតម្រូវការអង្ករក្នុងខេត្ត ព្រះវិហារមានចំនួន ២៨.២៤៥តោន បើវិភាគលើតុល្យភាពស្បៀង គិតជាអង្ករគឺមានចំនួនលើស៣៧.៧៤៨តោន ដែលតុល្យភាពស្បៀងនេះគិតជាស្រូវ គឺលើស៥៨.៩៨១តោន។ ចំពោះការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១២ មន្ទីរបានរៀបចំគ្រោងផែនការជាមួយឃុំស្រុកគោលដៅលើផែនការចំនួន ៥៧.៥០០ហ.ត ដែលមកទល់ បច្ចុប្បន្ននេះអនុវត្តជាក់ស្តែងបានចំនួន ៥៩.៨៥៩ហ.ត ស្មើនិង១០៤ ភាគរយ ។

ដោយឡែកផលិតកម្ម និងបសុព្យាបាល ក៏ជាមុខរបរមួយដ៏សំខាន់បន្ទាប់ពីដំណាំស្រូវរបស់ប្រជាពលរដ្ឋក្នុងខេត្តដែរ ។ ជាទូទៅប្រជាពលរដ្ឋមានប្រពៃណីចិញ្ចឹមសត្វសំរាប់លក់ដូរសម្រាប់ដោះស្រាយជីវភាពប្រចាំថ្ងៃ។ ប្រជាពលរដ្ឋ ៧១% ចិញ្ចឹមសត្វពាហនៈ(គោ-ក្របី)ជាលក្ខណៈគ្រួសារសំរាប់ជាកំលាំងអូសទាញ និងលក់ដូរបង្កើនប្រាក់ចំណូលគ្រួសារបន្ថែម។ ទន្ទឹមនឹងការអភិវឌ្ឍវិស័យកសិកម្ម ក៏មានបញ្ហាប្រឈមមួយចំនួនផងដែរដែលរាំងស្ទះខ្លះៗដែរដល់វិស័យកសិកម្ម មានដូចជា ការរាំងស្ងួត គ្រោះទឹកជំនន់ ទិន្នផលទាប ការប្រើប្រាស់ពូជបុរាណ, ខ្វះការត្រួតពិនិត្យ និងថែទាំ សត្វពាហនៈកើតជម្ងឺជាដើម ។

ដើម្បីរួមចំណែកកាត់បន្ថយកត្តាហានិភ័យទាំងអស់នេះ មន្ទីរកសិកម្មបានដាក់ចេញនូវយុទ្ធសាស្ត្រជាអាទិភាពចំបងៗស្របតាមផែនការអភិវឌ្ឍន៏បច្ចុប្បន្នកម្ម២០០៩-២០១៣ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ធ្វើយ៉ាងណាកាត់បន្ថយជាបណ្តើរៗ ដើម្បីដឹកនាំវិស័យកសិកម្មនៅក្នុងខេត្តព្រះវិហារឈានទៅរកការរីក

ចំរើនដូចបណ្តាខេត្តនានា។

ក្រៅពីនេះក៏មានស្ថាប័នរដ្ឋ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនផងដែរ ដែលបានសហការ និងគាំទ្រក្នុងវិស័យនេះ ដើម្បីឱ្យប្រជាកសិករមានជីវភាពប្រសើរឡើង។ ជាក់ស្តែង ក្នុងឆ្នាំ២០១២ កន្លងមកនេះមាន មន្ទីរអភិវឌ្ឍន៍ជនបទ មន្ទីរកិច្ចការនារី មន្ទីរសង្គមកិច្ចយុទ្ធជន និងយុវនិតិសម្បទា ខ័ណ្ឌរដ្ឋបាលព្រៃឈើ មន្ទីរដែនដីនគរូបនីយកម្មសំណង់និងសុរិយោដី មន្ទីរធនធានទឹកនិងឧតុនិយម អង្គការទស្សនៈពិភពលោក អង្គការអាដ្រា អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ អង្គការការិតាសបានចុះចែកពូជដំណាំ និងចុះផ្សព្វផ្សាយអំពីបច្ចេកទេសដាំដំណាំបន្លែ ផ្សព្វផ្សាយអំពីផលប៉ះពាល់នៃការប្រើប្រាស់ជីគីមី ផ្សព្វផ្សាយអំពីច្បាប់ព្រៃឈើ ផ្សព្វផ្សាយអំពីច្បាប់ភូមិបាលដល់ប្រជាពលរដ្ឋនៅតាមមូលដ្ឋាន និងបានចុះជួយចាក់វ៉ាក់សាំងដល់សត្វគោ ក្របី និងរៀបចំប្រព័ន្ធស្រោចស្រពនៅតាមមូលដ្ឋានទាំងនោះផងដែរ។

**តារាង: ការចិញ្ចឹមសត្វ (យោងស្ថិតិភូមិ ឆ្នាំ២០១១)**

| ប្រភេទសត្វដែលបានចិញ្ចឹម | 2011 | | |
|---|---|---|---|
| | ចំនួនគ្រួសារចិញ្ចឹម | %គ្រួសារចិញ្ចឹមសត្វ | សរុបសត្វដែលបានចិញ្ចឹម |
| គោ | 21,356 គ្រួសារ | 46.24% | 81,258 ក្បាល |
| ក្របី | 3,990 គ្រួសារ | 8.64% | 12,752 ក្បាល |
| ជ្រូក | 18,358 គ្រួសារ | 39.75% | 34,772 ក្បាល |
| មាន់ | 29,707 គ្រួសារ | 64.32% | 156,813 ក្បាល |
| ទា | 4,988 គ្រួសារ | 10.80% | 23,151 ក្បាល |
| ពពែ | 70 គ្រួសារ | 0.15% | 207 ក្បាល |
| ត្រី | 151 គ្រួសារ | 0.33% | 4,759គ.ក្រ |

**តារាង: ស្ថានភាពមុខរបរក្នុងវិស័យរបស់ប្រជាជនក្នុងខេត្ត** (យោងស្ថិតិភូមិឆ្នាំ២០១១)

| បរិយាយ | 2011 | | | |
|---|---|---|---|---|
| | មុខរបរជាចំបង | | មុខរបរបន្ទាប់បន្សំ | |
| | ចំនួនសរុប | ភាគរយ | ចំនួនសរុប | ភាគរយ |
| **មនុស្សប្រកបមុខរបរធ្វើកសិកម្ម** | **78,226** | **71.91** | **24,395** | **22.42** |
| ធ្វើស្រែ | 68,622 | 63.08 | 6,840 | 6.29 |
| ដាំដំណាំរយៈពេលវែង | 3,420 | 3.14 | 3,246 | 2.98 |
| ដាំដំណាំរយៈពេលខ្លី | 4,311 | 3.96 | 7,593 | 6.98 |
| ដាំដំណាំបន្លែ | 953 | 0.88 | 1,973 | 1.81 |
| នេសាទ | 132 | 0.12 | 158 | 0.15 |
| ចិញ្ចឹមសត្វ | 229 | 0.21 | 2,445 | 2.25 |
| អនុផលព្រៃឈើ | 559 | 0.51 | 2,140 | 1.97 |
| **មនុស្សប្រកបមុខរបរធ្វើសិប្បកម្ម** | **363** | **0.33** | **211** | **0.19** |
| ត្បាញរវៃ | 4 | 0.00 | 40 | 0.04 |

| | | | | |
|---|---|---|---|---|
| ផលិតពីផ្តៅ ឫស្សី រល្លី | 35 | 0.03 | 109 | 0.1 |
| គ្រឿងសង្ហារឹម(តុ ទូ កៅអី ...) | 255 | 0.23 | 60 | 0.06 |
| ចម្លាក់ពីស្ពាន់ ថ្ម ស្បែក | 6 | 0.01 | 0 | 0.00 |
| ផលិតពីដែក អាលុយ៉ូមីញ៉ូម កញ្ចក់ | 45 | 0.04 | 1 | 0 |
| ផលិតពីជ័រផ្លាស់ស្ទិក | 12 | 0.01 | 0 | 0.00 |
| កែឆ្នៃឬវិចខ្ចប់គ្រាប់ធញ្ញជាតិ | 6 | 0.01 | 0 | 0.00 |
| ផ្សេងៗដែលគ្មានឈ្មោះខាងលើ | 0 | 0.00 | 1 | 0.00 |
| **មនុស្សប្រកបមុខរបរធ្វើសេវាកម្ម** | **2,676** | **2.46** | **682** | **0.63** |
| លក់ដូរឬធ្វើជំនួញ | 2,233 | 2.05 | 490 | 0.45 |
| ជាងជួសជុល | 307 | 0.28 | 90 | 0.08 |
| វិស័យដឹកជញ្ជូន | 136 | 0.13 | 102 | 0.09 |
| **មនុស្សទទួលបានប្រាក់ខែឬប្រាក់ប្រចាំថ្ងៃ** | **7,370** | **6.77** | **861** | **0.79** |
| ស៊ីឈ្នួលក្នុងវិស័យកសិកម្ម សំណង់ ... | 559 | 0.51 | 821 | 0.75 |
| ធ្វើការក្នុងវិស័យឯកជន អង្គការ | 217 | 0.2 | 32 | 0.03 |
| ធ្វើការក្នុងផ្នែករដ្ឋាភិបាល | 6,594 | 6.06 | 8 | 0.01 |

### ១.២.១.២ វិស័យជលផល

វិស័យជលផលនៅក្នុងខេត្តព្រះវិហារ បានផ្តល់លទ្ធភាព និងធនធានជលផល(ត្រី)សម្រាប់ជាម្ហូបអាហារ (ត្រីសាច់ ត្រីប្រហុក ផ្អក...)សម្រាប់ប្រជាពលរដ្ឋ បានមួយរយៈកាលក្នុងរដូវបើកនេសាទកន្លងមកនេះ។ ទន្ទឹមនេះ ខណ្ឌរដ្ឋបាលជលផលបានខិតខំអនុវត្តការងារសកម្មភាព ដូចជា ការគ្រប់គ្រងធនធានជលផលតាមរយៈការបង្កើតសហគមន៍ស្រះជម្រកត្រី ការអភិវឌ្ឍវារីវប្បកម្មជាលក្ខណៈគ្រួសារ (ចិញ្ចឹមត្រី និងការផលិតកូនត្រីពូជ)ដែលបានសហការ និងការជួយគាំទ្រគម្រោងពីរដ្ឋបាលជលផល អង្គការជាតិ និងអន្តរជាតិនានា (FAO/EUFF ,DFID/ DANIDA, NCCD...)។ ដោយឡែកក្រៅពីការងារខាងលើ ខណ្ឌបានខិតខំទប់ស្កាត់នូវបទល្មើសមួយចំនួនដោយមានការចូលរួមសហការពីអាជ្ញាធរពាក់ព័ន្ធតាមរយៈការចុះផ្សព្វផ្សាយច្បាប់ស្តីពីជលផល ចុះពិនិត្យសកម្មភាពធ្វើនេសាទហួសកំរិត និងសកម្មភាពនេសាទខុសច្បាប់ផ្សេងៗ។ ខណ្ឌរដ្ឋបាលជលផលមានការជួបប្រទះបញ្ហាមួយចំនួន ដូចជា:

- ខ្វះមន្ត្រី ដើម្បីបម្រើការងារនៅថ្នាក់ខណ្ឌ ផ្នែក និងសង្កាត់រដ្ឋបាលជលផល។
- ពុំមានដីធ្លីសម្រាប់បង្កើតស្នាក់ការខណ្ឌ និងផ្នែក-សង្កាត់រដ្ឋបាលនៅថ្នាក់ក្រុង ស្រុក។
- ពុំមានកញ្ចប់ថវិកាដើម្បីដំណើរការសកម្មភាពការងារ និងអភិវឌ្ឍន៍ ដូចបណ្តាមន្ទីរជំនាញនានា។

បញ្ហាដូចបានរាប់ខាងលើនេះបណ្តាលមកពីការផ្តាច់ចេញរដ្ឋបាលគ្រប់គ្រងរយៈខ្សែបណ្តោយ និងពុំទាន់បានរៀបចំនូវថវិកា និងហេដ្ឋារចនាសម្ព័ន្ធអគាររូបវ័ន្តនានាសម្រាប់ខណ្ឌផ្នែកនិងសង្កាត់រដ្ឋបាលជលផលឱ្យបានទាន់ពេល មុននឹងផ្តាច់ចេញពីមន្ទីរកសិកម្មខេត្ត។

ទោះបីជាយ៉ាងនេះក៏ដោយបច្ចុប្បន្នខណ្ឌបានដោះស្រាយ និងសម្របសម្រួលឱ្យមានស្ថានភាពល្អខ្លះៗផងដែរ ដូចជា:

- បានជួលទីស្នាក់ការបណ្ដោះអាសន្ន ដើម្បីមានទីតាំងច្បាស់លាស់មានកន្លែងធ្វើការ និងការស្នាក់អាស្រ័យការងាររបស់មន្ត្រីជំនាញ។
- បានស្នើសុំជំនួយពីរដ្ឋបាលជលផល និងបានរកដៃគូអភិវឌ្ឍន៍នានា ដើម្បីជួយអភិវឌ្ឍន៍ការងារវិស័យជលផល និងជួយដល់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រះវិហារ ។
- បានរៀបចំគម្រោង និងសំណើផ្សេងៗដាក់បញ្ចូលទៅក្នុងផែនការថ្នាក់ជាតិ និងកំពុងបានដំណើរការសកម្មភាពគម្រោង ដើម្បីលើកស្ទួយវិស័យជលផលក្នុងគោលបំណង គាំទ្រដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅតាមភូមិ ឃុំ សង្កាត់ ក្រុង ស្រុក។

### ១.២.១.៣ វិស័យធនធានទឹក និងឧតុនិយម

ខេត្តព្រះវិហារ មានប្រព័ន្ធធារាសាស្ត្រចាស់ៗជាច្រើនដែលបានសាងសង់ក្នុងកំឡុងឆ្នាំ១៩៧៥-៧៩។ ប៉ុន្តែប្រព័ន្ធធារាសាស្ត្រទាំងនោះបានខូចខាតស្ទើរតែទាំងស្រុង ដោយសារខ្វះការថែទាំ និងសំណង់ដែលពុំមានគុណភាពល្អ។ ចាប់តាំងពីឆ្នាំ២០០១មក មន្ទីរធនធានទឹកបានរៀបចំធ្វើការសិក្សា និងស្វែងរកទុនក្នុងការជួសជុលស្តារឡើងវិញនូវប្រព័ន្ធធារាសាស្ត្រទាំងនោះជាបណ្តើរៗ ដើម្បីចូលរួមដោះស្រាយបញ្ហាទឹកក្នុងការងារកសិកម្មជូនប្រជាពលរដ្ឋតាមមូលដ្ឋាន។ ប្រព័ន្ធធារាសាស្ត្ររួមមាន ទំនប់អាងទឹកចំនួន២១៩ទំនប់(ប្រើប្រាស់បានចំនួន១៦ទំនប់) ស្រះទឹកចំនួន៧៦ស្រះ(ប្រើប្រាស់បានចំនួន២៦ស្រះ) ប្រឡាយចំនួន៤៥ខ្សែ(ប្រើប្រាស់បានចំនួន១៣ខ្សែ) ទ្វារទឹកចំនួន១៤០កន្លែង (ប្រើប្រាស់បានចំនួន៣៣កន្លែង) លូដោះទឹកចំនួន៨១កន្លែង (ប្រើប្រាស់បានចំនួន៩កន្លែង) និងទំនប់បង្វែរ ចំនួន១៩កន្លែង(ប្រើប្រាស់បានចំនួន១៣កន្លែង)។

**តារាងៈ ស្ថិតិប្រព័ន្ធធារាសាស្ត្រ (*ប្រភពៈ* *ទិន្នន័យមន្ទីរធនធានទឹក និងឧតុនិយម*)**

| ល.រ | បរិយាយ | ទំនប់អាងទឹក | | ស្រះទឹក | | ប្រឡាយ | | ទ្វារទឹក | | ទំនប់បង្វែរ | | លូដោះទឹក |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | ប្រើបាន | សរុប | ប្រើបាន | សរុប | ប្រើបាន | សរុប | ប្រើបាន | សរុប | ប្រើបាន | (កន្លែង) |
| ១ | ក្រុងព្រះវិហារ | ០៥ | ០២ | ០ | ០ | ០៣ | ០៣ | ០៥ | ០៣ | ០១ | ០១ | ០២ |
| ២ | ស្រុកគូលែន | ៤២ | ០១ | ២៥ | ០៨ | ០៥ | ០២ | ៤០ | ០១ | ០ | ០ | ២៣ |
| ៣ | ស្រុកសង្គមថ្មី | ៣៣ | ០៣ | ១១ | ០ | ០៥ | ០ | ២០ | ០៤ | ០២ | ០២ | ១៣ |
| ៤ | ស្រុកជាំក្សាន្ត | ៣៩ | ០៤ | ១៣ | ១៣ | ០៦ | ០៣ | ១៩ | ១៦ | ០៥ | ០៥ | ០៩ |
| ៥ | ស្រុកត្បែង | ២០ | ០១ | ០៤ | ០ | ០៤ | ០ | ០៨ | ០១ | ០១ | ០១ | ០៧ |
| ៦ | ស្រុករវៀង | ៤២ | ០២ | ០២ | ០ | ០៥ | ០១ | ១៤ | ០២ | ០២ | ០២ | ០៥ |
| ៧ | ស្រុកឆែប | ២០ | ០១ | ០៨ | ០១ | ០៩ | ០១ | ១៧ | ០១ | ០១ | ០១ | ១៤ |
| ៨ | ស្រុកជ័យសែន | ១៨ | ០២ | ១៣ | ០៤ | ០៨ | ០៣ | ១៧ | ០៥ | ០៧ | ០១ | ០៨ |
| **សរុប** | | **២១៩** | **១៦** | **៧៦** | **២៦** | **៤៥** | **១៣** | **១៤០** | **៣៣** | **១៩** | **១៣** | **៨១** |

ទិន្នន័យតាមដានកម្ពស់ទឹកភ្លៀងតាមបណ្តាស្រុកនានាមានចំនួន០២ស្រុក ០១ក្រុង និងការតាមដានកម្ពស់ទឹកជំនន់នៅតាមដងស្ទឹងសែនមាន ០១ កន្លែងនៅក្រុងព្រះវិហារ។

**បញ្ហាជួបប្រទះនិងមូលហេតុនៃបញ្ហាៈ** យោងតាមស្ថានភាពជាក់ស្តែងបច្ចុប្បន្នកសិករ ទូទាំងខេត្តខ្វះលទ្ធភាពនាំទឹកសម្រាប់ស្រោចស្រពក្នុងការងារបង្កបង្កើតផល។ ម្យ៉ាងទៀតនៅតំបន់មួយចំនួនមាន

ប្រព័ន្ធស្រោចស្រពហើយប៉ុន្តែប្រជាពលរដ្ឋខ្វះការគ្រប់គ្រងថែទាំ។ ប្រជាពលរដ្ឋមួយចំនួនរស់នៅឆ្ងាយពីប្រភពទឹក ពេលជួបគ្រោះរាំងស្ងួតមិនអាចនាំទឹកទៅជួយសង្គ្រោះបានទាន់ពេលវេលា។ ជាទូទៅការអនុវត្តនីគម្រោងភាគច្រើនចំរដូវវស្សានាំឱ្យមានការយឺតយ៉ាវ។

**បញ្ហាឧតុនិយមនិងជលសាស្ត្រ:** ទាក់ទងនឹងទិន្នន័យកម្ពស់ទឹកភ្លៀងនៅតាមបណ្តាស្រុកទាំង០៧ និង០១ក្រុង សមត្ថភាព និងឧបករណ៍របស់ភ្នាក់ងារតាមដាននៅមានកំរិតនៅឡើយ។ ក្នុងនោះប៉ុស្តិ៍សម្រាប់ពិនិត្យ និងយកទិន្នន័យមានការខូចខាត រីឯការតាមដានកម្ពស់ទឹកជំនន់តាមដងស្ទឹងសែនវិញពុំទាន់មានគ្រប់គ្រាន់តាមតម្រូវការនៅឡើយ។

**ដំណោះស្រាយ:** គោលបំណងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ និងផែនការសកម្មភាពរបស់មន្ទីរធនធានទឹក និងឧតុនិយមគឺដើម្បីលើកកម្ពស់មុខរបរកសិកម្មជូនប្រជាពលរដ្ឋ តាមរយៈសកម្មភាពដូចខាងក្រោម :

- ជួសជុលទំនប់ អាងទឹក ស្ពានស្រះ ត្រពាំង បឹងបួរ ដែលមានស្រាប់ និង ស្ពានប្រឡាយ ឬប្រព័ន្ធស្រោចស្រពឡើងវិញ ។
- ជួសជុលប៉ុស្តិ៍តាមដានតម្រងទឹកភ្លៀងទាំង ០៧ស្រុក និងប៉ុស៏តាមដានកម្ពស់ទឹកជំនន់នៅតាមដងស្ទឹងសែនបន្ថែមទៀត។
- រៀបចំ និងពង្រឹងដល់សហគមន៍កសិករប្រើប្រាស់ទឹកដែលមានស្រាប់ ដើម្បីចូលរួមលើការគ្រប់គ្រងថែរក្សាឱ្យបាននូវនិរន្តរភាព។
- បង្កើតសហគមន៍កសិករប្រើប្រាស់ទឹកបន្ថែម ដើម្បីចូលរួមលើការគ្រប់គ្រងថែរក្សាប្រព័ន្ធស្រោចស្រពក្រោយពេលជួសជុលរួច។

### ១.២.១.៤ វិស័យទេសចរណ៍

ខេត្តមានសក្តានុពលវប្បធម៌និងធម្មជាតិសំបូរបែបដែលជាប្រភពទាក់ទាញភ្ញៀវទេសចរនិងដៃគូអភិវឌ្ឍន៍នានា ដើម្បីចូលរួមអភិវឌ្ឍន៍វិស័យទេសចរណ៍នៅក្នុងខេត្តប្រកបដោយនិរន្តរភាព។ ម្យ៉ាងវិញទៀត ខេត្តមានបណ្តាញផ្លូវគមនាគមន៍តភ្ជាប់ទៅបណ្តាខេត្តដែលនៅជុំវិញដូចជាខេត្តសៀមរាប ខេត្តឧត្តរមានជ័យ ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង។ ពិសេសទៅទៀតខេត្តព្រះវិហារមានទំនាក់ទំនងល្អជាមួយខេត្តប្រទេសជិតខាងនៅតាមបណ្តោយព្រំដែនដូចជាខេត្តចម្ប៉ាសាក់នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ខេត្តឧប៊ុនរាជធានី ខេត្តស៊ីសាកេត ខេត្តសារិននៃប្រទេសថៃ និងកំពុងត្រៀមលក្ខណៈសម្បត្តិបើកច្រកអានសេះសម្រាប់ទំនាក់ទំនងលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច ទេសចរណ៍ជាដើម។ មន្ទីរទេសចរណ៍មានយុទ្ធសាស្ត្រ និងយន្តការដឹកនាំត្រឹមត្រូវពីក្រសួងទេសចរណ៍ និងរដ្ឋបាលខេត្ត ពិសេសគឺមានច្បាប់ស្តីពីទេសចរណ៍ដែលជាមូលដ្ឋានគ្រឹះក្នុងការអនុវត្តព្រមទាំងមានការគាំទ្រ និងសហការល្អពីបណ្តាមន្ទីរ អង្គភាព អាជ្ញាធរដែនដី និង ផ្នែកឯកជន ក៏ដូចជាអង្គការពាក់ព័ន្ធនានានៅក្នុងខេត្ត។

វិស័យទេសចរណ៍បានដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកកសាងសេដ្ឋកិច្ចសង្គម ផ្តល់ឱកាសការងារ បង្កើនប្រាក់ចំណូល លើកកម្ពស់ជីវភាពរស់នៅ និងការរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្រោមការចាត់តាំងអនុវត្តតាមទិសដៅជាយុទ្ធសាស្ត្រនិងរាល់លិខិតបទដ្ឋានរបស់ក្រសួងទេសចរណ៍និងការដឹកនាំផ្ទាល់របស់ខេត្ត ធ្វើឱ្យស្ថានភាពវិស័យទេសចរណ៍នៅក្នុងខេត្តព្រះវិហារគិតមក

ដល់ពេលនេះបានរីកចម្រើនជាបន្តបន្ទាប់ ពិសេសចាប់ពីក្រោយពេលដែលប្រាសាទព្រះវិហារត្រូវបានដាក់បញ្ចូលជាសម្បត្តិបេតិកភ័ណ្ឌពិភពលោកកាលពីថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៨ កន្លងមកនេះ **សម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានយកចិត្តទុកដាក់អភិវឌ្ឍយ៉ាងគំហុកលើគ្រប់វិស័យ ពិសេសបណ្តាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់តភ្ជាប់ពីខេត្តដែលនៅជុំវិញមកកាន់ខេត្តព្រះវិហារ ដូចជា ផ្លូវជាតិលេខ៦២ លេខ៩ និងលេខ២៦២៩ជាដើម។ លើមូលដ្ឋានដ៏សំខាន់នេះ បានជម្រុញភ្ញៀវទេសចរឱ្យមកទស្សនាកំសាន្តនៅខេត្តព្រះវិហារមានកំណើនកើនឡើងជារៀងរាល់ឆ្នាំ លើកលែងតែចុងឆ្នាំ ២០០៩ និង ឆ្នាំ ២០១១ ដែលអត្រាភ្ញៀវទេសចរបានធ្លាក់ចុះប្រមាណ ៧,៨៣ % និង ៥១,៤២ % ដោយសារការឈ្លានពានរបស់ប្រទេសថៃ ដែលបានបង្កើតឱ្យមានសង្គ្រាមនៅតាមព្រំដែន និងប្រាសាទព្រះវិហារ។

**តារាងស្ថិតិភ្ញៀវទេសចរទស្សនាខេត្តព្រះវិហាររយៈពេល៩ឆ្នាំ ២០០៦-២០១២**

| លំដាប់ឆ្នាំ | ភ្ញៀវជាតិ | ភ្ញៀវអន្តរជាតិ | សរុប | ប្រៀបធៀប | ផ្សេងៗ |
|---|---|---|---|---|---|
| 2006 | 18.972 | 73.876 | 92.848 | + 4,55 % | +4.233 |
| 2007 | 37.530 | 90.693 | 128.223 | +27,58 % | +35.375 |
| 2008 | 65.182 | 62.258 | 127.440 | -0,61 % | -783 |
| 2009 | 53.391 | 8.512 | 61.903 | -51,42 % | -65.537 |
| 2010 | 124.408 | 11.249 | 135.657 | +54,36 % | +73.754 |
| 2011 | 114.463 | 10.572 | 125.035 | -7.83% | |
| 2012/9ខែដើមឆ្នាំ | 142.910 | 13.140 | 156.050 | +59.19% | +58.027 |
| សរុប | **556.856** | **270.300** | **827.156** | | |

*( ប្រភព : ទិន្នន័យមន្ទីរទេសចរណ៍)*

លើមូលដ្ឋាននៃចំនួនភ្ញៀវទេសចរខាងលើនេះ យើងបានកត់សម្គាល់ឃើញថា អត្រានៃការស្នាក់នៅរបស់ភ្ញៀវនៅតាមផ្ទះសំណាក់នៅក្នុងខេត្ត ក្នុងមួយឆ្នាំៗមានប្រមាណ២៣,៩៧ % ប៉ុណ្ណោះ ឯក្រៅពីនេះជាភ្ញៀវវិលល្ងាច ឬភ្ញៀវទៅសម្រាកនៅខេត្តផ្សេងៗវិញ ដែលគេយល់ឃើញថាមានសេវាល្អជាង ឬ ការធ្វើដំណើរមានលក្ខណៈងាយស្រួលដែលមិនចាំបាច់ឱ្យពួកគេស្នាក់នៅក្នុងទីរួមខេត្តព្រះវិហារ។

ខេត្តព្រះវិហារមានប្រភពធនធានទាំងវប្បធម៌ និងធម្មជាតិសម្រាប់ទាក់ទាញភ្ញៀវទេសចរឱ្យមកទស្សនាកំសាន្ត ដូចមានក្នុងតារាងខាងក្រោម :

**តារាង: គោលដៅទេសចរណ៍ដែលភ្ញៀវអាចទៅទស្សនាកំសាន្តបាន** *( ប្រភព : ទិន្នន័យមន្ទីរទេសចរណ៍)*

| ឈ្មោះរមណីយដ្ឋាន | ទីតាំង | | | ប្រភេទផ្លូវ | ចម្ងាយផ្លូវ | ការគ្រប់គ្រង | ការគាំទ្រថវិកា |
|---|---|---|---|---|---|---|---|
| | ភូមិ | ឃុំ | ស្រុក | | | | |
| **១-រមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ** | | | | | | | |
| -ក្រុមប្រាសាទព្រះវិហារ | ធម្មជាតិ | កន្ទួត | ជាំក្សាន្ត | កៅស៊ូ | ១១០គម | អាជ្ញធរជាតិ | អាជ្ញាធរព្រះវិហារ |
| -ក្រុមប្រាសាទកោះកេរ | ស្រយ៉ង់ | ស្រយ៉ង់ | គូលែន | កៅស៊ូ | ៧០គម | ក្រុមហ៊ុន | អាជ្ញធរអប្សរា |
| -ក្រុមប្រាសាទព្រះខ័ន | តាសែងជើង | រណៈសិរ្ស | សង្គមថ្មី | កៅស៊ូ+ផ្លូវដី | ៨៥គម | ក្រុមការងារ | ស្វែងរក |
| -ក្រុមប្រាសាទខ្នារពណ្ណរាយ | ក្រឡាពាស | ព្រីងធំ | ជាំក្សាន្ត | រទេះ | ២៥ គម | | |
| -ក្រុមប្រាសាទនាគបួស | ឆ្អេះ | ទឹកក្រហម | ជាំក្សាន្ត | កៅស៊ូ+ផ្លូវដី | ១១៥ គម | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| -ក្រុមប្រាសាទខ្នារសែនកែវ | ក្របៅ | ភ្នំពេញ | គូលែន | គ្រួសក្រហម | ៤៥ គម | | |
| -ក្រុមបាសាទព្រះលាន | ក្រាំងដូង | ព្រះឃ្លាំង | ត្បែង | កៅស៊ូ | ២៥ គម | | |
| -ក្រុមប្រាសាទក្រពុំឈូក | ថ្នល់កោង | រំដោះ | រវៀង | កៅស៊ូ | ៤៥ គម | | |
| -ក្រុមប្រាសាទក្តាក់ | ក្តាក់ | ត្បែងពីរ | គូលែន | គ្រួសក្រហម | ៥៥ គម | | |
| | | | | | | | |
| **២-រមណីយដ្ឋានធម្មជាតិ** | | | | | | | |
| -សហគមន៍ទេសចរណ៍ពើងអង្កាម | បាក់កាំ | ឈានមុខ | ត្បែង | កៅស៊ូ+ផ្លូវដី | ១៥គម | សហគមន៍ | |
| -វត្តរអាងថ្មបីដុំ (ខ្នងភ្នំ) | ក្តីលើ | រអាង | សង្គមថ្មី | កៅស៊ូ+ផ្លូវដី | ២៥គម | | |
| -សហគមន៍អភិរក្សសត្វស្លាបត្មាតប៉ើយ | ត្មាតប៉ើយ | ព្រីងធំ | ជាំក្សាន្ត | កៅស៊ូ+ផ្លូវដី | ៤០គម | សហគមន៍ | WCS |
| -តំបន់ការពារអភិរក្សសត្វព្រៃដងផ្លិត | ដងផ្លិត | ឆែបពីរ | ឆែប | ផ្លូវគ្រួស+ដី | ៧៥គម | WCS | WCS |
| -ទឹកធ្លាក់ព្រៃរយោង (ជើងភ្នំត្បែង) | បេងកោង | ព្រះឃ្លាំង | ត្បែង | កៅស៊ូ+ផ្លូវដី | ១១,៥គម | | ស្វែងរក |
| -ទឹកធ្លាក់តេជោបុស្សស្បូវ | តេជោបុស្សស្បូវ | កន្ទួត | ជាំក្សាន្ត | កៅស៊ូ+ផ្លូវដី | ១០០គម | | ស្វែងរក |
| -ទឹកធ្លាក់ព្រះនិម្មិត | កំពង់សីមី | ស្រឡៅពីរ | ឆែប | គ្រួសក្រហម | ១៤០ គម | សហគមន៍ | ស្វែងរក |
| -សហគមន៍ទំនប់ទឹក៩៥ | ទំនប់ | ប៉ាលហាល | ព្រះវិហារ | គ្រួសក្រហម | ៤គម | | ស្វែងរក |
| -រមណីយដ្ឋានវត្តពើងព្រះគោ | មហាផល | ឈានមុខ | ត្បែង | កៅស៊ូ+ផ្លូវដី | ៩គម | គណៈកម្មការវត្ត | ស្វែងរក |

ក្រៅពីនេះ ដោយអនុវត្តតាមយុទ្ធសាស្ត្ររបស់ក្រសួងក្នុងការចូលរួមចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ ខេត្តបានខិតខំលើកកម្ពស់ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងក្រុងព្រះវិហារ ដើម្បីបង្កើននូវការទាក់ទាញភ្ញៀវទេសចរបន្ថែមទៀត ដូចជា ការកសាងសួនច្បារ និងស្តូបគោរពវិញ្ញាណខ័ន្ធ កែលម្អរង្វង់មូល២កន្លែងទៀតគឺរង្វង់មូលនាគព័ន្ធនិងរង្វង់មូលព្រះនរាយណ៍ ការបំពាក់បង្គោលភ្លើងតាមដងផ្លូវការស្ថាបនាផ្លូវក្រាលកៅស៊ូ និង ការកសាងរូបសំណាកលោកតាឪ (បុព្វបុរសខ្មែរអ្នកស្នេហាជាតិ ជាមេទ័ពការពារទឹកដីនៅតំបន់ប្រាសាទព្រះវិហារប្រឆាំងនឹងចោរសៀមឈ្លានពាន) ជាដើម ។

ផ្នែកសេវាកម្មទេសចរណ៍ជាក់ស្តែងនៅក្នុងខេត្តនៅមានកង្វះខាតជាច្រើន អំពីបណ្តុសម្បទាសេវាកម្មសម្រាប់បម្រើដល់តម្រូវការរបស់ភ្ញៀវទេសចរ ជាពិសេសរាល់មូលដ្ឋានសេវាកម្មស្នាក់នៅ ដូចជាសណ្ឋាគារ ផ្ទះសំណាក់មួយចំនួនគុណភាពនៅមានកំរិតពុំទាន់ឆ្លើយតបទៅនិងកំរិតស្តង់ដានិងតម្រូវការសម្រាប់ភ្ញៀវអន្តរជាតិនៅឡើយ ។ បញ្ហានេះជាចំណុចគន្លឹះ ដែលទាមទារដល់ការចូលរួមវិនិយោគពីដៃគូឯកជន ។ សរុបមកអ្វីដែលខេត្តមាន និងកំពុង បម្រើភ្ញៀវសព្វថ្ងៃ ដូចមានក្នុងតារាងខាងក្រោម :

**តារាងស្ថិតិការគ្រប់គ្រងសេវាកម្មទេសចរណ៍ពីឆ្នាំ ២០១០-២០១២**( *ប្រភព : ទិន្នន័យមន្ទីរទេសចរណ៍*)

| មូលដ្ឋានសេវាកម្ម | ២០១០ | | ២០១១ | | ២០១២ | |
|---|---|---|---|---|---|---|
| | កន្លែង | បន្ទប់ | កន្លែង | បន្ទប់ | កន្លែង | បន្ទប់ |
| ១-សណ្ឋាគារ | ១ | ២០ | ១ | ២០ | ១ | ៣៥ |
| ២-ផ្ទះសំណាក់ | ២៣ | ២៤៨ | ២៩ | ៣៦៥ | ៣២ | ៤៤៩ |
| ៣-ម៉ូតែល | ០១ | ០៦ | ០១ | ០៧ | ១ | ១១ |
| ៤-ភោជ.ទេសចរណ៍ | ០៧ | | ១០ | | ១៤ | |
| ៥- អាហារ.ក្នុងស្រុក | ២១ | | ១៤ | | ៣០ | |
| ៦-ខារ៉ាអូខេ | ០៤ | | ១០ | | ១៧ | |

| | | | | | | |
|---|---|---|---|---|---|---|
| ៧-បៀហ្គាឌិន | ០១ | | ០ | | ១ | |
| ៨-ម៉ាស្សាស្សា | | | ០ | | ១ | |

បញ្ហាប្រឈមមួយចំនួនទាក់ទងទៅនឹងវិស័យទេសចរណ៍រួមមាន :

- ផលិតផលទេសចរណ៍ទាំងមានស្រាប់ និងកែឆ្នៃ (វប្បធម៌ធម្មជាតិ) ទាំងរូបិយនិងអរូបិយមិនទាន់អភិវឌ្ឍន៍ឱ្យអស់លទ្ធភាពសម្រាប់បម្រើតម្រូវការភ្ញៀវទេសចរជាតិ និងអន្តរជាតិនៅឡើយ ដោយសារខ្វះមធ្យោបាយ និងដៃគូសម្រាប់អភិវឌ្ឍន៍។
- សម្បទាសេវាកម្មទេសចរណ៍ដែលមាន នៅមិនទាន់ឆ្លើយតបនិងតម្រូវការភ្ញៀវទេសចរនៅឡើយ ពិសេសគឺទេសចរណ៍អន្តរជាតិ ដោយសារគុណភាពផលិតផល សេវាកម្មទេសចរណ៍ ការយល់ដឹងអំពីទេសចរណ៍នៅមានកំរិត ពិសេសការវិនិយោគលើផ្នែកនេះក៏នៅមានកំរិតតិចតួចផងដែរ។
- ទេសចរប្រមាណជាង ៧០ ភាគរយ ជាទេសចរវិលល្ងាច មូលហេតុសំខាន់គឺមិនទាន់មានសាខាឬក្រុមហ៊ុនទីភ្នាក់ងារទេសចរណ៍សម្រាប់នាំភ្ញៀវ។
- នៅខ្វះលិខិតបទដ្ឋានក្រោមច្បាប់មួយចំនួនទៀតសម្រាប់គ្រប់គ្រងឧស្សាហកម្មទេសចរណ៍។
- ខ្វះធនធានមនុស្សសម្រាប់បំពេញការងារ ព្រោះក្របខ័ណ្ឌថ្មីមិនមានរើសចូល។
- បុគ្គលិកបម្រើការងារនៅតាមសេវាកម្មដែលបានបណ្តុះបណ្តាល ហើយភាគច្រើនបានចល័តកន្លែងធ្វើការដោយរត់តាមប្រាក់កំរៃ ។
- ម្ចាស់ ឬ អ្នកគ្រប់គ្រង ទាំងសេវាកម្មស្នាក់នៅ និងភោជនីយដ្ឋាន អាហារដ្ឋាន ភាគច្រើន បម្រើការងារដោយខ្លួនឯង (ជាអ្នកគ្រប់គ្រង ទទួលភ្ញៀវ រៀបចំបន្ទប់ ចំអិនអាហារ ធ្វើអនាម័យ បោកគក់ រត់តុ លើកម្ហូប។ល ។ មូលហេតុចំណូល មិនបំពេញចំណាយលើប្រាក់កម្រៃបុគ្គលិក។
- ការរៀចំសហគមន៍ទេសចណ៍មូលដ្ឋាន នៅមិនទាន់មានលិខិតបទដ្ឋានណែនាំឱ្យបានច្បាស់លាស់។
- ការរៀបចំរមណីយដ្ឋានទេសចរណ៍គំរូតាមបទដ្ឋានដែលក្រសួងបានកំណត់នៅមិនទាន់ធ្វើបាននៅឡើយ។
- មគ្គុទេសក៏ទេសចរណ៍មិនទាន់បានបណ្តុះបណ្តាលបន្ថែម ដើម្បីឆ្លើយតបតាមតម្រូវការភ្ញៀវ។

ដើម្បីសម្រេចបានគោលដៅ និងផ្អែកលើមូលដ្ឋានខាងលើសម្រាប់ឆ្នាំ ២០១៣ ខាងមុខនេះ មន្ទីរទេស-ចរណ៍រំពឹងថា ភ្ញៀវទេសចរនឹងមានកំណើនប្រមាណ ២៥០.០០០នាក់ ចូលមកទស្សនាខេត្តព្រះវិហារ ។ ដូចនេះដើម្បីឆ្លើយតបទៅនិងកំណើននេះ មន្ទីរមានផែនការអភិវឌ្ឍន៍លើចំណុចសំខាន់ៗ ដូចខាងក្រោម :

-រៀបចំអភិវឌ្ឍន៍រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋានធម្មជាតិ សហគមន៍ទេសចរណ៍មូលដ្ឋាន តំបន់ទស្សនាសត្វស្លាប សហការជាមួយស្ថាប័នពាក់ព័ន្ធបង្កើននូវព្រឹត្តិការណ៍ផ្សេងៗប្រចាំខេត្ត និងការជម្រុញផលិតវត្ថុអនុស្សាវរីយសម្រាប់បម្រើឱ្យភ្ញៀវទេសចរ។

-បន្តខិតខំពង្រឹងគុណភាពផលិតផលទេសចរណ៍ គុណភាពសេវាកម្ម ឱ្យធានាបាននូវគុណភាពប្រសិទ្ធភាពស្របតាមស្តង់ដាដែលបានកំណត់ ពិសេសបន្តជម្រុញសកម្មភាពចលនាប្រឡងប្រណាំង **ទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ** ឱ្យកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាព។

-បន្តសហការជាមួយដៃគូពាក់ព័ន្ធ ដើម្បីចងក្រងផលិតឯកសារសម្រាប់ផ្សព្វផ្សាយពីផលិតផលទេសចរណ៍នៅក្នុងខេត្តឱ្យបានកាន់តែទូលំទូលាយ ដោយធានាបាននូវព័ត៌មានជាក់លាក់ត្រឹមត្រូវ ក្នុងគោលដៅចូលរួមផ្សព្វផ្សាយ **កម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ ។**

-សហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីលើកគម្រោងកសាងផ្លូវលំចូលទៅកាន់រមណីយដ្ឋានវប្បធម៌ និង ធម្មជាតិសំខាន់ៗមួយចំនួនទៀតនៅក្នុងខេត្ត ។

-បង្កើតខ្សែទស្សនៈកិច្ចជាមួយប្រទេសជិតខាង ពិសេសជាមួយខេត្តចំប៉ាសាក់នៃប្រទេសឡាវ បើកខ្សែទស្សនាបេតិកភ័ណ្ឌវប្បធម៌ពីប្រាសាទវត្តភូមកប្រាសាទព្រះវិហារ ប្រាសាទកោះកេរ ប្រាសាទព្រះខ័នកំពង់-ស្វាយ និងតំបន់សៀមរាបអង្គរ ស្របតាមគោលការណ៍របស់ក្រសួងទេសចរណ៍ ។

-បើកវគ្គផ្សព្វផ្សាយនូវគោលនយោបាយ ប្រកាស និងផ្សព្វផ្សាយសេចក្តីណែនាំនានារបស់ក្រសួងទេសចរណ៍ដល់មូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ និងផ្នែកពាក់ព័ន្ធស្តីពីការគ្រប់គ្រង និង អភិវឌ្ឍន៍វិស័យទេសចរណ៍នៅក្នុងខេត្ត ក្រោមយន្តការគណៈកម្មការគ្រប់គ្រងអភិវឌ្ឍន៍ទេសចរណ៍ខេត្ត ។

-ចុះអប់រំផ្សព្វផ្សាយដល់មូលដ្ឋាន និងនៅតាមតំបន់ទេសចរណ៍ស្តីពីពង្រឹងការយល់ដឹងនិងវិធានការទប់ស្កាត់នៃការជួញដូរ កេងប្រវ័ញ្ចផ្លូវភេទលើកុមារ និង ស្ត្រីក្នុងវិស័យទេសចរណ៍ ។

-បើកវគ្គបណ្តុះបណ្តាលភាសារអង់គ្លេសដើម្បីបង្កើនសមត្ថភាពយល់ដឹងដល់មន្ត្រីរាជការក្នុងអង្គភាព

-ផ្សព្វផ្សាយច្បាប់ស្តីពីការទប់ស្កាត់អំពើជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ក្នុងវិស័យទេសចរណ៍ ។

-បន្តផ្សព្វផ្សាយច្បាប់ស្តីពីទេសចរណ៍ នៅតាមទីប្រជុំជន និងតាមបណ្តាស្រុក ក្រុង ។

### ១.២.១.៥ វិស័យសាធារណការ និងដឹកជញ្ជូន

ខេត្តព្រះវិហារមានភូមិសាស្ត្រជាប់នឹងប្រទេសថៃ និងប្រទេសឡាវ មានចម្ងាយផ្លូវ ២៩៨ គម ពីរាជធានីភ្នំពេញ និងមានផ្លូវគមនាគមន៍សំខាន់ៗជាច្រើន ដែលតភ្ជាប់ពីទីក្រុងទៅជនបទ ហើយបា នធ្វើឱ្យវិស័យដឹកជញ្ជូនផ្លូវគោកមានលទ្ធភាពច្រើនសម្រាប់ការផ្លាស់ប្តូរផលិតផលកសិផលរបស់ប្រជាពលរដ្ឋ បានមកដល់គោលដៅ ។

លទ្ធផលដែលសម្រេចបានទាំងនេះអាស្រ័យដោយរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ផ្តល់ថវិកាជារៀងរាល់ឆ្នាំ និងជាបន្តបន្ទាប់ដូចនេះបណ្តាញហេដ្ឋារចនាសម្ព័ន្ធដែលបាន និងកំពុងធ្វើការសាងសង់គិតទាំងផ្លូវជាតិ និងផ្លូវខេត្តរួមមាន ផ្លូវជាតិលេខ ៦២ សំរាប់ភ្ជាប់ពីព្រំប្រទល់ខេត្តកំពង់ធំដល់ជើងភ្នំប្រាសាទព្រះវិហារ មានប្រវែង ២០ ២ គម សម្រេចបាន ១០០ % ។ ផ្លូវជាតិលេខ ៦៤ ពីឃុំថ្មីស្រុកគូលែនដល់ព្រំប្រទល់ស្រុកស្វាយលើខេត្តសៀមរាប មានប្រវែង ៥១គម ដោយចាក់កៅស៊ូប្រវែង ៣៤ ,១៥គម សម្រេចបាន ១០០ % ។ផ្លូវខេត្តលេខ ៦២-៧ ពីភូមិស្រអែមដល់អូរតាខៀវ ព្រំប្រទល់ស្រុកត្រពាំងប្រាសាទខេត្តឧត្តមានជ័យប្រវែង១៦ ,៦ គម កៅស៊ូ១០០ % ។ ផ្លូវខេត្តលេខ ២៦២៤ ពីភូមិភ្នំដែក ឃុំរមណីយ ស្រុករវៀងដល់ស្ពង់ខេត្តស្ទឹងត្រែង ប្រវែង ៧៨ គម ចាក់កៅស៊ូបាន ៣៧,៥ គម ។ ផ្លូវជាតិលេខ ៩ ពីទីរួមខេត្តព្រះវិហារដល់ព្រំប្រទល់ខេត្តស្ទឹងត្រែងប្រវែង ៦៩ ,៨គម បាននឹងកំពុងធ្វើការសាងសង់ថ្មីជាផ្លូវកៅស៊ូ ដោយក្រុមហ៊ុនសៀងហៃគ្រុប ។ ផ្លូវខេត្តលេខ ២៦៤៦ ប្រវែង ៤០ គម

ពីទីរួមស្រុកឆែបដល់ភូមិពុទ្រា ក្នុងនោះក្រាលកៅស៊ូប្រភេទ DBST ប្រវែង ៥ គម សម្រេចបាន ១០០ %។ ដោយឡែកផ្លូវជាច្រើនខ្សែទៀតនៅតាមបណ្តោយព្រំដែនប្រទេសថៃ និងប្រទេសឡាវសុទ្ធតែបានកសាងរួចរាល់ និងបន្តធ្វើការសាងសង់ជាបន្តបន្ទាប់ដែលជាប្រភេទផ្លូវក្រាលគ្រួសក្រហម និងជាផ្លូវយុទ្ធសាស្ត្រសម្រាប់ការពារបូរណភាពដែនដី ដែលសាងសង់ដោយកងវិស្វកម្ម។

ទន្ទឹមនឹងសមិទ្ធិផល ដែលសម្រេចបានខាងលើមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តបានលើកផែនការយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍន៍សម្រាប់៣ឆ្នាំរំកិល និងផែនការរយៈពេលវែង ៥ឆ្នាំ សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងការងារថែទាំលើផ្លូវ ដែលមានស្រាប់ និងសាងសង់ថ្មីទៀត ឱ្យសមស្របតាមកំណើនសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋ ព្រោះផ្លូវថ្នល់ ស្ពានជាសរសៃឈាមរបស់ប្រទេសជាតិសម្រាប់ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ការអនុវត្តការងារកន្លងមក ក្នុងការសាងសង់ផ្លូវ ស្ពាន មន្ទីរសាធារណការខេត្តមានបញ្ហាប្រឈមដូចខាងក្រោម ៖

- មានផលប៉ះពាល់ផ្នែកបរិស្ថាន និងផលប៉ះពាល់ជាមួយខ័ណ្ឌរដ្ឋបាលព្រៃឈើ
- ទីតាំងយកថ្ម និងគ្រួសក្រហមត្រូវបានប្រជាពលរដ្ឋរំលោភកាន់កាប់
- តម្លៃសម្ភារៈសំណង់ និងប្រេងឥន្ធនៈមានការប្រែប្រួលមិនទៀងទាត់
- ការធ្វើចរាចរឯកសារ មានការយឺតយ៉ាវ ហើយនៅពេលបានថវិកាពុំសមស្របតាមពេលវេលា
- ប្រជាពលរដ្ឋពុំទាន់យល់ច្បាស់អំពីការប្រើប្រាស់ដីចំណីផ្លូវ
- មន្ត្រីរាជការមួយចំនួន និងប្រជាពលរដ្ឋពុំបានចូលរួមក្នុងការកែលម្អប្រព័ន្ធលូបង្ហូរទឹកតាមសងខាងផ្លូវ
- ប្រជាពលរដ្ឋមួយចំនួន មិនគោរពស្លាកសញ្ញាការដ្ឋាន និងស្លាកសញ្ញាចរាចរណ៍
- រថយន្តមួយចំនួនធ្វើការដឹកជញ្ជូនលើសទម្ងន់កំរិតកំណត់
- ប្រជាពលរដ្ឋស្នើសុំសាងសង់ប្រព័ន្ធលូ ដោយប្រើប្រាស់លូពុំត្រូវតាមលក្ខណៈ បច្ចេកទេសរបស់មន្ទីរ
- បច្ចុប្បន្នការប្រើប្រាស់យានយន្តនៅក្នុងខេត្តពុំបានធ្វើការត្រួតពិនិត្យលក្ខណៈបច្ចេកទេសដោយម៉ាស៊ីនឡើយ។

## ១.២.១.៦ វិស័យប្រៃសណីយ៍ និង ទូរគមនាគមន៍

ផ្តើមចេញពីគោលនយោបាយយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលតំណាក់កាលទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១១-២០១៥។ មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍បានលើកគម្រោងផែនការ និងសកម្មភាពការងារសំដៅរៀបចំប្រព័ន្ធប្រៃសណីយ៍និងទូរគមនាគមន៍មួយស្របតាមបណ្តាខេត្តឱ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ សេវាកម្មទំនើប និងគ្របដណ្តប់ទូទាំងខេត្តដោយមានប្រព័ន្ធត្រួតពិនិត្យគុណភាពដើម្បីចូលរួមជម្រុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរបស់ប្រជាជនកាត់បន្ថយភាពក្រីក្រ។ ពង្រីកសេវាប្រៃសណីយ៍នៅតំបន់ជនបទ បង្កលក្ខណៈឱ្យប្រជាជនបានទទួលព័ត៌មាន និងបញ្ជូនព័ត៌មានក្នុងការទំនាក់ទំនងបានឆាប់រហ័ស។ បង្កើនសហប្រតិបត្តិការល្អជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីសម្រេចនូវកម្មវិធីទំនើបកម្មក្នុងវិស័យនេះ។ យកចិត្តទុកដាក់ជម្រុញការបណ្តុះបណ្តាលធនធានមនុស្ស។

ប្រៃសណីយ៍ និងទូរគមនាគមន៍ ជាវិស័យមួយដែលបម្រើឱ្យសកម្មភាពសង្គមលើគ្រប់វិស័យ ដើម្បីកាត់បន្ថយការចំណាយពេលវេលា និងថវិកាដែលមិនអាចខ្វះបានឡើយ ហើយវិស័យនេះចែកចេញជាពីរគឺប្រៃសណីយ៍ និងទូរគមនាគមន៍។

ប្រៃសណីយ៍មានភារកិច្ចក្នុងការបម្រើសេវាកម្ម អាជីវកម្មសម្រាប់បម្រើឱ្យផលប្រយោជន៍សង្គមជាតិទាំងមូលដូចជាការបញ្ជូន និងទទួលលិខិតគ្រប់ប្រភេទ បញ្ញើឆាប់រហ័ស អាណត្តិប្រៃសណីយ៍(ផ្ញើប្រាក់)កញ្ចប់គ្រប់ប្រភេទនៅក្នុងនិងក្រៅប្រទេស និងបញ្ជូននិងទទួលបញ្ញើគ្រប់ប្រភេទទៅតាមបណ្តាស្រុក និងមូលដ្ឋានជនបទទូទាំងខេត្ត។

ទូរគមនាគមន៍ជាវិស័យមួយបម្រើសេវាកម្ម អាជីវកម្មនៅផ្ទៃប្រទេស និងនៅទូទាំងពិភពលោក។ ដោយឡែកនៅទូទាំងខេត្តព្រះវិហារ បច្ចុប្បន្នទូរគមនាគមន៍មានបណ្តាញសេវាគ្របដណ្តប់ទូទាំងខេត្តដែលមានក្រុមហ៊ុនទូរស័ព្ទចល័ត ក្រុមហ៊ុនទូរស័ព្ទអចល័ត និង អ៊ីនធឺណេត ហើយក្រុមហ៊ុននីមួយៗ មានស្ថានីយ៍នៅគ្រប់ ក្រុង ស្រុក និង ទីប្រជុំជន ដូចមានក្នុងតារាងស្ថិតិស្ថានីយ៍ទូរស័ព្ទភ្ជាប់ខាងក្រោម:

**តារាង: ស្ថិតិស្ថានីយ៍ទូរស័ព្ទតាមបណ្តាក្រុង-ស្រុក**

| ឈ្មោះ ក្រុមហ៊ុន | ក្រុង ព្រះវិហារ | ស្រុកត្បែង មានជ័យ | ស្រុក រវៀង | ស្រុក ជ័យសែន | ស្រុក ឆែប | ស្រុក ជាំក្សាន្ត | ស្រុក គូលែន | ស្រុក សង្គមថ្មី | សរុបរួម |
|---|---|---|---|---|---|---|---|---|---|
| Mobitel | ០៨ | ០៣ | ១៥ | ០៥ | ០៤ | ១០ | ០៧ | ០៤ | **៥៦** |
| veittel | ០៧ | ០៥ | ១៧ | ០៤ | ០៥ | ០៩ | ០៦ | ០៤ | **៥៧** |
| HELLO | ០២ | ០១ | ០៤ | ០ | ០ | ០២ | ០៣ | ០ | **១២** |
| SOTEL | ០៣ | ០២ | ០៨ | ០១ | ០១ | ០៣ | ០៣ | ០ | **២១** |
| MFONE | ០៤ | ០១ | ០៤ | ០២ | ០២ | ០២ | ០៣ | ០២ | **២០** |
| SMART | ០១ | ០ | ០២ | ០ | ០ | ០២ | ០៣ | ០ | **០៨** |
| TELECOM | ០១ | | | | | | | | **០១** |
| CAMINTEL | ០១ | | | | | | | | **០១** |
| **សរុប** | **២៧** | **១២** | **៥០** | **១២** | **១២** | **២៨** | **២៥** | **១០** | **១៧៦** |
| អ៊ីនធឺណេត | ៥៣ | | | | | | | | **៥៣** |
| FM ៩៩ | | | | | | ០១ | | | **០១** |
| FM ៩៥ | | | | | | ០១ | | | **០១** |
| ទូរទស្សបាយ័ន | | | | | | ០១ | | | **០១** |
| វិទ្យុ ICOM | ០៦ | ០១ | ០១ | ០២ | ០២ | ០១ | ០១ | ០១ | **១៥** |

*( ប្រភព : ទិន្នន័យមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ )*

លើសពីនេះ ខេត្តក៏មានបណ្តាញកាប្លិអុបទិចកប់ដី និងកាប្លីអាកាសរាយតាមបណ្តាញផ្លូវជាតិ និងទីប្រជុំជនមួយចំនួននៅទូទាំងខេត្ត និងការគ្រប់គ្រងរលកអាកាសវិទ្យុ និងអាជ្ញាប័ណ្ណ។

តាមស្ថានភាពជាក់ស្តែងនៃវិស័យប្រៃសណីយ៍និងទូរគមនាគមន៍ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា:

- គ្មានមន្ត្រីបម្រើការងារ និងទីតាំងការិយាល័យបម្រើការងារនៅថ្នាក់ក្រុង ស្រុក ។
- ការបញ្ជូន និង ទទួលលិខិតគ្រប់ប្រភេទមានការយឺតយ៉ាវដោយមូលហេតុខ្វះមន្ត្រី និងមធ្យោបាយ ។
- សមត្ថភាពមន្ត្រីបម្រើការជំនាញបច្ចេកទេសនៅមានកំរិត ខ្វះបុគ្គលិក ម្យ៉ាងទៀតមន្ត្រីជំនាញមួយចំនួនបានចូលនិវត្តន៍ជាបន្តបន្ទាប់ ។
- ស្ថានីយ៍មួយចំនួន កំពុងប្រើប្រាស់បរិក្ខារវិទ្យុគមនាគមន៍ដោយគ្មានអាជ្ញាប័ណ្ណ ។
- នៅមិនទាន់គ្រប់គ្រងបានលើក្រុមហ៊ុនទូរស័ព្ទមួយចំនួនដែលបានតម្លើងស្ថានីយ៍ក្នុងខេត្ត ។
- ភាពអាណាធិបតេយ្យនៃការទទួលបញ្ញើក្នុងស្រុកគ្រប់ប្រភេទរបស់រថយន្តតាក់ស៊ី និងរថយន្តក្រុង ។
- ក្រុមហ៊ុនទូរស័ព្ទចល័តមួយចំនួនតម្លើងបង្គោលអង់តែនដោយពុំមានការអនុញ្ញាតិគ្រប់គ្រាន់ពីមន្ទីរជំនាញខេត្ត ។
- អតិថិជនមួយចំនួនបានប្រើប្រាស់បរិក្ខាវិទ្យុគមនាគមន៍ដោយគ្មានការអនុញ្ញាតិពីមន្ទីរប្រៃសណីយ៍ខេត្ត ។
- ការប្រមូលពន្ធអាជ្ញាប័ណ្ណវិទ្យុទាក់ទងមានការធ្លាក់ចុះ ( អតិថិជនឈប់ប្រើប្រាស់ ) ។

## ១.២.១.៧ វិស័យពាណិជ្ជកម្ម

មន្ទីរពាណិជ្ជកម្មមានមន្ត្រីក្របខ័ណ្ឌចំនួន ១២នាក់ ស្រី ៤នាក់ មានមន្ត្រីចំនួន ៨នាក់ ( ស្រី៣នាក់) ក្នុងមន្ទីរ និងតាមបណ្តាស្រុកមានមន្ត្រីចំនួន៤នាក់ (ស្រី១នាក់) ។មន្ទីរមាន ៣ការិយាល័យ: ១-ការិយាល័យរដ្ឋបាលហិរញ្ញវត្ថុមាន៤ផ្នែក ២-ការិយាល័យគ្រប់គ្រងអាជីវកម្មមាន៥ផ្នែក និង៣-ការិយាល័យជម្រុញ ពាណិជ្ជកម្មមាន៥ផ្នែក ។

មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត គឺជាអង្គភាពរដ្ឋបាលសេដ្ឋកិច្ចតំណាងឱ្យក្រសួងពាណិជ្ជកម្ម ទទួលអនុវត្តគ្រប់គ្រងវិស័យពាណិជ្ជកម្មនៅមូលដ្ឋាន និងសម្របសម្រួលសកម្មភាពរបស់ក្រសួង និងមានមុខងារ ភារកិច្ចដូចតទៅ:

- អនុវត្តការងារគ្រប់គ្រងអាជីវកម្ម តម្លៃ និងគោលនយោបាយប្រកួតប្រជែង
- អនុវត្តការងារជម្រុញ និងអភិវឌ្ឍន៏ពាណិជ្ជកម្ម
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មប្រគល់ជូន ។

ខេត្តព្រះវិហារមានផ្សារសំខាន់ៗចំនួន ៩កន្លែង គឺផ្សារ កំពង់ប្រណាក ស្ថិតនៅ ក្នុងក្រុងព្រះវិហារ និងផ្សារតូចៗ៨កន្លែងទៀតគឺ ១កន្លែងនៅទីរួមស្រុករវៀង ២កន្លែងនៅស្រុកជាំក្សាន្ត ២កន្លែងនៅស្រុកគូលែន ១កន្លែងនៅស្រុកឆែប ១កន្លែងនៅស្រុកសង្គមថ្មី និង១កន្លែងនៅស្រុកជ័យសែន ។ ប៉ុន្តែក្នុងចំណោមផ្សារតូចៗ ទាំងនេះមានផ្សារ៤ គឺផ្សារឆែប ជ័យសែន រវៀង និងសង្គមថ្មី ដែលមិនទាន់មានទីតាំងលក់ដូរត្រឹមត្រូវនៅឡើយគឺអាជីវករលក់ដូរនៅតាមផ្ទះតាមបណ្តោយដងផ្លូវ ។

**បញ្ហាប្រឈម និងមូលហេតុនៃបញ្ហា :** ផលិតផលក្នុងស្រុកមួយចំនួនមិនអាចជ្រៀតចូលទីផ្សារបាន ឬមិនអាចប្រកួតប្រជែងក្នុងទីផ្សារ និងពុំទាន់មានទីផ្សារត្រឹមត្រូវ ។ តម្លៃផលិតផលឡើងចុះមិនទៀងទាត់តាមឈ្មួញជាអ្នកកំណត់ ។ ម្យ៉ាងទៀត ផលិតផលពុំទាន់មានការកែច្នៃ និងវិចខ្ចប់ត្រឹមត្រូវតាមស្តង់ដាបច្ចេកទេសនៅឡើយ ។

ដើម្បីដោះស្រាយបញ្ហានេះ មន្ទីរត្រូវអនុវត្តសកម្មភាពចម្បងៗមួយចំនួនដូចជាៈ បន្តសាងសង់អាគាររដ្ឋបាលមន្ទីរពាណិជ្ជកម្ម ផ្សព្វផ្សាយព័ត៌មានទីផ្សារ សាងសង់មណ្ឌលពិព័រណ៍សម្រាប់ដាក់តាំងផលិតផល លើកកម្ពស់ការផ្តល់សេវាកម្ម និងបណ្តុះបណ្តាលធនធានមនុស្ស រៀបចំកម្មវិធីតាំងពិព័រណ៍ផលិតផលពាណិជ្ជកម្មខេត្ត បណ្តុះបណ្តាលពង្រឹងសមត្ថភាពមន្ត្រីបច្ចេកទេសថ្នាក់ខេត្ត ថ្នាក់ស្រុក ភ្នាក់ងារ ផ្សព្វផ្សាយផលិតផល និងព័ត៌មានទីផ្សារ ជម្រុញផលិតផលនាំចេញ កែលម្អធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ ចំណូលរបស់ប្រជាពលរដ្ឋឱ្យកាន់តែមានភាពប្រសើរឡើង។ ពង្រីកសកម្មភាពទីផ្សារព័ត៌មានទីផ្សារ និងបង្កើនបរិមាណ គុណភាពផលិតផលកសិកម្ម សិប្បកម្ម ដើម្បីប្រកួតប្រជែងក្នុងទីផ្សារ។

### ១.២.១.៨ វិស័យឧស្សាហកម្ម រ៉ែ និង ថាមពល

#### ក.វិស័យឧស្សាហកម្ម

ខេត្តព្រះវិហារនាពេលបច្ចុប្បន្នមានសហគ្រាសផលិតទឹកបរិសុទ្ធ ០៣កន្លែង សិប្បកម្មផលិតទឹកកក០៥កន្លែង និងសិប្បកម្មផ្សេងទៀតដែលមានដើមទុនលើសពីប្រាំពាន់ដុល្លារមានចំនួន ១៧ កន្លែង។ ក្រៅពីនោះមានសិប្បកម្មតូចៗ ដែលមានដើមទុនក្រោមបីពាន់ដុល្លារ មានប្រមាណ ៨,០០០ កន្លែងនៅទូទាំងខេត្ត។ ចំពោះឧស្សាហកម្មធុនធំ ដូចជា វិស័យកាត់ដេរ កែច្នៃកសិផលកសិ-ឧស្សាហកម្មពុំទាន់មាននៅឡើយ ដោយសារខេត្តមានចំនួនប្រជាជនកំពុងរស់នៅមានតិច និងមានជីវភាពខ្វះខាត។ វិស័យឧស្សាហកម្មមានការរីកចំរើនតិចតួចបើធៀបទៅបណ្តាខេត្តផ្សេងៗទៀត។ បច្ចុប្បន្នមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកំពុងយកចិត្តទុកដាក់ពង្រីក និងគ្រប់គ្រងឱ្យបានល្អនូវមូលដ្ឋានសិប្បកម្ម អាជីវកម្មនៅក្នុងខេត្ត ដើម្បីគាំទ្រដល់ការកែឆ្នៃកសិផលសម្រាប់តម្រូវការក្នុងមូលដ្ឋាន និងការនាំចេញ។ ការចូលរួមរបស់វិស័យឯកជនក្នុងការចូលមកបណ្តាក់ទុនវិនិយោគលើវិស័យនេះគឺជាចំណុចគន្លឹះសម្រាប់ការអភិវឌ្ឍវិស័យឧស្សាហកម្មនាពេលអនាគត។

#### ខ.វិស័យធនធានរ៉ែ

វិស័យរ៉ែនៅខេត្តព្រះវិហារ គឺជាផ្នែកមួយនៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម និងជាប្រភពវត្ថុធាតុដើមមួយដ៏សំខាន់ដើម្បីទ្រទ្រង់ដល់ឧស្សាហកម្មដែលប្រើប្រាស់វត្ថុធាតុដើមរ៉ែ។ រាជរដ្ឋាភិបាលតែងតែបានចាត់ទុកផ្នែកឯកជនជាដៃគូមួយដ៏ល្អក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមផ្សេងៗ ដែលក្នុងនោះមានការវិនិយោគលើវិស័យធនធានរ៉ែផងដែរ។ នៅក្នុងរយៈពេលកន្លងមកនេះក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលបានផ្តល់អាជ្ញាប័ណ្ណស្វែងរុករកជូនដល់ក្រុមហ៊ុនរ៉ែ ដើម្បីសិក្សាស្រាវជ្រាវរ៉ែមាស និងរ៉ែដែកនៅក្នុងខេត្តព្រះវិហារ ដែលមានចំនួន ២៥ តំបន់សម្បទាន។ អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មរ៉ែដែក ០១ ស្ថិតនៅក្នុងស្រុករវៀង ខេត្តព្រះវិហារ និងអាជ្ញាប័ណ្ណអណ្តូងរ៉ែបើក និងការដ្ឋានវាយថ្មមានចំនួន ០៣កន្លែង។

បញ្ហាប្រឈមដែលខេត្តកំពុងជួបប្រទះ គឺកង្វះខាតធនធានមនុស្សលើវិស័យរ៉ែ ដើម្បីគ្រប់គ្រង និង ត្រួតពិនិត្យសកម្មភាពសិក្សាស្រាវជ្រាវរបស់ក្រុមហ៊ុន។ ម្យ៉ាងទៀត ពុំមានកំលាំងពលកម្មគ្រប់គ្រាន់ សម្រាប់បំពេញតម្រូវការរបស់រោងចក្ររ៉ែដែកនៅពេលអនាគត។ បញ្ហាប្រឈមខ្លាំងជាងគេ គឺកង្វះខាតថាមពលអគ្គិសនី សម្រាប់ផ្គត់ផ្គង់ជូនរោងចក្រ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។ ដូច្នេះជាចក្ខុវិស័យរបស់រាជរដ្ឋាភិបាលក៏ដូចជា ខេត្តព្រះវិហារ គឺការជម្រុញទាក់ទាញអ្នកវិយោគទុនបរទេសធំៗ ដើម្បីផលិតថាមពលអគ្គិសនីនៅក្នុងខេត្តសម្រាប់បំពេញតម្រូវការថាមពមរបស់ក្រុមហ៊ុនរ៉ែនៅពេលអនាគត។

#### គ.វិស័យថាមពល

វិស័យថាមពលជាវិស័យមួយសំខាន់សម្រាប់អភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ។ បច្ចុប្បន្នថាមពលអគ្គិសនីនៅក្នុងខេត្តនៅមានកំរិត សេវាអគ្គិសនីមានតំលៃខ្ពស់ ជាហេតុប៉ះពាល់ដល់ការអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ ក្រុមហ៊ុនឯកជនបានចូលមកផលិតថាមពលអគ្គិសនីនៅទីរួមខេត្ត ១កន្លែង និងនៅទីរួមស្រុកចំនួន ១នោះមាន ១កន្លែង ក្នុងស្រុករវៀង ស្រុកជាំក្សាន្ត ស្រុកគូលែន និងស្រុកសង្គមថ្មី ដែលមានអានុភាពប្រមាណជា ២ មេហ្គាវ៉ាត់។ ដោយពិនិត្យឃើញស្ថានភាពខ្វះខាតថាមពលអគ្គិសនី រាជរដ្ឋាភិបាលកម្ពុជាបានចុះអនុស្សរណៈយោគយល់ (MOU) ជាមួយរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតឡាវ ដើម្បីផ្គត់ផ្គង់អគ្គិសនីពីខេត្តចំប៉ាសាក់មកកំពង់ស្រឡៅ ស្រុកឆែប ដែលមានអនុភាព០២មេហ្គាវ៉ាត់ ហើយបានចែកចាយជូនប្រជាពលរដ្ឋប្រើប្រាស់តាំងពីដើមខែមេសា ឆ្នាំ២០១២។ បច្ចុប្បន្ន អគ្គិសនីកម្ពុជា បានកំពុងសិក្សាការភ្ជាប់បណ្តាញអគ្គិសនីពីកំពង់ស្រឡៅ មកទីរួមខេត្តព្រះវិហារដែលអាចមានអានុភាពរហូតដល់ ៧ មេហ្គាវ៉ាត់បន្ថែមទៀត ហើយគម្រោងនេះនឹងអាចបញ្ចប់ នឹងដាក់ឱ្យប្រើប្រាស់នៅចុងឆ្នាំ២០១៣ ឬដើមឆ្នាំ២០១៤។ ជាចក្ខុវិស័យរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល គឺបង្កើនការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់ទីប្រជុំជន និងជនបទ ដែលមានតម្លៃសមស្របទៅតាមជីវភាពរស់នៅបច្ចុប្បន្ន និងជម្រុញឱ្យមានការចូលរួមវិនិយោគពីផ្នែកឯកជនក្នុងវិស័យថាមពល រួមមាន ការផលិត ការបញ្ជូន និងការចែកចាយជាដើម។

### ១.២.១.៩ វិស័យអភិវឌ្ឍន៍ជនបទ

### ក. ការងារផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ

ទឹកស្អាតជាតម្រូវការចាំបាច់បំផុត សម្រាប់ប្រជាពលរដ្ឋនៅតាមជនបទក្នុងខេត្តព្រះវិហារ។ ជាទូទៅ ក្នុងរដូវប្រាំងប្រជាពលរដ្ឋតែងប្រឈមនឹងការខ្វះខាតទឹកយ៉ាងខ្លាំង ដោយត្រូវចំណាយពេលយ៉ាង ច្រើនក្នុងការស្វែងរកទឹក សម្រាប់ប្រើប្រាស់ និងបរិភោគ ហើយនេះគឺជាបន្ទុកយ៉ាងធ្ងន់ធ្ងរសម្រាប់ស្ត្រី និងកុមារ ដែលជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សុខភាពរបស់ស្ត្រី និងការរៀនសូត្ររបស់កុមារ។ យោងតាមទិន្នន័យដែលប្រមូលបានពីថ្នាក់ភូមិ និងឃុំ បង្ហាញឱ្យឃើញថាចំនួនគ្រួសារ មានប្រភពទឹកប្រើប្រាស់ជិតជាង១៥០ម៉ែត្រពីផ្ទះមានចំនួន ៥៩,៩៨% រីឯចំនួនគ្រួសារដែលមានប្រភពទឹកឆ្ងាយជាង១៥០ម៉ែត្រពីផ្ទះ មានចំនួន ២៣,៩២%។ ក្រៅពីនោះ គឺប្រើប្រាស់ទឹកពីប្រភពផ្សេងៗទៀត ដូចជា ស្ទឹង អូរ ជាដើម មានចំនួន ១២,៦៩%។ ចំណែកឯចំនួនគ្រួសារ គ្មានបង្គន់អនាម័យប្រើប្រាស់មានចំនួនរហូតដល់ ៨១,៤២%។ ការផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទមានបញ្ហាប្រឈមមួយចំនួនដូចជា:

**ផ្នែកទឹកស្អាត:**

-ការផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋនៅខ្វះខាត

-ការចូលរួមថែរក្សាសមិទ្ធិផល នៅមានកម្រិត

-នៅតំបន់ដាច់ស្រយ៉ាលនៅតែខ្វះខាតទឹក ព្រោះគ្រឿងចក្រចូលមិនដល់

-តំបន់មួយចំនួន ខួងអណ្តូងមិនចេញទឹក ដោយសារ គ្មានប្រភពទឹកក្រោមដី និងប៉ះស្រទាប់ថ្មរឹង

**ផ្នែកអនាម័យ:**

-ប្រជាពលរដ្ឋមួយចំនួននៅមានទំលាប់បន្ទោរបង់ពាសវាលពាសកាល

-ប្រជាពលរដ្ឋយល់ដឹងពីអនាម័យ និងសុខភាពនៅមានកំរិត

-មិនទាន់អនុវត្តបាននូវសារគន្លឹះទាំង បី គឺ ប្រើបង្គន់អនាម័យ លាងដៃនិងសាប៊ូ ពិសារទឹកសុវត្ថភាព

-ការគាំទ្រ និងការចូលរួមពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់នៅមានកម្រិត

-ប្រជាពលរដ្ឋភាគច្រើនគ្មានលទ្ធភាពសាងសង់បង្គន់និងមួយចំនួនទៀតត្រូវពឹងផ្អែកលើជំនួយទាំងស្រុង។

តារាង ៖ អនាម័យនៃការទទួលទានទឹក (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| គ្រួសារដែលទំលាប់ទទួលទានទឹកពី ៖ | 2009 | 2010 | 2011 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួនគ្រួសារ |
| ទឹកម៉ាស៊ីនឬទឹកបរិសុទ្ធ | | | 2.42 | 1,119 |
| ប្រើឧបករណ៍ចម្រោះទឹក | 14.65 | 16.45 | 11.04 | 5,097 |
| ធ្វើទឹកឱ្យស្អាតដោយដាក់សារជាតិក្លរ៍ | | | 0.47 | 218 |
| ទឹកសំលាប់មេរោគដោយពន្លឺព្រះអាទិត្យ | | | 0.10 | 0 |
| ដោយដាំទឹកឱ្យពុះ | 23.36 | 23.52 | 32.33 | 14,933 |

តារាង ៖ ស្ថានភាពនៃការប្រើប្រាស់ទឹក (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| គ្រួសារដែលនិយមប្រើប្រាស់ទឹកពីប្រភព ៖ | 2009 | 2010 | 2011 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួនគ្រួសារ |
| ទឹកដែលឆ្លងកាត់ប្រព័ន្ធធ្វើទឹកឱ្យស្អាត | 3.22 | 4.00 | 2.86 | 1,319 |
| ទឹកអណ្តូងស្នប់ឬអណ្តូងចំរុះ | 57.52 | 60.94 | 56.80 | 26,234 |
| ទឹកអណ្តូងជីកមានការការពារ | | | 8.04 | 3,715 |
| ទឹកអណ្តូងជីកមិនមានការការពារ | | | 12.10 | 5,587 |
| ទឹកស្រះ | 2.20 | 2.25 | 4.14 | 1,912 |
| ទឹកភ្លៀងដែលមានការការពារ | | | 3.37 | 1,556 |
| ទឹកពីប្រភពផ្សេងៗ(ទន្លេ ស្ទឹង អូរ ជ្រោះ) | 6.34 | 5.17 | 12.69 | 5,816 |

ក្រាហ្វិក ៖ ភាគរយគ្រួសារប្រើប្រាស់ទឹកអណ្តូងជីកមានការការពារ




| បរិយាយ | 2009 | 2010 | 2011 | ចំនួនអណ្តូង |
|---|---|---|---|---|
| ផលធៀបអណ្តូងខួងនិងគ្រួសារប្រើប្រាស់ | | | 6.48 | 4,048 |
| ផលធៀបអណ្តូងជីកមានការពារនិងគ្រួសារប្រើប្រាស់ | | | 4.31 | 862 |

| | | | | |
|---|---|---|---|---|
| ផលធៀបអណ្តូងជីកគ្មានការពារនិងគ្រួសារប្រើប្រាស់ | | | 4.47 | 1,249 |
| ផលធៀបស្រះទឹកនិងគ្រួសារប្រើប្រាស់ | | | 5.10 | 375 |

ក្រាហ្វិក ៖ ផលធៀបគ្រួសារប្រើប្រាស់និងអណ្តូងខួង




តារាង ៖ ការប្រើប្រាស់បង្គន់អនាម័យ (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| | 2009 | 2010 | 2011 | |
|---|---|---|---|---|
| | ភាគរយ | ភាគរយ | ភាគរយ | ចំនួនគ្រួសារ |
| គ្រួសារមានបង្គន់អនាម័យប្រើប្រាស់ | 8.89 | 11.31 | 18.58 | 8,579 |
| គ្រួសារប្រើប្រាស់បង្គន់មានបច្ចេកទេស | | | 12.15 | 5,612 |
| គ្រួសារប្រើប្រាស់បង្គន់គ្មានបច្ចេកទេស | | | 6.42 | 2,967 |
| គ្រួសារមានប្រភពទឹកជិតជាង១៥0ម៉ែត្រពីផ្ទះ | 63.11 | 59.68 | 59.98 | 27.702 |
| គ្រួសារមានប្រភពទឹកឆ្ងាយជាង១៥0ម៉ែត្រពីផ្ទះ | 31.18 | 26.94 | 23.92 | 11,049 |

ក្រាហ្វិក ៖ ភាគរយគ្រួសារមានប្រភពទឹកជិតជាង១៥0ម៉ែត្រ




ក្រាហ្វិក ៖ ភាគរយគ្រួសារគ្មានបង្គន់អនាម័យ




**ខ.ការងារផ្លូវជនបទ**

ផ្លូវជនបទ គឺជាប្រព័ន្ធគមនាគមន៍ដឹកជញ្ជូនដ៏សំខាន់ សម្រាប់តភ្ជាប់ពីជនបទមកកាន់ផ្លូវជាតិ ផ្លូវខេត្ត ទីផ្សារ សាលារៀន មណ្ឌលសុខភាព វត្តអារាម តំបន់ទេសចរណ៍ និងកសិកម្ម។ល។ ផ្លូវជនបទបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងកាត់បន្ថយភាពក្រីក្រ។ ក្នុងការងារកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ដោយប្រើប្រាស់ថវិកាជាតិ មន្ទីរបានអនុវត្តគម្រោងថែទាំផ្លូវលំជាលក្ខណៈខួប១ខ្សែប្រវែង ២៦ គ.ម លូ៥កន្លែង ថែទាំជាលក្ខណៈប្រចាំ ១ខ្សែប្រវែង ២៧ គ.ម ជួលជុល និងសាងសង់ផ្លូវ អនុវត្តដោយកងវិស្វកម្ម និងក្រសួងអភិវឌ្ឍន៍ជនបទ ប្រវែង ៩២ គ.ម ផ្លូវប្រភេទ DBST ប្រវែង ៨ គ.ម ស្ពាន១៨ កន្លែង និងលូ ១៣២កន្លែង។

**ប្រភេទផ្លូវជនបទ:** ផ្លូវជនបទប្រភេទទី១ : ផ្លូវជាតិ-ផ្លូវខេត្ត ទៅក្រុង ស្រុក ខណ្ឌ និងពី ក្រុង ស្រុក ខណ្ឌ ទៅ ក្រុង ស្រុក ខណ្ឌ។ ផ្លូវជនបទប្រភេទទី២ : ក្រុង ស្រុក ខណ្ឌ ទៅឃុំ សង្កាត់។ ផ្លូវជនបទប្រភេទទី៣ : ឃុំ សង្កាត់ ទៅ ឃុំ សង្កាត់។ ផ្លូវជនបទប្រភេទទី៤ : ឃុំ សង្កាត់ ទៅភូមិ ពីភូមិ ទៅភូមិ និងផ្លូវក្នុងភូមិ។

មន្ទីរបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដូចជា ការដឹកទំនិញលើសទម្ងន់លើផ្លូវជនបទ ពុំសូវមានការចូលរួមសហការពីសំណាក់សហគមន៍ និងអាជ្ញាធរក្នុងការថែទាំផ្លូវជនបទ ខ្វះថវិកាសម្រាប់ជួសជុល និងថែទាំផ្លូវជនបទ មានគ្រោះទឹកជំនន់ដែលបណ្តាលឱ្យមានការខូចខាតផ្លូវ ខ្វះធនធានមនុស្ស ឧបករណ៍ និងសម្ភារៈសម្រាប់ការងារគ្រប់គ្រង និងថែទាំផ្លូវជនបទ ខ្វះឯកសារ និងលិខិតបទដ្ឋានគតិយុត្តិសម្រាប់ការគ្រប់គ្រង និងថែទាំផ្លូវជនបទ។

**គ. វិស័យជនជាតិដើមភាគតិច** មានបញ្ហាប្រឈមដូចខាងក្រោម:

- ជនជាតិដើមភាគតិច កំពុងប្រឈមនឹងការបាត់បង់ភាសារបស់ខ្លួនជាបណ្តើរៗ ព្រោះថា បច្ចុប្បន្នមានតែមនុស្សចាស់ប៉ុណ្ណោះ ដែលចេះនិយាយភាសារបស់ខ្លួន ចំណែកក្មេងជំនាន់ក្រោយ តិចតួចប៉ុណ្ណោះដែលចេះប្រើភាសាជនជាតិដើមភាគតិច។
- ការសិក្សារបស់បងប្អូនជនជាតិភាគតិច ភាគច្រើនមិនបានបញ្ចប់ការសិក្សានៅកំរិតមធ្យមសិក្សា ដោយសារមិនសូវយល់ដឹងពីតម្លៃនៃការសិក្សា។
- ការប្រើប្រាស់ធនធានធម្មជាតិ ជាលក្ខណៈសម្ហូហភាព ប៉ុន្តែក្រុមគាត់គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន (បាត់បង់នូវជំនឿ ផលប្រយោជន៍សម្ហូហភាព)
- ការបាត់បង់នូវមុខរបរ (មានការបាត់បង់ដើមច្បោះជ័រ...)។

- ការយល់ដឹងពីសុខភាព-អនាម័យនៅមានកំរិត ។
- ការផ្តល់សេវាសុខភាពដល់ជនជាតិនៅមានកំរិត ។
- ពុំមានថវិកាសម្រាប់ធ្វើការអភិវឌ្ឍន៍ដល់វិស័យជនជាតិភាគតិច ។
- អង្គការក្រៅរដ្ឋាភិបាលមួយចំនួនមិនសូវបានចាប់អារម្មណ៍លើការងារជនជាតិភាគតិច ។
  - ទំនៀមទំលាប់ប្រពៃណីរបស់ជនជាតិភាគតិច ឈានទៅរកការបាត់បង់ (មិនបានអភិរក្ស) ។

តារាង ៖ ជនជាតិដើមភាគតិច (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| លរ. | ប្រភេទស្ថិតិ | ចំនួន |
|---|---|---|
| 1 | **សរុប គ្រួសារជនជាតិដើមភាគតិច** | **4,243** |
| 2 | **សរុប ជនជាតិដើមភាគតិច** | **18,816** |
| 3 | **សរុបស្រីជនជាតិដើមភាគតិច** | **9,731** |
| | **ក-ជាតិដើមភាគតិច ព្នង** | |
| 1 | ចំនួនគ្រួសារជនជាតិដើមភាគតិច ព្នង | 1 |
| 2 | សរុបជនជាតិដើមភាគតិចព្នង | 7 |
| 3 | សរុបស្រីជនជាតិដើមភាគតិចព្នង | 2 |
| | **ខ-ជាតិដើមភាគតិច កួយ** | |
| 1 | ចំនួនគ្រួសារជនជាតិដើមភាគតិច កួយ | 3,927 |
| 2 | សរុបជនជាតិដើមភាគតិចកួយ | 17,158 |
| 3 | សរុបស្រីជនជាតិដើមភាគតិចកួយ | 8,904 |
| | **គ -ជាតិដើមភាគតិច ទំពួន** | |
| 1 | ចំនួនគ្រួសារជនជាតិដើមភាគតិច ទំពួន | 3 |
| 2 | សរុបជនជាតិដើមភាគតិចទំពួន | 9 |
| 3 | សរុបស្រីជនជាតិដើមភាគតិចទំពួន | 3 |
| | **ឃ -ជាតិដើមភាគតិច ចារាយ** | |
| 1 | ចំនួនគ្រួសារជនជាតិដើមភាគតិច ចារាយ | 1 |
| 2 | សរុបជនជាតិដើមភាគតិចចារាយ | 2 |
| 3 | សរុបស្រីជនជាតិដើមភាគតិចចារាយ | 1 |
| | **ង -ជាតិដើមភាគតិច គ្រឹង** | |
| 1 | ចំនួនគ្រួសារជនជាតិដើមភាគតិច គ្រឹង | 6 |
| 2 | សរុបជនជាតិដើមភាគតិចគ្រឹង | 23 |
| 3 | សរុបស្រីជនជាតិដើមភាគតិចគ្រឹង | 10 |
| | **ច -ជាតិដើមភាគតិច ព័រ** | |
| 1 | ចំនួនគ្រួសារជនជាតិដើមភាគតិចព័រ | 305 |
| 2 | សរុបជនជាតិដើមភាគតិចព័រ | 1,617 |

| 3 | សរុបស្រីជនជាតិដើមភាគតិចព័រ | 811 |
|---|---|---|

## ១.២.២ ស្ថានភាពសង្គមកិច្ច

### ១.២.២.១ វិស័យអប់រំយុវជន និងកីឡា

មន្ទីរអប់រំ យុវជន និងកីឡាខេត្ត បានខិតខំអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំខេត្តឆ្នាំ២០០៧-២០០៩ ឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០០៦-២០១០របស់ក្រសួងអប់រំយុវជននិងកីឡាខេត្ត ដើម្បីឈានទៅសម្រេចផែនការជាតិអប់រំសម្រាប់ទាំងអស់គ្នាឆ្នាំ២០១១-២០១៥ និងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ជាពិសេសដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងនិតិកាលទី៤របស់សភាជាតិ គឺជម្រុញកំណើនការងារ ធានាសមធម៌ និងប្រសិទ្ធភាពឱ្យសមស្របតាមនិន្នាការរីកចម្រើនរបស់ពិភពលោក ។

***តារាង*** **: ចំនួនសាលារៀន ថ្នាក់រៀន សិស្ស មន្ត្រីអប់រំ/បុគ្គលិកសិក្សា (តួលេខដើមឆ្នាំសិក្សា២០១១-១២)**

| បរិយាយ | សាលា/កន្លែង | ថ្នាក់រៀន | សិស្ស/គរុសិស្ស/គរុនិស្សិត | | មន្ត្រីអប់រំ/បុគ្គលិកសិក្សា | | | |
|---|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | មន្ត្រីអប់រំ/បុគ្គ.សិក្សា | ស្រី | បុគ្គ.បង្រៀន | ស្រី |
| មន្ទីរអយកខេត្ត | | | | | 60 | 12 | | |
| ការិ.អយកស្រុក | | | | | 70 | 13 | | |
| **សរុប** | | | | | **130** | **25** | | |
| មត្តេយ្យសិក្សា | 62 | 75 | 1,906 | 1,000 | 36 | 36 | 34 | 34 |
| បឋមសិក្សា | 205 | 1,255 | 36,279 | 17,869 | 991 | 375 | 825 | 333 |
| អនុវិទ្យាល័យ | 39 | 152 | 5,836 | 3,042 | 330 | 87 | 304 | 82 |
| វិទ្យាល័យ | 09 | 107 | 4,644 | 2,1855 | 173 | 65 | 151 | 58 |
| ម.បឋមភូមិ | | *176* | *6,920* | *3,568* | | | | |
| ម.ទុតិយភូមិ | | *83* | *3,560* | *1,641* | | | | |
| **សរុប** | **315** | **1,848** | **59,145** | **48,975** | **1,530** | **563** | **1,323** | **507** |
| អក្ខរកម្ម | 25 | 25 | 500 | 335 | | | 25 | 14 |
| ចូលរៀនឡើងវិញ | 37 | 52 | 723 | 399 | | | 49 | 17 |
| ម.សិក្សាសហគមន៍ | 06 | 19 | 166 | 69 | | | 17 | 10 |
| បំពេញវិជ្ជា | 01 | 02 | 40 | 60 | | | 11 | 03 |
| ថ្នាក់សង្គ្រោះបន្ទាន់ | 0 | 0 | 0 | 0 | | | 0 | 0 |
| **សរុប** | **69** | **98** | **1,429** | **863** | | | 102 | 44 |
| សាលាគរុកោសល្យ | 01 | 03 | 84 | 49 | 19 | 06 | 19 | 06 |
| **សរុប** | **01** | **03** | **84** | **49** | **19** | **06** | **19** | **6** |

***ប្រភព*** **:** *របាយការណ៍របស់មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើមឆ្នាំសិក្សា ២០១១-១២*

ទោះបីមានការរីកចម្រើនក៏ដោយ មន្ទីរបានជួបប្រទះនូវបញ្ហាលំបាកខ្លះៗដូចជា ៖ ខ្វះបន្ទប់រៀន អគារសិក្សា និងគ្រូមត្តេយ្យសិក្សាដែលមានលក្ខណៈសមស្របតាមបច្ចេកទេសគរុកោសល្យមត្តេយ្យ។ ខ្វះគ្រូបង្រៀននៅតាមសាលារៀននៅតំបន់ដាច់ស្រយាល និងខ្វះសៀវភៅសិក្សាគោលសម្រាប់គ្រូ និងសិស្ស។ សាលារៀននៅឆ្ងាយពីភូមិ ឃុំមួយចំនួនពុំទាន់មាន អនុវិទ្យាល័យ និងពុំទាន់មានគ្រូសមស្របទៅតាមមុខវិជ្ជាឯកទេសនៅមធ្យមសិក្សា។ ការអនុវត្តម៉ោងសិក្សាទៅតាមប្រតិទិនសិក្សាពុំទាន់បានសមស្របតាមការណែនាំរបស់ក្រសួងអប់រំយុវជននិងកីឡា។ ប្រជាពលរដ្ឋនៅរាយប៉ាយតាមភូមិកើតថ្មី ផ្លាស់ប្តូរទីលំនៅញឹកញាប់ និងយកកូនទៅស្រែចំការ នៅរដូវធ្វើស្រែចំការ ។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាខាងលើ មន្ទីរអប់រំយុវជន និងកីឡាខេត្ត មានការសហការល្អជាមួយអង្គការជាតិ អន្តរជាតិ សប្បុរសជនជាតិ អន្តរជាតិ និងសហគមន៍នៅក្នុងមូលដ្ឋានបានបង្កើតជាសាលារោងដោលដែលជាសាលាឆ្លងកាត់ និងជាសាលាដែលស្ថិតនៅក្បែរផ្ទះប្រជាជនបំផុតសម្រាប់ឱ្យកុមារដែលទើបនឹងគ្រប់អាយុបានចូលរៀននៅថ្នាក់ទី១ ទី២ និងបានរៀបចំឱ្យមានថ្នាក់សម្រាប់មធ្យមសិក្សាបឋមភូមិនៅក្នុងបឋមសិក្សា។ ដោយមានកិច្ចសហប្រតិបត្តិការដ៏ល្អជាមួយដៃគូអភិវឌ្ឍន៍នានាជាច្រើនដែលមានក្នុងខេត្ត បាននាំគ្នាឧបត្ថម្ភជួយសង់ជាសាលាឆ្លងកាត់ បណ្តុះបណ្តាលកែលម្អវិធីសាស្ត្របង្រៀនថ្មីៗ និងកែលម្អបរិស្ថានសាលាឱ្យទៅជាបរិស្ថានសិក្សាកុមារមេត្រី។ ម្យ៉ាងវិញទៀត មន្ទីរបានរៀបចំឱ្យមានការប្រើប្រាស់គ្រូជាប់កិច្ចសន្យា គ្រូបង្រៀនថ្នាក់គួប ពីរពេល និងគ្រូបឋមសិក្សាជួយបង្រៀននៅបឋមភូមិ គ្រូមធ្យមសិក្សាបឋមភូមិជួយបង្រៀននៅមធ្យមសិក្សាទុតិយភូមិទៅតាមចំណេះដឹងមូលដ្ឋានដែលពួកគេមាន។

ភាគរយអ្នកមិនចេះអក្សរពីអាយុ១៥ទៅ ៤៥ឆ្នាំមានចំនួន២១,៤៨% ក្នុងនោះស្ត្រីមានចំនួន១០,៩៥% បញ្ហានេះជាឧបស័គ្គសម្រាប់ការងារអភិវឌ្ឍន៍ក្នុងមូលដ្ឋាន ក៏ដូចជាការផ្តល់ចំណេះដឹងទូទៅសម្រាប់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

តារាង ៖ ស្ថានភាពអ្នកមិនចេះអក្សរ (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| បរិយាយ | 2009 | 2010 | 2011 | |
|---|---|---|---|---|
| សរុបមនុស្សអាយុ១៥-៤៥ឆ្នាំ | 77,798 | 84,057 | 93,885 | |
| សរុបមនុស្សស្រីអាយុ១៥-៤៥ឆ្នាំ | 39,708 | 42,812 | 47,390 | |
| %អ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | 26.13 | 23.79 | 21.48 | 20,162 |
| %ស្រីមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំ | 13.23 | 12.38 | 10.95 | 10,284 |
| %អ្នកមិនចេះអក្សរអាយុ១៥-១៧ឆ្នាំ | 15.19 | 13.22 | 16.51 | 2,596 |
| %ស្រីមិនចេះអក្សរអាយុ១៥-១៧ឆ្នាំ | 14.68 | 13.32 | 16.26 | 1,262 |
| %អ្នកមិនចេះអក្សរអាយុ១៨-២៤ឆ្នាំ | 23.67 | 22.78 | 19.40 | 4,940 |
| %ស្រីមិនចេះអក្សរអាយុ១៨-២៤ឆ្នាំ | 22.38 | 24.19 | 19.34 | 2,488 |
| %អ្នកមិនចេះអក្សរអាយុ២៥-៣៥ឆ្នាំ | 29.83 | 25.61 | 22.35 | 6,559 |
| %ស្រីមិនចេះអក្សរអាយុ២៥-៣៥ឆ្នាំ | 30.25 | 25.23 | 22.58 | 3,357 |
| %អ្នកមិនចេះអក្សរអាយុ៣៦-៤៥ឆ្នាំ | 32.22 | 30.17 | 25.99 | 6,067 |

| | | | | |
|---|---|---|---|---|
| %ស្រីមិនចេះអក្សរអាយុ៣៦-៤៥ឆ្នាំ | 32.34 | 31.01 | 26.70 | 3,177 |

ក្រាហ្វិក ៖ ចំនួនអ្នកមិនចេះអក្សរអាយុ១៥-៤៥ឆ្នាំតាមបណ្តាក្រុង ស្រុក




ក្រាហ្វិក ៖ ចំនួនអ្នកមិនចេះអក្សរអាយុ១៥-១៧ឆ្នាំតាមបណ្តាក្រុង ស្រុក




ក្រាហ្វិក ៖ ចំនួនអ្នកមិនចេះអក្សរអាយុ១៨-២៤ឆ្នាំតាមបណ្តាក្រុង ស្រុក




### ១.២.២.២ វិស័យសុខាភិបាល

មន្ទីរសុខាភិបាលមានស្រុកប្រតិបត្តិ០១ មន្ទីរពេទ្យបង្អែកខេត្ត០១ មណ្ឌលសុខភាព២០ និងប៉ុស្តិ៍សុខភាព ១៥កន្លែង មានបុគ្គលិកសរុប៣៥៣នាក់ ស្រី ១៥២ នាក់ ក្នុងនោះមានវេជ្ជបណ្ឌិត២៣នាក់ គ្រូពេទ្យ៤នាក់ ឱសថការី ៥នាក់ គិលានុបដ្ឋាកមធ្យម៩១នាក់ គិលានុបដ្ឋាកបឋម៨៥នាក់ ឆ្មបមធ្យម ៣៥នាក់ និង ឆ្មបបឋម៨៥នាក់។

ទោះបីវិស័យសុខាភិបាលបានរីកចំរើនពី១ឆ្នាំទៅ១ឆ្នាំក៏ដោយ ក៏នៅពុំទាន់ឆ្លើយតបតាមតម្រូវការរបស់ប្រជាជននៅឡើយ ដោយសារស្ថានភាពភូមិសាស្ត្រលំបាក ការរស់នៅរបស់ប្រជាជននៅរាយប៉ាយ ធ្វើឱ្យមានការលំបាកខ្លាំងសម្រាប់អ្នកទទួលយកសេវា និងការផ្តល់សេវា។ ការខ្វះធនធានមនុស្ស ធ្វើឱ្យមានការលំបាកយ៉ាងខ្លាំងក្នុងការពង្រីកបន្ថែមនូវមណ្ឌលសុខភាព។ ដូច្នេះមន្ទីរមានផែនការពង្រីកបន្ថែមនូវមូលដ្ឋានសុខាភិបាលដែលមានកំរិតប៉ុស្តិ៍សុខភាព។

មន្ទីរសុខាភិបាលខេត្តសំរេចលទ្ធផលបានអាស្រ័យលើការចូលរួមពីគ្រប់មជ្ឈដ្ឋានទូទាំងខេត្តដូចជា សហគមន៍ មន្ទីរពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមួយចំនួនដូចជា អង្គការអេច ភី អេ (ជួយកម្មវិធីគ្រុនចាញ់ និង របេង មួយផ្នែក) អង្គការរ៉ាឆា (ជួយកម្មវិធីសុខភាពបន្តពូជយុវវ័យ) អង្គការទស្សនៈពិភពលោក (ជួយកម្មវិធីអេដស៍) អង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ (ជួយកម្មវិធីអនាម័យនិងសុខភាព) ពិសេសអាជ្ញាធរដែនដី គ្រប់លំដាប់ថ្នាក់។

សមិទ្ធផលសំរេចបានពីឆ្នាំ ២០០៩-២០១១ (ប្រភពទិន្នន័យៈមន្ទីរសុខាភិបាលខេត្ត)

| **សូចនាករ** | **២០០៩** | **២០១០** | **២០១១** |
|---|---|---|---|
| ១-%នៃស្ត្រីរៀបការបានប្រើប្រាស់មធ្យោបាយពន្យាកំណើតទំនើប | 42% | 42.5% | 44% |
| ២-%នៃស្ត្រីមានផ្ទៃពោះបានទទួលការពិនិត្យផ្ទៃពោះយ៉ាងតិច ២ដង | 72.5% | 73% | 78% |
| ៣-%នៃការសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលបានបណ្តុះបណ្តាល | 38% | 35% | 49% |
| ៤-%នៃការសំរាលកូនដោយវះកាត់ | 1% | 1% | 1% |
| ៥-%នៃកុមារអាយុក្រោម ១ ឆ្នាំ បានទទួលវ៉ាក់សាំងបង្ការជំងឺកញ្ជ្រិល | 71% | 74% | 79% |
| ៦-%នៃកុមារអាយុក្រោម ១ ឆ្នាំ បានទទួលវ៉ាក់សាំងបង្ការជំងឺរបេង | 81% | 73% | 74% |
| ៧-អត្រាស្រាវជ្រាវករណីជំងឺរបេងសួតបេកាវិជ្ជមាន | 50% | 51% | 50% |
| ៨-អត្រាជាសះស្បើយនៃជំងឺរបេង | 91% | 90% | 91% |
| ៩-ចំនួនករណីគ្រុនចាញ់ដែលបានព្យាបាលនៅមូលដ្ឋានសុខាភិបាល | 38/1000 | 16/1000 | 26/1000 |
| ១០-អត្រាស្លាប់ដោយជំងឺគ្រុនឈាមដែលរាយការណ៍ដោយមូលដ្ឋានសុខា. | 0 | 1.7% | 0 |
| ១១-អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ | 1.7% | 1.3% | 1% |
| ១២-អត្រាប្រើប្រាស់គ្រែ | 90% | 131% | 131% |
| ១៣-រយៈពេលមធ្យមនៃការសំរាកព្យាបាល | 5 | 5 | 5 |
| ១៤-ករណីពិគ្រោះជម្ងឺករណីថ្មីលើប្រជាជនមួយនាក់ក្នុង១ឆ្នាំ | 0.9 | 1.1 | 1.5 |

### ១.២.២.៣ វិស័យវប្បធម៌ និងវិចិត្រសិល្បៈ

ខេត្តព្រះវិហារសម្បូរទៅដោយបេតិកភ័ណ្ឌវប្បធម៌រូបីយ រួមមាន ប្រាង្គប្រាសាទជាច្រើនកន្លែង និងស្រះបុរាណ ស្ពានបុរាណ រមណីយដ្ឋានធម្មជាតិ និងបុរេប្រវត្តិសាស្ត្រម្លូព្រៃ។ មិនតែប៉ុណ្ណោះ នៅមានបេតិកភ័ណ្ឌ

អរូបីយជាច្រើនប្រភេទ ច្រើនទម្រង់ទៀត ដូចជាចម្រៀង របាំ ល្ខោន ក្បាច់គុណបុរាណ និងទំនៀមទំលាប់ប្រពៃណី របស់ជនជាតិដើមភាគតិច ។ ទាំងនេះជាស្នាដៃដែលបុព្វបុរសដូនតាយើងបានបន្សល់ទុកឱ្យកូនចៅជំនាន់ក្រោយ ។

កេរ្តិ៍មរតកដ៏សម្បូរបែបនៃសម្បត្តិវប្បធម៌ទាំងអស់នេះ បច្ចុប្បន្នបានក្លាយជាកម្លាំងចលករប្រកបដោយប្រសិទ្ធភាពបំផុតក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម តាមរយៈការបង្កើតការងារ បង្កើនចំណូលស្របតាមទស្សនទាន **(វប្បធម៌គឺជាសេដ្ឋកិច្ចជាតិ)** ដែលជាចំណែកមួយដ៏ចាំបាច់ក្នុងការចូលរួមកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ដោយបានដាក់ចេញនូវកម្មវិធីនយោបាយ ថែរក្សាការពារលើកតម្កើងកេរ្តិ៍ដំណែលវប្បធម៌ជាតិ និងអភិវឌ្ឍន៍សកម្មភាពវប្បធម៌គ្រប់ជំនាញនៅតាមមូលដ្ឋាន។ ជម្រុញផលិតកម្មសិប្បកម្មវប្បធម៌ ដោយលើកទឹកចិត្តឱ្យមានការបង្កើតស្នាដៃថ្មី និងផ្សព្វផ្សាយអំពីផលិតផលវប្បធម៌ខ្មែរដ៏សម្បូរបែប។ អប់រំអំពីវប្បធម៌ និងសីលធម៌ដ៏ល្អថ្លៃថ្លារបស់ជាតិ ទប់ស្កាត់ការហូរចូលឥតឈប់ឈរនៃវប្បធម៌អវិជ្ជមានពីបរទេស កាត់បន្ថយសកម្មភាពមិនល្អក្នុងស្រទាប់យុវជន និងកុមារដែលធ្វើឱ្យប៉ះពាល់ដល់វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ដ៏ល្អផូរផង់របស់ជាតិ។

បន្តថែរក្សា និងអភិវឌ្ឍន៍វប្បធម៌ប្រពៃណីទំនៀមទម្លាប់ ភាសារបស់បងប្អូនជនជាតិដើមភាគតិច និងជម្រុញការអភិវឌ្ឍតំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឱ្យមានការរីកចម្រើនខាងសង្គមសេដ្ឋកិច្ច និងជីវភាពរស់នៅឈានឡើងស្របតាមកម្រិតរីកចម្រើនរួមរបស់ជាតិ ។

កន្លងមកក៏ដូចជាបច្ចុប្បន្ន មន្ទីរបានជួបប្រទះបញ្ហាប្រឈមដូចជាការងារថែរក្សា និងគ្រប់គ្រងនៅមានកំរិត ដោយបណ្តាលមកពីខ្វះក្របខ័ណ្ឌ និង ធនធានមនុស្ស។ ប្រជាពលរដ្ឋខ្វះការយល់ដឹងពីតម្លៃបេតិកភ័ណ្ឌជាតិ និង អត្តសញ្ញាណជាតិ ដោយមូលហេតុភាពក្រីក្រ លំហូរចូលវប្បធម៌អវិជ្ជមានពីបរទេស ការបណ្តុះបណ្តាល និងផ្សព្វផ្សាយពីច្បាប់ពាក់ព័ន្ធនិងវិស័យវប្បធម៌មិនបានទូលំទូលាយដល់មូលដ្ឋាន។ ដោយសារបញ្ហានិងមូលហេតុទាំងនេះ មន្ទីរបានរៀបចំជាផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ឱ្យប្រសើរឡើង ទាំងផ្នែកធនធានមនុស្ស និងការចូលរួមគាំទ្រពីមហាជននៅក្នុងខេត្តទាំងមូល ដើម្បីថែរក្សា និងលើកតម្កើងមរតកវប្បធម៌ឱ្យបានគង់វង្ស ។

វិស័យវប្បធម៌ និងវិចិត្រសិល្បៈនៅក្នុងខេត្តព្រះវិហារ នៅពុំទាន់ទទួលបានការចូលរួមគាំទ្រពីអង្គការសង្គមស៊ីវិលនៅឡើយសម្រាប់ការអនុវត្តន៍គម្រោងអភិវឌ្ឍន៍លើវិស័យវប្បធម៌នៅក្នុងខេត្ត។

**១.២.២.៤ <u>វិស័យព័ត៌មាន</u>**

មន្ទីរព័ត៌មានជាស្ថាប័នអនុវត្តសកម្មភាពផ្សព្វផ្សាយព័ត៌មាន និងសោតទស្សន៍ ដើម្បីបង្ហាញប្រាប់ដល់ប្រជាពលរដ្ឋគ្រប់មូលដ្ឋានបានដឹង និងបានឃើញនូវរាល់សភាពការណ៍ សមិទ្ធិផល ឬសកម្មភាពនានាក្នុងខេត្ត ដើម្បីរួមចំណែកអភិវឌ្ឍន៍សង្គមជាតិ។

មន្ទីរព័ត៌មានមានអាគារ០២ខ្នង សង់អំពីថ្មប្រក់ក្បឿងនៅផ្ទាល់ដី ស្ថិតក្នុងទីតាំងនៃបរិវេណតែមួយដែលក្នុងនោះមានអាគាររដ្ឋបាល ០១ ខ្នង ដែលទើបនិងសាងសង់រួចជាស្ថាពរ និងដំណើរការប្រើប្រាស់នៅដើមឆ្នាំ ២០១២ ដែលមាន ០៧ បន្ទប់ ក្នុងនោះមានសាលប្រជុំ ០១និងបន្ទប់ធ្វើការចំនួន០៦បន្ទប់ ព្រមទាំងអាគារស្ទូឌីយូវិទ្យុ A ០១ ខ្នង ដែលមាន ០៥ បន្ទប់ ពុំទាន់បំពាក់ឧបករណ៍។ មន្ទីរមានមន្ត្រីក្នុងក្របខ័ណ្ឌចំនួន ១៦ នាក់ ស្រី ០៣ នាក់ បុគ្គលិកជាប់កិច្ចសន្យា២០ នាក់ ស្រី ០៨នាក់ និងបុគ្គលិកអណ្តែត ០៥ នាក់

ស្រី ០៣ នាក់ ចែកចេញជា ០២ ការិយាល័យថ្នាក់ខេត្តមានការិយាល័យរដ្ឋបាលសោតទស្សន៍ និងការិយាល័យព័ត៌មាន ការិយាល័យថ្នាក់ស្រុក ក្រុងចំនួន ០៤ ។

នៅក្នុងខេត្តមានស្ថានីយ៍វិទ្យុចំនួន០២កន្លែងគឺវិទ្យុFM 99 រាជធានីភ្នំពេញនិងស្ថានីយ៍វិទ្យុផ្សាយបន្តបាយ័នដែលវិទ្យុទាំង០២ នេះមានវិសាលភាពគ្របដណ្តប់ អាចឱ្យប្រជាពលរដ្ឋស្តាប់បានប្រមាណ៨០% ក្នុងភូមិសាស្ត្រខេត្ត។ ស្ថានីយ៍ទាំងពីរនេះមានទីតាំងស្ថិតក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត ។ ក្នុងខេត្តមានស្ថានីយ៍ទូរទស្សន៍ផ្សាយបន្តបាយ័ន ០១កន្លែង ស្ថិតក្នុងឃុំកន្ទួត ស្រុកជាំក្សាន្ត ដែលអាចគ្របដណ្តប់ និងទស្សនាបានប្រមាណ ៣៥km ពីស្ថានីយ៍។ ក្រៅពីនោះមានស្ថានីយ៍ទូរទស្សន៍ខ្សែកាប ០២ កន្លែង មួយនៅក្រុងព្រះវិហារ និងមួយទៀតនៅស្រុករវៀង ។

សារព័ត៌មាន ឬកាសែតផ្សេងៗនៅក្នុងខេត្តមានភ្នាក់ងារកាសែត ដែលកំពុងធ្វើសកម្មភាពរបស់ខ្លួនដូចជា: កាសែតរស្មីកម្ពុជា កោះសន្តិភាព កម្ពុជាថ្មី មាតុភូមិ តាព្រហ្ម វរជ័យ និងភ្នាក់ងារសារព័ត៌មានកម្ពុជា (AKP) ។

មន្ទីរព័ត៌មានកំពុងជួបបញ្ហាប្រឈមមួយចំនួនដូចជា: ស្ថានីយ៍វិទ្យុ B មិនទាន់សាងសង់ និងមិនទាន់បំពាក់ឧបករណ៍។ អង់តែនវិទ្យុ-ទូរទស្សន៍របស់ស្ថានីយ៍ទូរទស្សន៍មិនទាន់បានសាងសង់នៅឡើយ។ រីឯឧបករណ៍បញ្ជូនព័ត៌មានពុំទាន់ឆ្លើយតបនិងការអភិវឌ្ឍន៍បច្ចុប្បន្ន ដែលធ្វើឱ្យការបញ្ជូនព័ត៌មានទូរទស្សន៍ និងវិទ្យុមានការយឺតយាវពុំទាន់ពេលវេលានៅឡើយ។

ជាការឆ្លើយតបនឹងតម្រូវការក្នុងខេត្ត មន្ទីរបានសាង់សង់អាគារស្ទូឌីយូវិទ្យុA មួយកន្លែង ព្រមទាំងទទួលការគាំទ្របន្តពីក្រសួង ដើម្បីសាងសង់អាគារស្ទូឌីយូវិទ្យុB សាងសង់អង់តែនវិទ្យុ-ទូរទស្សន៍ និងបំពាក់ឧបករណ៍វិទ្យុ-ទូរទស្សន៍ និងឧបករណ៍បញ្ជូនព័ត៌មានបែបបច្ចេកវិទ្យាថ្មី ដែលអាចបញ្ជូនព័ត៌មានបានរហ័សទាន់ពេលវេលា។ ជាងនេះទៅទៀត មន្ទីរបានចាត់បញ្ជូនមន្ត្រី ដើម្បីចូលរៀនក្នុងវគ្គស្តីពីបទយកការណ៍តាមវិទ្យុ ការរៀនសរសេរព័ត៌មានអត្ថបទវិទ្យុ និងទូរទស្សន៍ ដើម្បីបង្កើនសមត្ថភាពមន្ត្រី ព្រមទាំងការយកចិត្តទុកដាក់ក្នុងកិច្ចប្រតិបត្តិការលើវិស័យព័ត៌មានជាមួយបណ្តាខេត្តនានាក្នុងប្រទេស និងបណ្តាខេត្តមួយចំនួននៅប្រទេសថៃដែលមានទីតាំងជាប់និងខេត្តព្រះវិហារ។

បន្ថែមពីនេះមន្ទីរបានដាក់មន្ត្រីព័ត៌មានប្រចាំជាអចិន្ត្រៃយ៍នៅគ្រប់ស្រុកទូទាំងខេត្ត និងទីតាំងផ្សេងៗទៀតដូចជាតំបន់ប្រាសាទព្រះវិហារ ដើម្បីប្រមូលព័ត៌មាន និងលើវិស័យព័ត៌មានសោតទស្សន៍ក្នុងការបម្រើសេវាជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា៕

### ១.២.២.៥ វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តព្រះវិហារ ជាអង្គភាពរដ្ឋបាលបុព្វហេតុសាធារណៈ និងមានមុខងារ ភារកិច្ចធំៗចំនួនបីគឺ: ការងារសង្គមកិច្ច ការងារអតីតយុទ្ធជន និងការងារយុវនីតិសម្បទា ហើយកំពុងអនុវត្តការងារអត្ថិភាពចំនួន៦គឺៈ

1) សេវាសុខុមាលភាពសង្គមសម្រាប់មុខសញ្ញាជនក្រីក្រងាយរងគ្រោះ បច្ចុប្បន្នមន្ទីរកំពុងស្នើសុំថវិកាដើម្បីសាងសង់ផ្ទះចំនួន១៣ខ្នង និងគម្រោងស្នើសុំ ៦០ខ្នងទៀតជូនគ្រួសារអតីតយុទ្ធជនក្រីក្រសំរាប់ ឆ្នាំ ២០១៣-២០១៥ ។
2) សេវាសុខុមាលភាពកុមារ និង យុវនីតិសម្បទា មន្ទីរមានមជ្ឈមណ្ឌលកុមារកំព្រាមួយកន្លែងដែលមានកុមារចំនួន១០៤នាក់ ស្រី ៣៩នាក់ និងម៉ែដោះ ចំនួន ១០នាក់ កំពុងដំណើរការ។

3) សេវាសុខុមាលភាពជនពិការ និងស្តារលទ្ធភាពពលកម្ម បច្ចុប្បន្នមានជនពិការចំនួន៦២៦ នាក់កំពុងទទួលសេវានិង បើកប្រាក់ឧបត្ថមពីមន្ទីរ។
4) ការងាររបបសន្តិសុខសង្គម សុខុមាលភាពមនុស្សចាស់ និងប្រជាជនទូទៅ។ បច្ចុប្បន្នមាននិវត្តន៍ជនចំនួន ៧១៩ នាក់កំពុងទទួលប្រាក់ឧបត្ថមពីមន្ទីរ។
5) ការងាររបបសន្តិសុខសង្គម និងសុខុមាលភាពនៃអតីតយុទ្ធជន មានមុខសញ្ញាគ្រួសារអតីតយុទ្ធជនចំនួន ៨២៣ គ្រួសារកំពុងទទួលប្រាក់ឧបត្ថមពីមន្ទីរ។
6) ការងារសមត្ថភាពមន្ត្រីរាជការ ភាពជាដៃគូរ ការគៀគរប្រភពធនធាន និងបង្កើនប្រសិទ្ធភាពនៃសេវាសង្គមកិច្ច។

ក្នុងឆ្នាំ២០១២ មន្ទីរមានថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្របខណ្ឌ ចំនួន ២៦នាក់ (ស្រី ៧នាក់) និង បុគ្គលិកអណ្តែតចំនួន ៩នាក់ ( ស្រី៦នាក់)។ ទន្ទឹមនេះមន្ទីរមានបញ្ហាប្រឈមខ្លះៗ ដូចជា មុខសញ្ញាមួយចំនួនមិនយល់ពីប្រាក់របបប្រចាំខែរបស់ខ្លួន មិនមកសួរនាំសហការជាមួយមន្ទីរ និងការគ្រប់គ្រងត្រួតពិនិត្យមុខសញ្ញានូវមានកំរិត។

ដើម្បីដំណើរការកសាងផែនការ៣ឆ្នាំ រំកិល ២០១៣-២០១៥ ឲ្យបានល្អមន្ទីរបានយកប្រកាសលេខ ៣៥៩ ស អ យ ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់មន្ទីរ ស អ យ ខេត្ត ក្រុង មកធ្វើការបែងចែកតួនាទី និងភារកិច្ច តាមការិយាល័យចំណុះមន្ទីរ និងខិតខំសហការជាមួយស្ថាប័នពាក់ព័ន្ធអាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គការជាតិ និងអន្តរជាតិ។

### ១.២.២.៦ វិស័យធម្មការ និង សាសនា

មន្ទីរធម្មការ និងសាសនាខេត្តគឺជាស្ថាប័នផ្តល់សេវាដែលមិនគិតពីប្រាក់កម្រៃ។ មន្ទីរមានតួនាទីសំខាន់ក្នុងការសម្របសម្រួលការងារសាសនា ពុទ្ធិកៈសាសនា រៀបចំគណៈកម្មាការវត្ត ដោះស្រាយបញ្ហាដែលកើតឡើងរវាងសង្ឃ និងគណៈកម្មាការអាចារ្យវត្ត រៀបចំឯកសារចុះបញ្ជី ចងក្រងជីវប្រវត្តិរបស់វត្ត ការរៀបចំប្លង់អភិវឌ្ឍន៍វត្តការ តែងតាំងគោរម្យងារ (តួនាទី) ព្រះសង្ឃ។

**ស្ថានភាពបច្ចុប្បន្ន:** មន្ទីរមានបុគ្គលិកក្របខ័ណ្ឌសរុបចំនួន០៤នាក់ ក្នុងនោះ០១នាក់បម្រើការងារ នៅថ្នាក់ស្រុក និង០៣នាក់ទៀតបម្រើការងារនៅមន្ទីរ។ នៅក្នុងមន្ទីរបានចែកជា៤ការិយាល័យគឺ ១.ការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ២.ការិយាល័យកិច្ចការព្រះពុទ្ធសាសនាផ្សាភ្ជាប់សង្គម ៣.ការិយាល័យពុទ្ធិកសិក្សា និងបណ្ណាល័យ ៤.ការិយាល័យពាហិរសាសនា។

មន្ទីរមានការិយាល័យនៅតាមស្រុកនិងក្រុង ប៉ុន្តែនៅការិយាល័យក្រុងពុំមានមន្ត្រីនៅឡើយ។ នៅតាមបណ្តាស្រុកទាំង៧ គឺមានមន្ត្រីក្របខ័ណ្ឌចំនួន១ស្រុក ឯ៥ស្រុកទៀតជាមន្ត្រីជាប់កិច្ចសន្យា។ ថ្វីត្បិតតែមន្ទីរមានធនធានមនុស្សតិចតួចក្តី ក៏មន្ទីរខិតខំអនុវត្តការងារដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- សាងសង់មន្ទីរធម្មការ និងសាសនាខេត្តរួចរាល់ជាស្ថាពរ ដោយប្រើប្រាស់ថវិការដ្ឋ។
- ការបើកអនុសំវច្ឆរ(សន្និបាតសង្ឃ) ប្រចាំឆ្នាំ។
- ការប្រលងធម្មវិន័យ(វិន័យសម្រាប់សង្ឃ) ។

- បានចុះស្រង់ស្ថិតិវត្ត ព្រះសង្ឃ អាចារ្យ គណៈកម្មការវត្ត តាជី យាយជី ក្មេងវត្ត និងសិស្សស្នាក់នៅក្នុងវត្ត។
- បានចូលរួមសិក្ខាសាលាប្រចាំឆ្នាំ ក្រោមការអញ្ជើញរបស់អង្គការសន្និស្ស័គ្រចិត្ត ដែលជាដៃគូរសម្រាប់ជួយទ្រទ្រង់វិស័យព្រះពុទ្ធសាសនា។
- បានចូលរួមសិក្ខាសាលាបូកសរុបប្រចាំឆ្នាំនៅក្រសួងធម្មការ និងសាសនា។
- បានចុះដោះស្រាយរាល់អធិករណ៍(ជម្លោះ)កើតឡើងតាមវត្ត។

**បញ្ហាជួបប្រទះ :** បញ្ហាជួបប្រទះរបស់មន្ទីរធម្មការ និងសាសនាខេត្តព្រះវិហារ រួមមាន :

- មន្ត្រីបម្រើការងារមានចំណេះដឹងនៅមានកំរិត។
- ខ្វះមធ្យោបាយសម្រាប់ចុះទៅពិនិត្យមើលនៅនឹងកន្លែងជាក់ស្តែង។
- ខ្វះមន្ត្រីសម្រាប់បម្រើការងារនៅថ្នាក់ ក្រុងស្រុក ឃុំ សង្កាត់។
- វត្តនីមួយៗពុំសូវធ្វើការទំនាក់ទំនងគ្នា។

**ដំណោះស្រាយ:** ដើម្បីដោះស្រាយរាល់បញ្ហាខាងលើនេះមន្ទីរមានវិធានការដូចខាងក្រោម :

- ស្នើសុំក្រសួងផ្តល់ក្របខ័ណ្ឌមន្ត្រីរាជការបន្ថែម
- រៀបចំប្រជុំផ្សព្វផ្សាយ និងបណ្តុះបណ្តាលដល់មន្ត្រីសង្ឃ គណៈកម្មាការអាចារ្យវត្ត និង
- ស្វែងរកដៃគូគាំទ្រលើវិស័យធម្មការ និងសាសនា។

**តារាងស្ថិតិព្រះពុទ្ធសាសនា** *( ប្រភព : ទិន្នន័យមន្ទីរ ធម្មការ និង សាសនា)*

| ស្រុក/ក្រុង | ភិក្ខុ | សមណេរ | សរុប | វត្ត | អាស្រម | រោងឧបោសថ | ព្រះវិហារ | សាលាឆទាន | អាចារ្យ | គណៈកម្មការ | តាជី | យាយជី | ក្មេងវត្ត | សិស្សស្នាក់ នៅវត្ត |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| **ព្រះសង្ឃគណៈមហានិកាយ** | | | | | | | | | | | | | | |
| ជ័យសែន | ១៦ | ៦៥ | ៨១ | ៩ | ១ | ៦ | ១ | ៩ | ៣៣ | ៥៥ | ០ | ១ | ១ | ៤ |
|ឆែប | ២០ | ៣៥ | ៥៥ | ៧ | ០ | ៣ | ៣ | ៦ | ១៤ | ៣៩ | ០ | ៨ | ០ | ៣ |
| ជាំក្សាន្ត | ៣៥ | ៦០ | ៩៥ | ១៤ | ០ | ១២ | ២ | ១៤ | ២៩ | ៧៣ | ៣ | ៤ | ៤ | ០ |
| គូលែន | ២៥ | ៥៥ | ៨០ | ១២ | ០ | ៦ | ២ | ១៤ | ៣៣ | ១២១ | ៧ | ៤៣ | ១៧ | ០ |
| រវៀង | ៣៥ | ៧៥ | ១១០ | ១៤ | ១ | ៧ | ៧ | ១៥ | ២៨ | ៦៣ | ២០ | ៤០ | ១៣ | ០ |
| សង្គមថ្មី | ២០ | ៤០ | ៦០ | ៧ | ០ | ៦ | ១ | ៧ | ៩ | ៤៥ | ២ | ១៨ | ១ | ០ |
| ត្បែងមានជ័យ | ១៥ | ២៩ | ៤៤ | ៦ | ០ | ៤ | ២ | ៦ | ២៣ | ៤៧ | ២ | ១៧ | ០ | ០ |
| ក្រុងព្រះវិហារ | ១៨ | ៣៥ | ៥៣ | ៧ | ១ | ៥ | ២ | ៧ | ២៣ | ៤៩ | ១២ | ០ | ០ | ២៦ |
| **ព្រះសង្ឃគណៈធម្មយុត្តិនិកាយ** | | | | | | | | | | | | | | |
| ក្រុងព្រះវិហារ | ១០ | ១៩ | ២៩ | ១ | | ១ | ០ | ១ | ២ | ៣ | ០ | ០ | ០ | ០ |
| **សរុបរួម** | **១៩៤** | **៤១៣** | **៦០៧** | **៧៧** | **៣** | **៥០** | **២០** | **៧៩** | **១៩៤** | **៤៩៥** | **៤៦** | **១៣១** | **៣៦** | **៣៣** |

**តារាងស្ថិតិពាហិរសាសនា (សាសនាផ្សេងៗ)** *( ប្រភព : ទិន្នន័យមន្ទីរ ធម្មការ និង សាសនា)*

| ឈ្មោះព្រះវិហារឬនិកាយ | ទីតាំង | ចំនួនស្នាក់ការវិហារ | ចំនួនគ្រូសាសនា | ចំនួនបរិស័ទ | |
|---|---|---|---|---|---|
| | | | | សរុប | ស្រី |
| សេវេនដេយអាត់វែនទីស | ក្រុងព្រះវិហារ | ១ | ១ | ៥១ | ៣០ |
| | រវៀង | ២ | ១ | ១៣០ | ៩៥ |
| ព្រេសប៊ិធេរ៉ាន់ | ជ័យសែន | ១ | ១ | ៣៥ | ៧ |
| | ក្រុងព្រះវិហារ | ១ | ១ | ១៥ | ៦ |
| ដំណឹងល្អទាំងបួន | ជាំក្សាន្ត | ១ | ១ | ២៦ | ១១ |
| | គូលែន | ១ | ១ | ១៨ | ៧ |
| | ត្បែងមានជ័យ | ១ | ១ | ១១០ | ៥០ |
| | ក្រុងព្រះវិហារ | ១ | ១ | ៣២ | ១៣ |
| បាហៃ | ក្រុងព្រះវិហារ | ១ | ១ | ២៦៦៥ | ១៤២៧ |
| បាបទិស | សង្គមថ្មី | ១ | ១ | ៣៦ | ២៣ |
| ឥស្លាមសាសនា | ក្រុងព្រះវិហារ | ២ | ១ | ៦៧៤ | ៣៦៤ |

## ១.២.២.៧ វិស័យយេនឌ័រ (កិច្ចការនារី)

ការជម្រុញលើកតម្កើងសមភាពយេនឌ័រ និងការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ ជាទិសដៅមួយដ៏សំខាន់របស់ខេត្ត ក៏ដូចជាគោលការណ៍របស់រាជរដ្ឋាភិបាល។ បច្ចុប្បន្នក្នុងខេត្តព្រះវិហារ ទាំងស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាលកំពុងខិតខំបណ្តុះបណ្តាល និងផ្សព្វផ្សាយ ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសមភាពយេនឌ័រ ដោយបានអនុវត្តការបញ្ជ្រាបយេនឌ័រ ការស្វែងរកមតិគាំទ្រ និងផ្សព្វផ្សាយច្បាប់ប្រឆាំងអំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ច្បាប់ទប់ស្កាត់ការជួញដូរមនុស្ស ជួញដូរផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការរំលោភសេពសន្ថវៈ ច្បាប់ប្រឆាំងនឹងការរើសអើងលើស្ត្រី និងកុមារ ដល់ថ្នាក់មូលដ្ឋានភូមិ ឃុំ និងទីប្រជុំជន។ ម្យ៉ាងវិញទៀតក៏មានការជម្រុញលើកស្ទួយសិទ្ធិកុមារ និងលើកទឹកចិត្តដល់ស្ត្រីឱ្យមានការចូលរួមបញ្ចេញមតិយោបល់ក្នុងសកម្មភាពការងារសង្គមឱ្យកាន់តែច្រើនថែមទៀត តាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

**វិស័យកិច្ចការនារី ជួបបញ្ហាប្រឈមមួយចំនួនដូចជា:**

- ក្របខ័ណ្ឌមន្ត្រីរាជការមានតិច មិនសមស្របនឹងទំហំការងារ
- សមត្ថភាពរបស់មន្ត្រី កិច្ចការនារី និងអ្នកទទួលបន្ទុកស្ត្រី-កុមារថ្នាក់មូលដ្ឋាននៅមានកំរិត និងមានការផ្លាស់ប្តូរនៅក្នុងពេលបោះឆ្នោតក្រុមប្រឹក្សាអាណត្តិទី៣នេះ
- ការិយាល័យកិច្ចការនារីស្រុកចំនួន០៣មិនទាន់មានការិយាល័យ បច្ចុប្បន្នធ្វើការងារជាមួយសាលាស្រុក

- អ្នកប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារមួយចំនួនមិនបានចូលរួមស្តាប់ការផ្សព្វផ្សាយអំពីច្បាប់
- អំពើហិង្សាក្នុងគ្រួសារ ការរំលោភសេពសន្ថវៈ ការធ្វើចំណាកស្រុក ការជួញដូរមនុស្ស ការជួញដូរគ្រឿងញៀន និងអំពើអសីលធម៌ផ្សេងៗនៅតែមាន
- ស្ត្រីជាជនរងគ្រោះច្រើនតែយោគយល់ចំពោះអំពើហិង្សា និងអំពើអសីលធម៌របស់ប្តី
- ការផ្តល់របាយការណ៍របស់អ្នកទទួលបន្ទុករបស់ស្ត្រីនិងកុមារមានការយឺតយ៉ាវ
- ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងគម្រោងនានាមិនបានទៀងទាត់តាមការកំណត់
- ថវិកាមានកំណត់ជាហេតុនៃការចុះមូលដ្ឋានមិនបានពេញលេញ
- ការផ្តល់ថវិកាពីថ្នាក់ជាតិសម្រាប់ការងារមន្ទីរនៅមានការយឺតយ៉ាវ

**ខ.ដំណោះស្រាយៈ**

- ពង្រឹងសមត្ថភាពមន្ត្រីក្នុងការអនុវត្តការងារគ្រប់ផ្នែក
- បើកវគ្គបណ្តុះបណ្តាលដល់ស្ត្រីក្នុងភាពជាអ្នកដឹកនាំ
- បើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសសម្របសម្រួលដល់មន្ត្រីនៅមូលដ្ឋាន

តារាង ៖ អំពើហឹង្សារក្នុងគ្រួសារ (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| បរិយាយ | 2009 | 2010 | 2011 |
|---|---|---|---|
| ចំនួនគ្រួសារមានអំពើហឹង្សាក្នុងគ្រួសារ | 1,085 | 863 | 1,006 |
| ផលធៀបចំនួនគ្រួសារមានអំពើហឹង្សាក្នុង១000គ្រួសារ | 28.97 | 21.65 | 21.78 |
| ចំនួនករណីអំពើហឹង្សាក្នុងគ្រួសារពាក់ពន្ធ័ដល់អាជ្ញាធរ | | | 412 |
| ចំនួនជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ | | | 764 |
| %ស្ត្រីអាយុ១៨ឆ្នាំឡើងរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ | | | 35.08 |
| ចំនួនអ្នកស្លាប់ដោយអំពើហឹង្សាក្នុងគ្រួសារ | | | 32 |
| %ស្ត្រីអាយុ១៨ឆ្នាំឡើងស្លាប់ដោយអំពើហឹង្សាក្នុងគ្រួសារ | | | 15.63 |

ក្រាហ្វិក ៖ ផលធៀបចំនួនគ្រួសារមានអំពើហឹង្សាក្នុង១០០០គ្រួសារ




### ១.២.២.៨ វិស័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

ការអភិវឌ្ឍន៍របស់ខេត្តព្រះវិហារសព្វថ្ងៃនេះកំពុងដំណើរការបានល្អ សមិទ្ធិផលទាំងឡាយបាន និងកំពុងលេចជារូបរាងឡើង ជាបណ្តើរៗនៅតាមមូលដ្ឋានដោយមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋាននានា។

ដើម្បីបន្តជម្រុញការអភិវឌ្ឍន៍ខេត្ត ឱ្យកាន់តែមានល្បឿនលឿនថែមទៀតនោះ មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្តបានចូលរួមកសាងនូវ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល២០១៣-២០១៥ ដោយស្របតាមគោលដៅអភិវឌ្ឍន៍សហស្សវត្ស និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២របស់រាជរដ្ឋាភិបាល ដើម្បីកំណើន ការងារ សមធម៌ និង ប្រសិទ្ធិភាព។

ក្នុងការរៀបចំកិច្ចអភិវឌ្ឍន៍ខេត្ត តម្រូវឱ្យមានការចូលរួមពីមន្ទីរជំនាញនានាជុំវិញខេត្ត វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលកំពុងបំពេញការងាររបស់ខ្លួនក្នុងខេត្តព្រះវិហារ ដោយជម្រុញលើកទឹកចិត្តឱ្យស្ថាប័នទាំងនោះចូលរួមក្នុងការរៀបចំនូវកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ឆ្នាំ២០១៣-២០១៥ នេះផងដែរ។ ទោះបីស្ថាប័នទាំងអស់នោះមានបេសកកម្ម និងជំនាញខុសៗគ្នាក៏ដោយ តែគោលដៅ និងគោលបំណងដូចៗគ្នា គឺដើម្បីចូលរួមចំណែកស្តារ និងអភិវឌ្ឍន៍ខេត្តព្រះវិហារបន្តទៀត ឈានទៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានទូទាំងខេត្ត។

មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច គឺជាអង្គភាពមួយដែលទទួលបេសកកម្មជាសេនាធិការឱ្យក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ព្រមទាំងជាសេនាធិការឱ្យអាជ្ញាធរខេត្តផងដែរ។ មន្ទីរមានរចនាសម្ព័ន្ធចាត់តាំងរបស់ខ្លួនសំខាន់ៗចំនួន៣ រួមមាន: ១-ការិយាល័យរដ្ឋបាល កិច្ចការទូទៅ ២-ការិយាល័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអាជ្ញាធរខេត្ត និង៣-ការិយាល័យអធិការកិច្ច ដូចមានចែងក្នុងប្រកាសលេខ ០៤៤ ទ.រ.ព.អ/ប្រក ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៥ សំដៅប្រឆាំងនឹងអំពើពុករលួយ ការរំលោភដោយអំណាច និងបាតុភាពអសកម្មនានា។

១. ការិយាល័យរដ្ឋបាលកិច្ចការទូទៅដឹកនាំដោយប្រធាន១រូប និងមន្ត្រីជាជំនួយការ២រូប មានភារកិច្ចជាសេនាធិការឱ្យប្រធានមន្ទីរលើការងារ:

- សម្របសម្រួល គ្រប់គ្រងចរាចរ ឯកសាររដ្ឋបាលផ្សេងៗរបស់មន្ទីរ
- គ្រប់គ្រងផ្នែករដ្ឋបាលមន្ត្រីរាជការ រៀបចំស្ថិតិអំពើការគ្រប់គ្រងបុគ្គលិក និងតារាងព័តិមានប្រតិបត្តិ
- រៀបចំការងារបៀវត្សពលកម្ម ប្រាក់កម្រៃ និង របបធានារ៉ាប់រងសង្គម
- លើកផែនការការងារទូទៅរយៈពេលខ្លី មធ្យម និង រយៈពេលវែង
- គេហបាល រក្សាសុវត្ថិភាព សន្តិភាព សណ្តាប់ធ្នាប់ក្នុងអង្គភាពទទួលខុសត្រូវលើការងារពិធីការ និងទំនាក់ទំនងសាធារណៈ
- លើកសំណើតម្លើងឋានៈ ថ្នាក់ ដាក់ពិន័យលើកសរសើរ និង ជូនរង្វាន់ដល់មន្ត្រីរាជការក្នុងអង្គភាព
- តាមដានត្រួតពិនិត្យលិខិតបទដ្ឋាន បទបញ្ញត្តិនានាដែលចូលជាធរមាន និងអនុវត្តតាមភារកិច្ច ដែលក្រសួងប្រគល់ឱ្យ
- ប្រមូលផ្តុំតម្រូវការលើកគម្រោងធ្វើកម្មវិធីចំណូល-ចំណាយ និង តាមដានរំលឹកពីការប្រតិបត្តិ
- គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ បរិក្ខា ប្រេងឥន្ធនៈ និងធ្វើបញ្ជីសារពើភ័ណ្ឌរបស់អង្គភាព

- បូកសរុប និងធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំអំពីសកម្មភាព និងលទ្ធផលការងារ ដែលមន្ទីរសម្រេចបាន។

២. ការិយាល័យទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអាជ្ញាធរខេត្ត ដឹកនាំដោយប្រធានមួយរូប និងមន្ត្រីមួយរូបជាជំនួយការធ្វើជាសេនាធិការឱ្យប្រធានមន្ទីរលើការងារៈ

- សម្របសម្រួលទំនាក់ទំនង និងសហការជាមួយអាជ្ញាធរខេត្ត ជាមួយសមាជិករដ្ឋសភា-ព្រឹទ្ធសភាក្នុងមណ្ឌលខេត្តរបស់ខ្លួន
- សិក្សាស្រាវជ្រាវច្បាប់ដែលចូលជាធរមាន និង លិខិតបទដ្ឋានគតិយុត្តិនានារបស់រាជរដ្ឋាភិបាល
- ផ្សព្វផ្សាយច្បាប់ជូនប្រជាពលរដ្ឋក្នុងមណ្ឌលខេត្តរបស់ខ្លួនឱ្យទទួលបានការយល់ដឹង និងប្រតិបត្តិតាម
- ទទួលពាក្យបណ្តឹង ពិនិត្យសមត្ថកិច្ច អង្កេតស្រាវជ្រាវ និងដោះស្រាយឱ្យបានត្រឹមត្រូវតាមថេរវេលាកំណត់
- តាមដានជម្រុញការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ
- ធ្វើរបាយការណ៍អំពីលទ្ធផលការងារទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអាជ្ញាធរខេត្ត។

៣. ការិយាល័យអធិការកិច្ចដឹកនាំដោយប្រធានមួយរូប និងមន្ត្រីមួយរូបជាជំនួយការ ដោយធ្វើជាសេនាធិការឱ្យប្រធានមន្ទីរ លើការងារមួយចំនួនដូចជាៈ

- ក្តាប់សភាពការណ៍ក្នុងមណ្ឌលខេត្តរបស់ខ្លួន លើកផែនការសុំការអនុញ្ញាតពីក្រសួង ដើម្បីធ្វើអធិការកិច្ចលើការងារដឹកនាំ គ្រប់គ្រងចំណូល-ចំណាយថវិកាជាតិក្នុងរង្វង់ដែនដីរបស់ខ្លួន
- ត្រួតពិនិត្យលើការគ្រប់គ្រង បញ្ជីសារភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ
- ពិនិត្យទៅលើអង្គភាពនានា ដែលទទួលការគ្រប់គ្រងប្រើប្រាស់ជំនួយជាតិ និងអន្តរជាតិ។

## ១.២.៣ ស្ថានភាពនៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថាន

ខេត្តព្រះវិហារសម្បូរទៅដោយព្រៃភ្នំ ស្ទឹង បឹង អូរ ធនធានរ៉ែ និងសត្វព្រៃ។ ខេត្តមានតំបន់ការពារធនធានធម្មជាតិចំនួនពាក់ន្លែង គឺដែនជំរកសត្វព្រៃគូលែនព្រហ្មទេព ដែនជំរកសត្វព្រៃបឹងពែរ និងដែនការពារទេសភាពប្រាសាទព្រះវិហារ ដែលមានផ្ទៃដីសរុបទាំងអស់ប្រមាណជាង ៣០០.០០០ហិកតា។ បច្ចុប្បន្នប្រជាពលរដ្ឋអាចប្រកបមុខរបរកសិកម្ម និងពិសេសដោយការបន្លាស់ទីនៃប្រជាពលរដ្ឋពីខេត្តផ្សេងៗ និងកំណើនប្រជាជនផ្ទាល់ក្នុងស្រុកបានធ្វើឱ្យមានបញ្ហាជាច្រើនដូចជាទំនាស់ដីធ្លី ការបំផ្លិចបំផ្លាញព្រៃឈើ និងការបំពុលបរិស្ថានដែលគួរឱ្យព្រួយបារម្ភក្នុងពេលបច្ចុប្បន្ន និងអនាគត។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ អាជ្ញាធរខេត្ត ក៏ដូចជា អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបាន និងកំពុងធ្វើការទប់ស្កាត់តាមរយៈការចុះផ្សព្វផ្សាយច្បាប់ភូមិបាល ច្បាប់ព្រៃឈើ និងកិច្ចការពារបរិស្ថានដល់ប្រជាពលរដ្ឋ។ កន្លងមក ខេត្តបានរៀបចំកំណត់ព្រំប្រទល់តំបន់អភិរក្សសត្វព្រៃ និងរៀបចំឱ្យមានសហគមន៍ព្រៃឈើ ដើម្បីឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានចូលរួមក្នុងការគ្រប់គ្រងការពារព្រៃឈើ និងសម្បត្តិធម្មជាតិផ្សេងៗទៀត។ បញ្ហានៃការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថានគឺជាបញ្ហា

ដ៏ស្មុកស្មាញបំផុត ដែលតម្រូវឱ្យមានការចូលសហការពីគ្រប់ស្ថាប័នពាក់ព័ន្ធ ជាស្ដែងថ្នាក់ជាតិ ជាពិសេសប្រមុខរាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តគោលនយោបាយដីធ្លី" គោលនយោបាយចាស់សកម្មភាពថ្មី" ដោយបានរៀបចំក្រុមយុវជនស្ម័គ្រចិត្តចុះអនុវត្តការផ្ដល់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ដោយមានកិច្ចសហការ និងចូលរួមយ៉ាងសកម្មពីសំណាក់អាជ្ញាធរថ្នាក់ខេត្ត និងមូលដ្ឋាន។

## ១.២.៣.១ វិស័យគ្រប់គ្រងដីធ្លី សុរិយោដី

ដើម្បីឱ្យផែនការអភិវឌ្ឍន៍ ដំណើរការចំគោលដៅ និងមានប្រសិទ្ធិភាព មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ខិតខំប្រឹងប្រែងរិះរកមធ្យោបាយទាំងផ្នែកជំនាញ និងឯកសារសំខាន់ៗដែលតម្រូវដល់ការអនុវត្ត និងរកដៃគូរសម្រាប់គាំទ្រ។ មន្ទីរមានមន្ត្រីបម្រើការងារសរុបចំនួន ២២នាក់ មានការិយាល័យចំណុះចំនួន៣ និងការិយាល័យក្រុង ស្រុកចំនួន៨ ក្នុងនោះមន្ទីរបានបំពេញបេសកម្មមានដូចជា ចុះធ្វើអត្តសញ្ញាណកម្មដីសម្បទានសេដ្ឋកិច្ចចំនួន ២១កន្លែង ស្មើ ១០៣.២០៦ហិកតា ចុះធ្វើអត្តសញ្ញាណកម្មដីសម្បទានសង្គមកិច្ចចំនួន ១១កន្លែង ស្មើ១៨.០៧៤ហិកតា ទទួលពាក្យបណ្ដឹងចំនួន៤២ករណី ដោះស្រាយទំនាស់ដីធ្លីបានចំនួន៤២ករណី ដោះស្រាយបញ្ចប់ចំនួន២១ករណី ច្រានចោលចំនួន១៥ករណី កំពុងដោះស្រាចំនួន០៦ករណី។ ចុះបញ្ជីដីធ្លីជាក់ស្ដែងបានចំនួន ៤៦៩ប័ណ្ណ។ ចុះរៀបចំភូមិធម្មជាតិតេជោហ៊ុន សែនចំនួន០១ភូមិ ស្មើផ្ទៃដីចំនួន ៤.៥២៥ហិកតា។

ទន្ទឹមនេះ មន្ទីរក៏ជួបបញ្ហាប្រឈមផងដែរដូចជា ភាពអនាធិបតេយ្យកាប់ព្រៃឈើយកដី ការសាងសង់សំណង់លើដីចំណីផ្លូវ ប្រជាជនមិនទាន់យល់ច្បាស់អំពីសិទ្ធិក្នុងការកាន់កាប់ដីធ្លីរបស់ខ្លួន មិនបានធ្វើប័ណ្ណសំគាល់សិទ្ធិដីរបស់ខ្លួន ដែរជាមូលហេតុនៃទំនាស់ដីធ្លី។ ក្រុមហ៊ុនដែលសុំដីសម្បទានសេដ្ឋកិច្ចមួយចំនួនមិនទាន់បាន ចុះបញ្ជីដីធ្លី។ ការផ្ទេរ ការលក់ដូរដីធ្លីភាគច្រើនធ្វើលិខិតត្រឹមមេឃុំ សង្កាត់ និងសាខាពន្ធដារប៉ុណ្ណោះ នាំឱ្យបញ្ហាទំនាស់ដីធ្លីកាន់តែកើនឡើង។ ទន្ទឹមនឹងនេះ សមត្ថភាពមន្ត្រីពាក់ព័ន្ធវិស័យដីធ្លីនៅមានកំរិតនៅឡើយ។

ដើម្បីឱ្យដំណើរការនៃការកសាងផែនការ៥ឆ្នាំបានជោគជ័យ មន្ទីរសម្រេចយកអនុក្រឹត្យ សារាចរណែនាំ សេចក្ដីណែនាំប្រកាសលេខ ៧៦ប្រក/ដនស ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ ស្ដីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធរបស់មន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងតួនាទីរបស់ការិយាល័យក្រោមឱវាទមកអនុវត្ត ដោយមានការសហការជាមួយស្ថាប័នពាក់ព័ន្ធនានា ដូចជា អង្គភាពរដ្ឋបាលព្រៃឈើ មន្ទីរបរិស្ថាន មន្ទីរកសិកម្ម កងកម្លាំងប្រដាប់អាវុធទាំងបីប្រភេទ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ ព្រមទាំងអង្គការជាតិ និងអន្តរជាតិ។

## ១.២.៣.២ វិស័យបរិស្ថាន គ្រប់គ្រងធនធានធម្មជាតិ

បច្ចុប្បន្ន ថ្នាំពុលកសិកម្មសម្រាប់សំលាប់សត្វល្អិត និងជីគីមីកំពុងត្រូវបានប្រើប្រាស់យ៉ាងច្រើននៅក្នុងខេត្តព្រះវិហារសម្រាប់វិស័យកសិកសិកម្ម។ ការប្រើប្រាស់ថ្នាំពុលកសិកម្ម និងជីគីមីនេះ បានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន និងសុខភាពប្រជាពលរដ្ឋ។ ដើម្បីរក្សាលំនឹងបរិស្ថានឱ្យបានល្អបន្តទៀតនោះ មន្ទីរបរិស្ថានរួមជាមួយមន្ទីរកសិកម្ម រដ្ឋបាលព្រៃឈើ និងគ្រប់ស្ថាប័នទាំងអស់ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលបានធ្វើការផ្សព្វផ្សាយ

អំពីផលប៉ះពាល់ និងវិធានការការពារបរិស្ថានដល់ប្រជាពលរដ្ឋ ដើម្បីធ្វើយ៉ាងណាឱ្យពួកគាត់បានយល់ច្បាស់ពីតម្លៃបរិស្ថាន និងការការពារសុខភាព។ ការចងក្រងបង្កើតសហគមន៍ព្រៃឈើ មានការចូលរួមពីស្ត្រីយ៉ាងច្រើនកុះករ គឺជិតស្មើនិងបុរសដែរ ដែលជួយដល់ជីវភាពប្រជាពលរដ្ឋរស់នៅកាន់តែប្រសើរឡើង។

ពាក់ព័ន្ធវិស័យបរិស្ថាន ប្រជាពលរដ្ឋខេត្តព្រះវិហារ ជួបបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម :

- ភាពអនាធិបតេយ្យការកាប់បំផ្លាញព្រៃឈើ ការយកដីធ្វើជាកម្មសិទ្ធិ និងការបរបាញ់សត្វព្រៃជាដើមនៅតែមាន ដោយសារប្រជាជនមិនទាន់យល់អំពីច្បាប់បរិស្ថាន ច្បាប់តំបន់ការពារធម្មជាតិ ឬក៏ច្បាប់ផ្សេងៗទៀត។
- **ការប្រើប្រាស់ជីគីមី** សម្រាប់វិស័យកសិកម្មមិនទាន់ត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ដោយសារការយល់ដឹងរបស់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់ជីគីមីនូវមានកំរិត។
- **ការប្រើប្រាស់ថ្នាំពុល**បណ្ដាលឱ្យមានផលប៉ះពាល់លើសុខភាពមនុស្ស និងសត្វ។ ថ្នាំកសិកម្មបានជ្រាបចូលក្នុងខ្លួនមនុស្សតាមរយៈអាហារ ទឹកផឹក ការដកដង្ហើម និងតាមរយៈស្បែក ដែលបណ្ដាលមកពីខ្វះការយល់ដឹងអំពីវិធីសាស្ត្រប្រើប្រាស់ថ្នាំពុលទាំងនោះ។
- **បម្រែបម្រួលអាកាសធាតុ** កើតឡើងដោយសារសកម្មភាពរបស់មនុស្ស ដូចជា ការកាប់បំផ្លាញព្រៃឈើ ឈូសឆាយដីភ្នំ ការរុករករ៉ែ និងសំណល់នៃរោងចក្រឧស្សាហកម្មធំៗជាដើម។ ឥទ្ធិពលនៃបម្រែបម្រួលអាកាសធាតុបានបណ្ដាលឱ្យមានគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ភ្លៀងខុសរដូវ ខ្យល់ព្យុះ និងការឡើងនៃកំដៅជាដើម។

*តារាង* ៖ ចំនួនគ្រួសារដែលពាក់ព័ន្ធនឹងបរិស្ថាន (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| បរិយាយ | 2009 | 2010 | 2011 |
|---|---|---|---|
| សរុបចំនួនគ្រួសារដែលរស់នៅក្នុងតំបន់ការពារឬអភិរក្ស | 2,394 | 3,875 | 3,857 |
| សរុបចំនួនគ្រួសារមានសេវាប្រមូលសំរាមតាមផ្ទះ | 287 | 492 | 370 |
| សរុបចំនួនគ្រួសារដែលទទួលរងផលប៉ះពាល់ពីការបំពុលបរិស្ថាន | 114 | 19 | 16 |
| %គ្រួសារប្រើប្រាស់ជីគីមី | 1.15 | 3.96 | 2.17 |
| %គ្រួសារប្រើប្រាស់ជីសរីរាង្គ | | | 8.02 |
| %គ្រួសារប្រើប្រាស់ថ្នាំគីមីសំលាប់សត្វល្អិត ស្មៅ | 1.11 | 1.75 | 4.86 |
| %គ្រួសារប្រើប្រាស់ថ្នាំសរីរាង្គសំលាប់សត្វល្អិត ស្មៅ | | | 0.78 |

ក្រាហ្វិក ៖ ភាគរយគ្រួសារប្រើជីគីមីនិងជីសរីរាង្គ



ក្រាហ្វិក ៖ ភាគរយគ្រួសារប្រើថ្នាំគីមីនិងថ្នាំសរីរាង្គ




### ១.២.៣.៣ វិស័យរដ្ឋបាលព្រៃឈើ

វិស័យព្រៃឈើនៅក្នុងខេត្តព្រះវិហារបានផ្តល់នូវធនធានព្រៃឈើ (ផលអនុផលព្រៃឈើ) សម្រាប់ដោះស្រាយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងខេត្តព្រះវិហារ ហើយអាចនាំចេញទៅក្រៅប្រទេសទៀតផង។ ទន្ទឹមនឹងនេះ ខណ្ឌរដ្ឋបាលព្រៃឈើខេត្តព្រះវិហារបានខិតខំអនុវត្តសកម្មភាពគ្រប់គ្រងធនធានព្រៃឈើ តាមរយៈការបង្កើតសហគមន៍ព្រៃឈើ ការដាំឈើឡើងវិញ និងពង្រឹងការអនុវត្តច្បាប់ ដោយសហការជាមួយអាជ្ញាធរបានធ្វើការផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងព្រៃឈើ ហើយអនុវត្តការងារទប់ស្កាត់បទល្មើសព្រៃឈើជាប្រចាំ។

**បញ្ហាជួបប្រទះក្នុងខណ្ឌរដ្ឋបាលព្រៃឈើ**

- ខ្វះមន្ត្រីសម្រាប់ បំរើការងារក្នុងខណ្ឌ ផ្នែក សង្កាត់រដ្ឋបាលព្រៃឈើ
- ពុំមានស្នាក់ការគ្រប់គ្រាន់សំរាប់បំរើការងារ
- ពុំមានកញ្ចប់ថវិកាសំរាប់ ដំណើរការសកម្មភាពដូចមន្ទីរផ្សេងៗ
- ការយល់ដឹងអំពីច្បាប់ស្តីអំពីព្រៃឈើរបស់ប្រជាពលរដ្ឋនៅមានកំរិត
- ការទន្ទ្រានយកដីព្រៃធ្វើជាកម្មសិទ្ធិ

**វិធីសាស្ត្ររបស់ខណ្ឌរដ្ឋបាលព្រៃឈើ**

- បណ្តុះបណ្តាលមន្ត្រីជំនាញ ដើម្បីបង្កើនសមត្ថភាព
- ជួលស្នាក់ការសំរាប់បំរើការងារ
- ស្នើសុំជំនួយពីអង្គការដៃគូសំរាប់អភិវឌ្ឍន៍វិស័យព្រៃឈើ
- រៀបចំគំរោងសំណើផ្សេងៗដាក់បញ្ចូលក្នុងផែនការថ្នាក់ជាតិ ក្នុងគោលបំណងជួយទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមូលដ្ឋាន។
- ផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា
- ធ្វើនិយ័តកម្មសហគមន៍ព្រៃឈើ និងរៀបចំសហគមន៍ព្រៃឈើបន្តទៀត
- ដាំឈើឡើងវិញ និង
- កំណត់ព្រំប្រទល់ព្រៃឈើ(បោះបង្គោលព្រំ) និងចុះបញ្ជីការ

### ១.២.៣.៤ ការបោសសំអាតមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ

វិស័យសកម្មភាពមីន មានលក្ខណៈជាប្រពន្ធ័ និងជាវិស័យអាទិភាពមួយត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលក្នុងគោលដៅទី៩នៃគោលដៅអភិវឌ្ឍសហវត្សរិកម្ពុជា។ វិស័យនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងសេដ្ឋកិច្ចសង្គម លើកកំពស់ជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ និងរួមចំណែកយ៉ាងសកម្មដល់កិច្ចអភិវឌ្ឍទិនៅតាមមូលដ្ឋានភូមិ ឃុំដែលមានតំបន់មីន។ វិស័យសកម្មភាពមីនរួមចំណែកយ៉ាងសំខាន់មួយទៀតគឺ កាត់បន្ថយគ្រោះថ្នាក់របស់ប្រជាពលរដ្ឋដែលស្ថិតនៅលើតំបន់មានមីន នឹងគ្រាប់មិនទាន់ផ្ទុះ។

បច្ចុប្បន្ននេះ ការបោសសម្អាតមីននៅខេត្តព្រះវិហារទទួលបានជោគជ័យយ៉ាងធំធេង។ ថ្វីបើយើង សម្រេចបានសមិទ្ធិផលជាច្រើនរួមទាំងបានផ្តល់ផ្ទៃដីបោសសម្អាតមីនរាប់រយហិកតា ដើម្បីស្តារនិងកសាង ឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធសង្គម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបានកាត់បន្ថយគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ យ៉ាងណាក្តី ក៏បញ្ហាមីន និងសំណល់ជាតិផ្ទុះពីសង្រ្គាម(ស.ផ.ស.) នៅតែបន្តបង្កគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ និងរាំងស្ទះដល់ការអភិវឌ្ឍខេត្តនៅឡើយ។

ក្រុមការងារផែនការសកម្មភាពកំចាត់មីនខេត្តមានផែនការសម្រាប់ឆ្នាំ២០១៣ តម្រូវឱ្យធ្វើការបោសសម្អាតមីនជាចាំបាច់ក្នុងឃុំចំនួន១៣ដែលទាក់ទងជាមួយស្រុកទាំង៦បន្តទៀត និងត្រូវការថវិកាជាច្រើន ដើម្បីគាំទ្រកិច្ចការនេះ។

ជារៀងរាល់ឆ្នាំ យើងមានផែនកាបោសសំអាតជាបន្តបន្ទាប់តំបន់មានមីន និងគ្រាប់មិនទាន់ផ្ទុះក្នុងភូមិសាស្ត្រខេត្តព្រះវិហារ។ ជាក់ស្តែងក្នុងឆ្នាំ២០១២កន្លងទៅនេះ អង្គភាពបានធ្វើការបោសសំអាតមីនបានចំនួនសរុប២៦ចំការមីន ដែលអនុវត្តដោយស៊ីម៉ាក ២៤ចំការមីន និងអង្គការដោះមីនកម្ពុជាចំនួន០២ចំការមីន ស្មើនឹងផ្ទៃដីសរុបចំនួន១១៥,៧៥ហិកតា។

ដើម្បីរួមចំណែកអនុវត្ត គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម និងផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីនឱ្យទទួលបានជោគជ័យ តម្រូវឱ្យមានការចូលរួមយ៉ាងសកម្មពីស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ប្រតិបត្តិករបោសសម្អាតមីន ដៃគូអភិវឌ្ឍន៍ និងសហគមន៍អ្នកទទួលផល។ ការបោសសម្អាតមីនត្រូវតែអនុវត្តលើតំបន់មានមីន ដែលបានស្រាវជ្រាវច្បាស់លាស់។

តារាង ៖ មីននិងសំណល់ជាតិផ្ទុះពីសង្រ្គាម (ប្រភពទិន្នន័យភូមិឆ្នាំ២០១១)

| បរិយាយ | 2009 | 2010 | 2011 |
|---|---|---|---|
| ចំនួនករណីផ្ទុះមីនសល់ពីសង្រ្គាមក្នុងឆ្នាំ | | | 6 |
| ចំនួនអ្នកស្លាប់ដោយសារការផ្ទុះមីនសល់ពីសង្រ្គាម | | | 2 |
| %អ្នកស្លាប់អាយុក្រោម១៨ឆ្នាំដោយសារការផ្ទុះមីន | | | 0.00 |
| ចំនួនជនរងរបួសដោយសារការផ្ទុះមីនសល់ពីសង្រ្គាម | | | 7 |
| %អ្នករងរបួសអាយុក្រោម១៨ឆ្នាំដោយសារការផ្ទុះមីន | | | 0.00 |
| ចំនួនករណីផ្ទុះសំណល់ជាតិផ្ទុះពីសង្រ្គាម | | | 8 |

| | | | |
|---|---|---|---|
| ចំនួនអ្នកស្លាប់ដោយសារផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម | | | 3 |
| %អ្នកស្លាប់អាយុក្រោម១៨ឆ្នាំដោយសារផ្ទុះសំណល់ជាតិផ្ទុះ | | | 33.33 |
| ចំនួនអ្នករងរបួសដោយសារផ្ទុះសំណល់ជាតិផ្ទុះពីសង្គ្រាម | | | 16 |
| %អ្នករបួសអាយុក្រោម១៨ឆ្នាំដោយសារផ្ទុះសំណល់ជាតិផ្ទុះ | | | 31.25 |
| ចំនួនផ្ទៃដីដែលបានសំអាតមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម | | | 185 |
| ចំនួនគ្រួសារទទួលបានដីសំអាតមីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាម | | | 0 |

## ១.២.៤ ស្ថានភាពនៃការគ្រប់គ្រងគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

ខេត្តព្រះវិហារក៏ដូចជាខេត្តមួយចំនួននៃព្រះរាជាណាចក្រកម្ពុជាដែលធ្លាប់បានរងគ្រោះដោយគ្រោះមហន្តរាយធម្ម-ជាតិផ្សេងៗ ពិសេស គ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។ ព្រោះខេត្តមានភូមិសាស្ត្រស្ថិតនៅតំបន់ខ្ពង់រាបមានជួរភ្នំ ទន្លេ ស្ទឹង អូរ ដែលអាចទទួលឥទ្ធិពលពីទឹកជំនន់ដោយសារទឹកភ្លៀង ខ្យល់ព្យុះ ដែលបង្កឱ្យមានការខូចខាតផ្ទះសំបែង ទ្រព្យសម្បត្តិ សត្វពាហនៈ ផលដំណាំ ស្រែ ចំការ។ល។ ខេត្តក៏ទទួលរងនូវគ្រោះរាំងស្ងួតជាញឹកញាប់ផងដែរ ព្រោះប្រព័ន្ធធារាសាស្ត្រនៅមានកំរិតដែលមិនមានលទ្ធភាពផ្គត់ផ្គង់ទឹកគ្រប់គ្រាន់ សម្រាប់ប្រើប្រាស់ ក្នុងការស្រោចស្រពដំណាំកសិកម្ម។

ឥទ្ធិពលនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុបានធ្វើឱ្យផលិតផលកសិកម្មទទួលបានទិន្នផលទាប និងប៉ះពាល់ដល់ជីវិតសត្វ មនុស្ស និងទ្រព្យសម្បត្តិផ្សេងៗទៀតរបស់ប្រជាពលរដ្ឋ ជាហេតុធ្វើឱ្យមានការខាតបង់ធនធាន (ថវិកា សម្ភារៈ មនុស្ស) និងខាតបង់ពេលវេលាជាច្រើន ក្នុងការដោះស្រាយ។ គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត អាជ្ញាធរខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរធនធានទឹក និងឧតុនិយម មន្ទីរកសិកម្ម និងមន្ទីរអង្គភាពពាក់ព័ន្ធនានាគ្រប់លំដាប់ថ្នាក់ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋគ្រប់មូលដ្ឋាន ដើម្បីត្រៀមខ្លួនទប់ទល់ និងដោះស្រាយពេលមានបញ្ហាកើតឡើង។ ក្នុងន័យនេះ ប្រជាពលរដ្ឋត្រូវត្រៀមជាមុននូវសំល្បៀកបំពាក់ សម្ភារៈ ស្បៀង អាហារ ការសាងសង់លំនៅដ្ឋានឱ្យសមស្របមនឹងស្ថានភាពជាក់ស្តែង។ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រៀមសម្ភារៈ បរិក្ខារ ស្បៀងអាហារសម្រាប់ផ្គត់ផ្គង់ និងទីតាំងសុវត្ថិភាពសម្រាប់ជំលៀសប្រជាពលរដ្ឋផងដែរ។

*តារាង ៖* ផលប៉ះពាល់ *(ប្រភពទិន្នន័យភូមិឆ្នាំ២០១១)*

| បរិយាយ | 2009 | 2010 | 2011 |
|---|---|---|---|
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ | | | 1,722 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីទឹកជំនន់ | | | 7,115 |
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីព្យុះ | | | 12 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីព្យុះ | | | 44 |
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះរាំងស្ងួត | | | 286 |
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះរាំងស្ងួត | | | 919 |
| ចំនួនគ្រួសារទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះអគ្គិភ័យ | | | 31 |

| | | | |
|---|---|---|---|
| ចំនួនមនុស្សទទួលការប៉ះពាល់ធ្ងន់ធ្ងរពីគ្រោះអគ្គិភ័យ | | | 129 |

តារាង ៖ ស្លាប់ដោយគ្រោះធម្មជាតិ *(ប្រភពទិន្នន័យភូមិឆ្នាំ២០១១)*

| បរិយាយ | 2009 | 2010 | 2011 |
|---|---|---|---|
| ចំនួនអ្នកស្លាប់បណ្តាលមកពីគ្រោះទឹកជំនន់ | | | 7 |
| ចំនួនអ្នកស្លាប់បណ្តាលមកពីគ្រោះទឹកជំនន់អាយុក្រោម១៨ឆ្នាំ | | | 4 |
| ស្ត្រីស្លាប់បណ្តាលមកពីគ្រោះទឹកជំនន់អាយុក្រោម១៨ឆ្នាំ | | | 1 |
| ចំនួនអ្នកស្លាប់បណ្តាលមកពីខ្យល់ព្យុះ | | | 1 |
| ចំនួនអ្នកស្លាប់បណ្តាលមកពីខ្យល់ព្យុះអាយុក្រោម១៨ឆ្នាំ | | | 0 |
| ស្ត្រីស្លាប់បណ្តាលមកពីខ្យល់ព្យុះអាយុក្រោម១៨ឆ្នាំ | | | 0 |
| ចំនួនអ្នកស្លាប់បណ្តាលមកពីរន្ទះ | | | 1 |
| ចំនួនអ្នកស្លាប់បណ្តាលមកពីរន្ទះអាយុក្រោម១៨ឆ្នាំ | | | 0 |
| ស្ត្រីស្លាប់បណ្តាលមកពីរន្ទះអាយុក្រោម១៨ឆ្នាំ | | | 0 |

ក្រាហ្វិក ៖ ចំនួនអ្នកស្លាប់បណ្តាលមកពីគ្រោះទឹកជំនន់




ក្រាហ្វិក ៖ ចំនួនអ្នកស្លាប់បណ្តាលមកពីខ្យល់ព្យុះនិងរន្ទះ




### ១.២.៥ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាល និងសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

| ១ | បណ្តុះបណ្តាលជំនាញមុខវិជ្ជាជីវៈដល់ស្ត្រីតាមតម្រូវការរបស់ស្ត្រី | | ទីរួមខេត្ត | ៤វគ្គ | AFida | មន្ទីរកិច្ចការនារី | ៩ខែ ២០១៣-២០១៥ | ៤០នាក់ | ៤០នាក់ | 21.96 | 21.96 | 21.96 | 65.88 |
| ២ | បណ្តុះបណ្តាលវិជ្ជាជីវៈកាត់ដេរ | | ទីរួមខេត្ត | ៦វគ្គ | ក្រសួងកិច្ចការនារី | មន្ទីរកិច្ចការនារី | ១៨ខែ ២០១៣-២០១៥ | ២៥នាក់ | ២៥នាក់ | 43.20 | 43.20 | 43.20 | 129.60 |
| ៣ | បណ្តុះបណ្តាលវិជ្ជាជីវៈតម្បាញ | | ទីរួមខេត្ត | ៦វគ្គ | ក្រសួងកិច្ចការនារី | មន្ទីរកិច្ចការនារី | ១៨ខែ ២០១២-២០១៤ | ២៥នាក់ | ២៥នាក់ | 28.80 | 28.80 | 28.80 | 86.40 |
| ៤ | ប្រជុំជាមួយភាគីពាក់ព័ន្ធស្តីពីវិភាគយេនឌ័រក្នុងគំរោងប្រចាំឆ្នាំ | | ទីរួមខេត្ត | ៦វគ្គ | IFAD | មន្ទីរកិច្ចការនារី | ៣ថ្ងៃ ២០១៣-២០១៥ | ៣៧នាក់ | ២៧នាក់ | 5.88 | 5.88 | 5.88 | 17.64 |
| ៦ | ចុះជ្រើសរើសកសិករគំរូ | | ៣ឃុំ គោលដៅ | ៣វគ្គ | IFAD | មន្ទីរកិច្ចការនារី | ៩ថ្ងៃ ២០១៣-២០១៥ | ៣៣នាក់ | ៣៣នាក់ | 2.20 | 2.20 | 2.20 | 6.60 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ៦ | វេទិកាជាមួយស្ត្រីថ្នាក់ដឹកនាំខេត្ត ស្រុក ក្រុងប្រឹក្សាឃុំជាជនបង្គោលស្ត្រី-កុមារ | | ខេត្ត ស្រុក ក្រុង | ២៧ | PI3 | មន្ទីរកិច្ចការនារី | ៣៦ថ្ងៃ ២០១៣-២០១៥ | ១.០៨០ | ៦៥០ | 5.50 | 5.50 | 5.50 | 16.50 |
| ៧ | ប្រជុំប្រចាំខែ ត្រីមាសី ឆមាស ជាមួយបណ្តាញយេនឌ័រខេត្ត ស្រុក ក្រុង | | ខេត្ត ស្រុក ក្រុង | ១២ | PI3 | មន្ទីរកិច្ចការនារី | ១២ថ្ងៃ ២០១៣-២០១៥ | ៣៦០ | ២៦០ | 2.60 | 2.60 | 2.60 | 7.80 |
| ៨ | ចុះត្រួតពិនិត្យសកម្មភាពយេនឌ័រ នៅតាមស្រុក និង ឃុំ | | ខេត្ត ស្រុក ក្រុង | ៣៦ | PI3 | មន្ទីរកិច្ចការនារី | ៣៦ថ្ងៃ ២០១៣-២០១៥ | ៧២នាក់ | ៤៨នាក់ | 2.20 | 2.20 | 2.20 | 6.60 |
| **សរុបរង** | | | | | | | | | | **112.34** | **112.34** | **112.34** | **337.02** |
| **២.៨ ក្រុមការងារផែនការសកម្មភាពកំចាត់មីន** | | | | | | | | | | | | | |
| ១ | ការប្រជុំឃុំរៀបចំផែនការដោះមីន | ២.៨.១៩ | យាង.ជាំក្សាន្ត.រមណី. រស្មី.កំពង់ស្រឡៅ១. ម្លូព្រៃមួយ.សង្កែមួយ. | ២៥ លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 1.70 | 1.70 | 1.70 | 5.10 |
| ២ | ចុះអង្កេតចំការមីនបន្ទាន់ | ២.៨.១៩ | យាង.ជាំក្សាន្ត.រមណី. រស្មី.កំពង់ស្រឡៅ១. ម្លូព្រៃមួយ.សង្កែមួយ. | ១៨០ កន្លែង | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 1.30 | 1.30 | 1.30 | 3.90 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ៣ | ត្រួតពិនិត្យការគ្រប់គ្រង់ប្រើប្រាស់ដីដោះមីនរួច | ២.៨.២០ | ឃុំកន្ទួត.ទឹកក្រហម.<br>យាង.ជាំក្សាន្ត.រមណី.<br>រស្មី.កំពង់ស្រឡៅ១.<br>ម្លូព្រៃមួយ.សង្កែមួយ.<br>ពុទ្រា.ស្រយ៉ង់.<br>ភ្នំត្បែងពីរ.រណសិរ្ស | ១៣៨ លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 1.00 | 1.00 | 1.00 | 3.00 |
| ៤ | សិក្ខាសាលាអនុម័តថ្នាក់ខេត្ត | ២.៨.១៩ | សាលប្រជុំ<br>សាលាខេត្ត | ៣ លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 360 | 160 | 1.90 | 1.90 | 1.90 | 5.70 |
| ៥ | ការចុះអង្កេតចំការមីន និងធ្វើបញ្ជីអ្នកទទួលផល | ២.៨.១៩ | យាង.ជាំក្សាន្ត.រមណី.<br>រស្មី.កំពង់ស្រឡៅ១.<br>ម្លូព្រៃមួយ.សង្កែមួយ. | ៦២៤ កន្លែង | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 4.96 | 4.96 | 4.96 | 14.88 |
| ៦ | ប្រជុំភីម៉ាកប្រចាំត្រីមាស | ២.៨.២០ | សាលប្រជុំ<br>សាលាខេត្ត | ៩ កន្លែង | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 3.60 | 3.60 | 3.60 | 10.80 |
| ៧ | សិក្ខាសាលាចំការមីនអនុម័តថ្នាក់ស្រុក | ២.៨.១៩ | ស្រុកជាំក្សាន្ត.សង្គមថ្មី<br>.ឆែប.ជ័យសែន<br>.រវៀង.គូលែន | ១៨ លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 630 | 150 | 8.20 | 8.20 | 8.20 | 24.60 |
| ៨ | តាមដានការអនុវត្តទីការដោះមីន | ២.៨.២០ | យាង.ជាំក្សាន្ត.រមណី.<br>រស្មី.កំពង់ស្រឡៅ១.<br>ម្លូព្រៃមួយ.សង្កែមួយ. | ១១៧ លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 7.50 | 7.50 | 7.50 | 22.50 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ៩ | ការផ្ទេរប្រគល់ដីដោះមីនរួច | ២.៧.២០ | យាង.ជាំក្សាន្ត.រមណី.រស្មី.កំពង់ស្រឡៅ១.ម្លូព្រៃមួយ.សង្កែមួយ. | ១៥៦ លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 6.60 | 6.60 | 6.60 | 19.80 |
| ១០ | ប្រជុំឃុំបញ្ចូលផែនការសកម្មភាពមីនក្នុង CIP | ២.៨.១៩ | យាង.ជាំក្សាន្ត.រមណី.រស្មី.កំពង់ស្រឡៅ១.ម្លូព្រៃមួយ.សង្កែមួយ. | ៣៩លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 1.70 | 1.70 | 1.70 | 5.10 |
| ១១ | ចូលរួមសមាហរណកម្មផែនការថ្នាក់ស្រុក-ក្រុង | ២.៨.១៩ | ៨ក្រុង-ស្រុក | ២៤លើក | អាជ្ញាធរមីន (CMAA) | ម៉ាពូ | ២០១៣-២០១៥ | 9016 | 4600 | 1.70 | 1.70 | 1.70 | 5.10 |
| **សរុបរង** | | | | | | | | | | **40.16** | **40.16** | **40.16** | **120.48** |
| **២.៩ អេច ភី អេ (HPA)** | | | | | | | | | | | | | |
| ១ | ប្រជុំប្រាំខែរបស់ ក្រុមទ្រទ្រង់សុខភាពភូមិ នៅតាមភូមិគោលដៅទាំង ៥៩ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដល់កុមារនិង មាតា | ៧ស្រុកនិងក្រុង | ៦ដង | គំរោងសហគមន៍អឺរ៉ុប | អង្គការ អេច ភី អេ និង ក្រុមទ្រទ្រង់សុខភាពភូមិ | ២០១៣ | ៣៥៤ | | 31,152.00 | | | 31,152.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ២ | ប្រជុំប្រចាំត្រីមាស របស់គណៈកម្មការគ្រប់គ្រងមណ្ឌល សុខភាព | កាត់បន្ថយអត្រាឈឺនិងស្លាប់ដល់កុមារនិង មាតា | ១២មណ្ឌលសុខភាព | ២ដង | គំរោងសហគមន៍អឺរ៉ុប | អង្គការ អេច ភី អេ និងមណ្ឌលសុខភាព | ២០១៣ | | | 9,720.00 | | | 9,720.00 |
| ៣ | សកម្មភាពអប់រំដល់ឃុំគោលដៅតាមរយៈការបញ្ចាំង វីដេអូចល័ត | កាត់បន្ថយអត្រាឈឺនិងស្លាប់ដល់កុមារនិង មាតា | ៧ស្រុកនិងក្រុង | ៣ដង | គំរោងសហគមន៍អឺរ៉ុប | អង្គការ អេច ភី អេ | ២០១៣ | | | 33,810.00 | | | 33,810.00 |
| ៤ | ការប្រជុំប្រចាំត្រីមាស របស់សម្ព័ន្ធឆ្មបបុរាណ និងមណ្ឌលសុខភាព ទាំង១២មណ្ឌល សំរបសំរួលដោយមន្ត្រី អេច ភី អេ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដល់កុមារនិង មាតា | ១២មណ្ឌលសុខភាព | ២ដង | គំរោងសហគមន៍អឺរ៉ុប | អង្គការ អេច ភី អេ និងមណ្ឌលសុខភាព | ២០១៣ | ១២៥ | ១២៥ | 13,448.00 | | | 13,448.00 |
| ៥ | សិក្ខាសាលាផ្សព្វផ្សាយការពង្រីកតំបន់ប្រតិបត្តិដូតសីសហគមន៏ដល់ដៃគូរពាក់ព័ន្ធ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជំងឺរបេង | មន្ទីរសុខាភិបាលខេត្ត | ១ វគ្គ | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣ | ២០ នាក់/ឆ្នាំ | ២០ នាក់/ឆ្នាំ | 2,400.00 | | | 2,400.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ៦ | ចុះជ្រើសរើសភ្នាក់ងារដូតស៍សហគមន៍ពង្រីកគោលដៅ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដោយជំងឺរបេង | ៥០ ភូមិ | ១ វគ្គ/ឆ្នាំ | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣ | ៥០ នាក់ | ៥០ នាក់ | 1,270.00 | | | 1,270.00 |
| ៧ | បណ្តុះបណ្តាលភ្នាក់ងារដូតស៍សហគមន៍ពង្រីកគោលដៅ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដោយជំងឺរបេង | ៥១ ភូមិ | ១វគ្គ | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣ | ៥០ នាក់ | ៥០ នាក់ | 5,280.00 | | | 5,280.00 |
| ៨ | ចុះអភិបាលការងាររបេងដូតស៍សហគមន៍ តាមភូមិគោលដៅ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដោយជំងឺរបេង | ២៥០ ភូមិ/ ១៦ មណ្ឌលសុខភាព | ៥០០ ភុមិ (២ ដង / ភូមិ) | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣-២០១៤ | ៥០០ នាក់ | ៥០០ នាក់ | 9,760.00 | 2,440.00 | | 12,200.00 |
| ៩ | ដំណើរការប្រជុំប្រចាំត្រីមាសដូតស៍សហគមន៍ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដោយជំងឺរបេង | ១៦ មណ្ឌ សុខភាព | ២៥០ ភូមិ (៥០ភូម/ត្រីមាស) | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣-២០១៤ | ២៥០នាក់ | ២៥០ នាក់ | 8,860.00 | 2,220.00 | | 11,080.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ១០ | វាយតំលៃលទ្ធផលគំរោងប្រចាំឆ្នាំ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដោយជំងឺរបេង | ១៦ មណ្ឌសុខភាព | ១ ដង /ឆ្នាំ | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣-២០១៤ | ១០០ នាក់ | ១០០ នាក់ | 2,400.00 | 2,400.00 | | 4,800.00 |
| ១១ | ស្រាវជ្រាវរបេងករណីថ្មី និងការព្យាបាលដោយដូតសីសហគមន៍ | កាត់បន្ថយអត្រាឈឺនិងស្លាប់ដោយជំងឺរបេង | ១៦ មណ្ឌសុខភាព | ១៧៥០ នាក់ | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣-២០១៤ | ៨៧៥ នាក់ | ៨៧៥ នាក់ | 14,770.00 | 3,690.00 | | 18,460.00 |
| ១២ | បណ្តុះបណ្តាលសមត្ថភាពបុគ្គលិកគំរោង | កាត់បន្ថយអត្រាឈឺនិងស្លាប់ដោយជំងឺរបេង | អេច ភី អេ ព្រះវិហារ | ៦ នាក់ | គំរោងមូលនិធិសកលទី៧ | អង្គការ HPA | ២០១៣ | ៤ | ២ | 5,600.00 | | | 5,600.00 |
| ១៣ | ជ្រើសរើសក្រុមតស៊ូមតិគ្រុនចាញ់សហគមន៍ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ៥០ ភូមិ | ១ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និង មណ្ឌលសុខភាព | ២០១៣-២០១៥ | ១០០ | ៥០ | 3,520.00 | 3,520.00 | 3,520.00 | 10,560.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ១៤ | បណ្តុះបណ្តាល ក្រុមតស៊ូមតិគ្រុនចាញ់សហគមន៍ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ៥០ ភូមិ | ១ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងមណ្ឌលសុខភាព | ២០១៣-២០១៥ | ១០០ | ៥០ | 7,920.00 | 7,920.00 | 7,920.00 | 23,760.00 |
| ១៥ | ប្រជុំក្រុមក្រុមតស៊ូមតិគ្រុនចាញ់សហគមន៍ ប្រចាំត្រីមាសស្តីពីជំងឺគ្រុនចាញ់ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ៥០ ភូមិ | ៤ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងមណ្ឌលសុខភាព | ២០១៣-២០១៥ | ១០០ | ៥០ | 13,715.39 | 13,715.39 | 13,715.39 | 41,146.18 |
| ១៦ | គាំទ្រក្រុមតស៊ូមតិគ្រុនចាញ់ សហគមន៍សកម្មភាពអប់រំ ផ្សព្វផ្សាយជំងឺគ្រុនចាញ់ ប្រចាំត្រីមាស | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ៥០ ភូមិ | ៤ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងក្រុមតស៊ូមតិគ្រុនចាញ់សហគមន៍ | ២០១៣-២០១៥ | ១០០ | ៥០ | 4,960.00 | 4,960.00 | 4,960.00 | 14,880.00 |
| ១៧ | គាំទ្រអ្នកស្ម័គ្រចិត្តភូមិអប់រំ ផ្សព្វផ្សាយជំងឺគ្រុនចាញ់ ប្រចាំត្រីមាស | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ២២៥ ភូមិ | ៤ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងអ្នកស្ម័គ្រចិត្តភូមិ | ២០១៣-២០១៥ | ៤៥០ | ២២៥ | 19,897.34 | 19,897.34 | 19,897.34 | 59,692.03 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ១៨ | អភិបាលអ្នកស្ម័គ្រចិត្តភូមិ ស្តីពីការអប់រំសុខភាព និង ការប្រើប្រាស់មុងជ្រលក់ថ្នាំ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ៥០ ភូមិ | ៤ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងអ្នកស្ម័គ្រចិត្តភូមិ | ២០១៣-២០១៥ | ១០០ | ៥០ | 6,800.00 | 6,800.00 | 6,800.00 | 20,400.00 |
| ១៩ | យុទ្ធនាការផ្សព្វផ្សាយការយល់ដឹងឱសថក្លែងក្លាយ ដែលមានភាព សាំនឹងជំងឺគ្រុនចាញ់ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ៣ ភូមិ | ១ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងមណ្ឌលសុខភាព | ២០១៣-២០១៥ | ៤០០ | ២៥០ | 4,160.00 | 4,160.00 | 4,160.00 | 12,480.00 |
| ២០ | ជ្រើសរើសឆ្មបបូរាណ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ២៩ ភូមិ | ១ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងមណ្ឌលសុខភាព | ២០១៣-២០១៥ | ៥០ | ៥០ | 1,600.00 | 1,600.00 | 1,600.00 | 4,800.00 |
| ២១ | បណ្តុះបណ្តាលឆ្មបបូរាណ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ២៩ ភូមិ | ១ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និងមណ្ឌលសុខភាព | ២០១៣-២០១៥ | ៥០ | ៥០ | 5,458.00 | 5,458.00 | 5,458.00 | 16,374.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ២២ | ប្រជុំប្រចាំឆមាស ដល់ឆ្មបបូរាណ ស្តីពីជំងឺគ្រុនចាញ់ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ២៥ ភូមិ | ៤ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និង ឆ្មបបូរាណ | ២០១៣-២០១៥ | ៥០ | ៥០ | 4,576.00 | 4,576.00 | 4,576.00 | 13,728.00 |
| ២៣ | គាំទ្រឆ្មបបូរាណ អប់រំផ្សព្វផ្សាយជំងឺគ្រុនចាញ់ ប្រចាំត្រីមាស | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ២៥ ភូមិ | ៤ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និង ឆ្មបបូរាណ | ២០១៣-២០១៥ | ៥០ | ៥០ | 2,183.68 | 2,183.68 | 2,183.68 | 6,551.04 |
| ២៤ | សកម្មភាពអប់រំគ្រុនចាញ់ដល់សហគមន៍ជន ជាតិភាគតិច តាមរយៈការបញ្ចាំង វីដេអូចល័ត | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ៥ ភូមិ | ១ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និង មណ្ឌលសុខភាព | ២០១៣-២០១៥ | ១៥ | ៥ | 2,626.67 | 2,626.67 | 2,626.67 | 7,880.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ( គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ២៥ | សកម្មភាពអប់រំគ្រុនចាញ់ដល់សហគមន៍ ដែលប្រឈម មុខខ្ពស់នឹងគ្រុនចាញ់ តាមរយៈការបញ្ចាំងវីដេអូចល័ត | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ១៥ ភូមិ | ១ ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និង មណ្ឌលសុខភាព | ២០១៣-២០១៥ | ៤៥ | ១៥ | 6,987.33 | 6,987.33 | 6,987.33 | 20,961.99 |
| ២៦ | ប្រជុំ ប្រចាំត្រីមាស ដល់គណៈកម្មការគ្រប់គ្រងមណ្ឌល សុខភាព និង ក្រុមទ្រទ្រង់សុខភាពភូមិ ពីសកម្មភាពគ្រុនចាញ់ | កាត់បន្ថយអត្រាឈឺ និងស្លាប់ដោយជម្ងឺគ្រុនចាញ់ | ១៧ មណ្ឌលសុខភាព និង ១១៩ ភូមិ | ៤ដង | គំរោងមូលនិធិសកលជុំទី៩ | អង្គការ អេច ភី អេ និង មណ្ឌលចំរើន និង គណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាព និងក្រុមទ្រទ្រង់សុខភាពភូមិ | ២០១៣-២០១៥ | ២០២ | ៦៩ | 28,930.15 | 28,930.15 | 28,930.15 | 86,790.44 |
| **សរុបរង** | | | | | | | | | | **251,804.56** | **124,084.56** | **113,334.56** | **489,223.67** |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| **៣.ផ្នែកគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ** | | | | | | | | | | **1,589.35** | **228.35** | **208.35** | **2,026.04** |
| **៣.១ ខណ្ឌរដ្ឋបាលព្រៃឈើ** | | | | | | | | | | | | | |
| ១ | កំណត់និងសម្របសម្រួលការបង្កើតតំបន់សក្តានុពលសហគមន៍ព្រៃឈើ | ៣.៤.១១ | ស្រុកជាំក្សាន្ត, ស្រុក ឆែប, ស្រុកត្បែងមានជ័យ,ស្រុករវៀង | ២៣៤ វគ្គ, សកម្មភាព | អង្គការ សហគមន៍ អឺរុប " EU " | ខណ្ឌរដ្ឋបាលព្រៃឈើ , អង្គការRecoft , OxfarmGB , DPA , ពន្លកខ្មែរ, អាជ្ញាធរមូលដ្ឋាន, | 2013-2015 | 1,080 | 560 | 40.38 | 40.38 | 40.38 | 121.15 |
| ២ | រៀបចំរេចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រង សហគមន៍ព្រៃឈើ | ៣.៤.១១ | ស្រុកជាំក្សាន្ត, ស្រុក ឆែប, ស្រុកត្បែងមានជ័យ,ស្រុករវៀង | ១៤៤ វគ្គ, សកម្មភាព | អង្គការ សហគមន៍ អឺរុប " EU " | ខណ្ឌរដ្ឋបាលព្រៃឈើ , អង្គការRecoft , OxfarmGB , DPA , ពន្លកខ្មែរ, អាជ្ញាធរ | 2013-2015 | 1,080 | 560 | 40.38 | 40.38 | 40.38 | 121.15 |
| ៣ | រៀបចំបទបញ្ជាផ្ទៃក្នុង និង លក្ខន្តិកៈសហគមន៍ ព្រៃឈើ | ៣.៤.១១ | ស្រុកជាំក្សាន្ត, ស្រុក ឆែប, ស្រុកត្បែងមានជ័យ,ស្រុករវៀង | ១៨០ វគ្គ, សកម្មភាព | អង្គការ សហគមន៍ អឺរុប " EU " | ខណ្ឌរដ្ឋបាលព្រៃឈើ , អង្គការRecoft , OxfarmGB , DPA , ពន្លកខ្មែរ, អាជ្ញាធរ | 2013-2015 | 1,080 | 560 | 20.19 | 20.19 | 20.19 | 60.57 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ៤ | រៀបចំចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ | ៣.៤.១១ | ស្រុកជាំក្សាន្ត, ស្រុក ឆែប, ស្រុកត្បែងមានជ័យ,ស្រុករវៀង | ១៤៤ វគ្គ, សកម្មភាព | អង្គការសហគមន៍ អឺរុប " EU " | ខណ្ឌរដ្ឋបាលព្រៃឈើ , អង្គការRecoft , OxfarmGB , DPA , ពន្លកខ្មែរ, អាជ្ញាធរមូលដ្ឋាន, | 2013-2015 | 1,080 | 560 | 20.19 | 20.19 | 20.19 | 60.57 |
| ៥ | វគ្គបណ្តុះបណ្តាលពីបច្ចេកទេសដាំឈើ និង សារៈសំខាន់នៃការដាំឈើ | ៣.៤.១១ | ស្រុកជាំក្សាន្ត, ស្រុកត្បែងមានជ័យ,ស្រុកឆែប | ៥៤ វគ្គ, សកម្មភាព | រាជរដ្ឋា ភិបាល | ផរព. ជាំក្សាន្ត ខណ្ឌរដ្ឋបាលព្រៃឈើ | 2013-2015 | 270 | 140 | 14.00 | 14.00 | 14.00 | 42.00 |
| ៦ | រៀបចំប្រភពផ្គត់ផ្គង់គ្រាប់ពូជឈើ និងកូនឈើសម្រាប់ការដាំឈើត្រូវនឹងបំរែបំរួលអាកាសធាតុ | ៣.៤.១១ | ស្រុកជាំក្សាន្ត, ស្រុកត្បែងមានជ័យ,ស្រុកឆែប | ៥៤ វគ្គ, សកម្មភាព | រាជរដ្ឋា ភិបាល | ផរព. ជាំក្សាន្ត ខណ្ឌរដ្ឋបាលព្រៃឈើ | 2013-2015 | 126 | 67 | 14.00 | 14.00 | 14.00 | 42.00 |
| ៧ | ផ្សព្វផ្សាយច្បាប់ស្តីពីព្រៃឈើ ,បទបញ្ជាលេខ០១, សារាចរលេខ០២ ដើម្បីទប់ស្កាត់ការកាប់រានដីព្រៃឈើ | ៣.៤.១១ | ស្រុកត្បែងមានជ័យ, | ៤៨ វគ្គ, សកម្មភាព | រាជរដ្ឋា ភិបាល | ខរព. ព្រះវិហារ ,ផរព.ត្បែងមានជ័យ និង ស្ថាប័នពាក់ព័ន្ធ | 2013-2015 | 2,880 | 1,400 | 29.60 | 29.60 | 29.60 | 88.80 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ៨ | ដើរល្បាត រុករក ស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ- សត្វព្រៃ | ៣.៤.១១ | ស្រុកត្បែងមានជ័យ, | ៣៦០ លើក | រាជរដ្ឋា ភិបាល | ខរព. ព្រះវិហារ ,ផរព.ត្បែងមានជ័យ និង ស្ថាប័នពាក់ព័ន្ធ | 2013-2015 | 60 | 0 | 29.60 | 29.60 | 29.60 | 88.80 |
| **សរុបរង** | | | | | | | | | | **208.35** | **208.35** | **208.35** | **625.04** |
| **៣.២ កិច្ចការនារី** | | | | | | | | | | | | | |
| ១ | សិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុដល់ស្រុក ក្រុងទាំង០៨ និងឃុំទាំង ៥២ របស់ ខេត្ត | ៣.៦.១៣ | ទីរួមខេត្ត | ១វគ្គ | NAPA | មន្ទីរកិច្ចការនារី | ២០១៣-២០១៤ | ៦៧នាក់ | ៣៥នាក់ | 12.00 | 20.00 | | 32.00 |
| **សរុបរង** | | | | | | | | | | **12.00** | **20.00** | | **32.00** |
| **៣.៣ បរិស្ថាន** | | | | | | | | | | | | | |
| ១ | សាងសង់ស្នាក់ការបរិស្ថានស្រុក | ៣.៣.៤ | ០៧ស្រុក | ៧ខ្នង | រដ្ឋ | មន្ទីរបរិស្ថាន | 2013 | 69904 | 32384 | 210.00 | | | 210.000 |
| **សរុបរង** | | | | | | | | | | **210.00** | | | **210.00** |
| **៣.៤ សមាគមអភិរក្សសត្វព្រៃ (WCS)** | | | | | | | | | | | | | |
| ១ | អេកូទេសចរណ៍ | ៣.២.២ | ស្រុកជាំក្សាន្ត - ឆែប - គូលែន | ៣ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | WCS/SVC/MoE/FA | 2013 | 1850 | 980 | 40.00 | | | 40.00 |
| ២ | បង្កើនជីវភាពសហគមន៍តាមរយៈប្រមូលទិញស្រូវម្លិះ | ៣.២.២ | ស្រុកជាំក្សាន្ត - ឆែប - គូលែន | ៩ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | WCS/SVC/MoE/FA | 2013 | 3745 | 2514 | 55.00 | | | 55.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយៈពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ៣ | ផែនការប្រើប្រាស់ដីធ្លី | ៣.៣.១ | ស្រុកជាំក្សាន្ត - ឆែប - គូលែន | ១៤ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | WCS/SVC/MoE/FA | 2013 | 3670 | 2445 | 43.00 | | | 43.00 |
| ៤ | ពង្រឹងសមត្ថភាពសហគមន៍ស្តីពីច្បាប់ព្រៃឈើ បរិស្ថាន និង ធនធានធម្មជាតិ | ៣.៣.៣ | ស្រុកជាំក្សាន្ត - ឆែប - គូលែន | ១៤ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | WCS/SVC/MoE/FA | 2013 | 3895 | 2054 | 35.00 | | | 35.00 |
| ៥ | ផ្សព្វផ្សាយចំណេះដឹងដល់សហគមន៍ស្តីពីការគ្រប់គ្រងធនធានធម្មជាតិ | ៣.៣.៣ | ស្រុកជាំក្សាន្ត - ឆែប - គូលែន | ១៤ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | WCS/SVC/MoE/FA | 2013 | 3998 | 2235 | 40.00 | | | 40.00 |
| ៦ | តាមដាន និង ស្រាវជ្រាវ ព្រៃឈើ និងសត្វព្រៃ | ៣.៣.៣ | ស្រុកជាំក្សាន្ត - ឆែប - គូលែន | ១៤ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | WCS/SVC/MoE/FA | 2013 | 3784 | 1993 | 80.00 | | | 80.00 |
| ៧ | ការពារសំបុកសត្វកម្រ | ៣.៣.៤ | ស្រុកជាំក្សាន្ត - ឆែប - គូលែន | ១៤ កន្លែង | UNDP/ GEF CEPF / US Fish and Wildlife | WCS/MoE/FA | 2013 | 3787 | 1876 | 50.00 | | | 50.00 |
| ៨ | អភិរក្សសត្វត្មាត | ៣.៣.៤ | ភូមិ ដងផ្លិត គុណភាព ណារ៉ុង ឃុំ ឆែប ពីរ ស្រុក ឆែប | ១ កន្លែង | UNDP/ GEF CEPF / US Fish and Wildlife/JICA | WCS/FA | 2013 | 1798 | 858 | 43.00 | | | 43.00 |
| ៩ | បោះបង្គោលដែនព្រៃបំរុងទុក អចិន្ត្រៃយ៍ | ៣.៣.៥ | ស្រុកឆែប-ជាំក្សាន្ត | ៥ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | WCS/FA | 2013 | 1896 | 985 | 100.00 | | | 100.00 |
| ១០ | កំណត់ព្រំប្រទល់ និង ការបែងចែកតំបន់គ្រប់គ្រងតំបន់ការពារ | ៣.៣.៣ | ស្រុកជាំក្សាន្ត - គូលែន | ៩ កន្លែង | UNDP/ GEF CEPF / US Fish and Wildlife | WCS/MoE | 2013 | 2065 | 52 | 43.00 | | | 43.00 |

| ល.រ | ឈ្មោះគម្រោង | ចូលរួមសម្រេចគោលបំណង | ទីតាំងគម្រោង | លទ្ធផលគ្រោង | ប្រភពថវិកា | អនុវត្តដោយ | រយះពេលអនុវត្ត | អ្នកទទួលផល | | កម្រិតទុនវិនិយោគ(គិតជាលានរៀល) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | សរុប | ស្រី | ២០១៣ | ២០១៤ | ២០១៥ | សរុប |
| ១១ | ជម្រុញការអនុវត្តច្បាប់ស្ដីពីច្បាប់គ្រប់គ្រងធនធានធម្មជាតិក្នុងតំបន់ការពារ | ៣.៤.១១ | ស្រុកជាំក្សាន្ត - គូលែន | ៦ កន្លែង | UNDP /GEF CEPF / US Fish and Wildlife | MoE | 2013 | 2276 | 958 | 150.00 | | | 150.00 |
| ១២ | ជម្រុញអនុវត្តច្បាប់ក្នុងតំបន់ព្រៃការពារស្ដីពីច្បាប់ព្រៃឈើ | ៣.៤.១១ | ស្រុកឆែប-ជាំក្សាន្ត | ២ កន្លែង | UNDP /GEF CEPF / US Fish and Wildlife/JICA | FA | 2013 | 2376 | 1068 | 150.00 | | | 150.00 |
| ១៣ | ពង្រឹងសម្ថតភាពក្រុមល្បាតក្នុងតំបន់ការពារស្ដីពីច្បាប់គ្រប់គ្រង | ៣.៣.១១ | ស្រុកជាំក្សាន្ត - គូលែន | | UNDP /GEF CEPF / US Fish and Wildlife | WCS/MoE | 2013 | 2456 | 1998 | 50.00 | | | 50.00 |
| ១៤ | ពង្រឹងសម្ថតភាពក្រុមល្បាតក្នុងតំបន់ព្រៃការពារ ស្ដីពីច្បាប់ព្រៃឈើ | ៣.៤.១១ | ស្រុកឆែប-ជាំក្សាន្ត | ៥ កន្លែង | UNDP/ GEF CEPF / US Fish and Wildlife/JICA | WCS/FA | 2013 | 2378 | 1087 | 50.00 | | | 50.00 |
| ១៥ | ការពារ ថែរក្សា និង ការគ្រប់គ្រងធនធានធម្មជាតិ | ៣.៣.៤ | ស្រុកជាំក្សាន្ត-ឆែប-គូលែន | ១៤ កន្លែង | UNDP/ GEF CEPF / US Fish and Wildlife/JICA | WCS/MoE/FA | 2013 | 2954 | 1896 | 230.00 | | | 230.00 |
| **សរុបរង** | | | | | | | | | | **1,159.00** | | | **1,159.00** |
| **សរុបរួម** | | | | | | | | | | **285,036.17** | **131,496.70** | **131,113.74** | **547,646.60** |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តព្រះវិហារ**
លេខ : ០០៩ -សសរ/ក្រប្រ

# សេចក្តីសម្រេច
## ស្តីពី
## គោលការណ៍ណែនាំផ្នែកគោលនយោបាយ
## សម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តព្រះវិហារ

## ប្រធានក្រុមប្រឹក្សា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៩/៧៥២ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៩ ស្តីពីការតែងតាំងជាអភិបាល នៃគណៈអភិបាលខេត្តព្រះវិហារ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៩/៦០៤ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ២០០៩ ស្តីពីការទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តព្រះវិហារអាណត្តិទី ១ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និង ក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- យោងតាមប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាក្រុង ការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាស្រុក និងការកំណត់តួនាទីភារកិច្ចរបៀបរបបការងារនៃការិយាល័យទាំងនោះ។
- បានឃើញអនុក្រឹត្យលេខ ២១៩ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

- បានឃើញអនុក្រឹត្យលេខ ១៥២ អនក្រ.បក ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា១២ នៃអនុក្រឹត្យស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញប្រកាសអន្តរក្រសួងលេខ ២៤១៧ ប្រក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១០ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- យោងតាមស្មារតីនៃកិច្ចប្រជុំសាមញ្ញលើកទី២៤ ក្រុមប្រឹក្សាខេត្តអាណត្តិទី១ នាថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១។

## សម្រេច ៖

**ប្រការ ១.-**

សេចក្តីសម្រេចនេះ មានគោលបំណងណែនាំផ្នែកគោលនយោបាយសម្រាប់ការកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ។

**ប្រការ ២.-**

ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវអនុវត្តទៅតាមសេចក្តីណែនាំបច្ចេកទេសស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

**ប្រការ ៣.-**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវរៀបចំឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗមួយចំនួនដូចជា ៖

១. ការចែករំលែកព័ត៌មាន

២. តម្លាភាព

៣. សង្គតិភាព និងសុខដុមនីយកម្ម

៤. ការចូលរួមពិគ្រោះយោបល់ជាទូទៅ

៥. ការឆ្លើយតបនឹងតម្រូវការ

៦. គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ

៧. ប្រសិទ្ធភាព និងសុក្រឹត្យភាពសេដ្ឋកិច្ច និងសង្គម

៨. ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន

៩. ការធានាសមធម៌។

**ប្រការ ៤.-**

ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខេត្ត ត្រូវមានលក្ខណៈគ្រប់ជ្រុងជ្រោយដែលគ្របដណ្តប់លើគ្រប់វិស័យអាទិភាពឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងស្របតាមគោលនយោបាយអភិវឌ្ឍន៍ខេត្ត និងគោលនយោបាយអភិវឌ្ឍន៍ជាតិ ដើម្បីអភិវឌ្ឍសេដ្ឋកិច្ច និងធ្វើឱ្យប្រសើរឡើងនូវគុណភាពជីវិត និងសុខុមាលភាពប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខេត្ត។

**ប្រការ ៥..**

ស្ថិតក្នុងអាណត្តិ៥ឆ្នាំ ក្រុមប្រឹក្សាខេត្តមានទស្សនៈវិស័យគោលដៅ បន្តអនុវត្តនូវយុទ្ធសាស្ត្រកាត់បន្ថយនូវភាពក្រីក្ររបស់រាជរដ្ឋាភិបាលស្របទៅតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ របស់រាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ និងគោលដៅអភិវឌ្ឍន៍សហវស្សវត្សកម្ពុជា។ គោលនយោបាយខាងលើនេះ ផ្អែកទៅតាមតម្រូវការរបស់ប្រជាពលរដ្ឋក្នុងពេលបច្ចុប្បន្ននេះដែលជាមតិយោបល់ពីគ្រប់មជ្ឈដ្ឋានប្រជាពលរដ្ឋ និងគ្រប់ស្ថាប័នដោយធ្វើការសំយោគចេញពីបញ្ហា និងតម្រូវការរបស់គ្រប់ស្ថាប័ននៅថ្នាក់ក្រោមជាតិដែលមានលក្ខណៈតាមបែបប្រជាធិបតេយ្យមានសង្គតិភាពសុខដុមនីយកម្ម និងតម្លាភាពដែលបម្រើឱ្យផលប្រយោជន៍ទូទៅរបស់ប្រជាពលរដ្ឋនៅក្នុងខេត្ត និងប្រើប្រាស់ឱ្យសក្តានុពលធនធានដែលមាននៅក្នុងខេត្ត និងការជួយឧបត្ថម្ភគាំទ្រពីថ្នាក់ជាតិ។ ផែនការអភិវឌ្ឍន៍ខេត្តរយៈពេល៥ឆ្នាំចាប់ពីឆ្នាំ២០១១-២០១៥ មានគោលដៅកាត់បន្ថយនូវភាពក្រីក្រក្នុងខេត្ត។កត្តាចាំបាច់ត្រូវយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍ប្រព័ន្ធគមនាគមន៍ធនធានទឹក អគ្គិសនី ធនធានមនុស្សនិងយកចិត្តទុកដាក់ជា សំខាន់ទៅលើជនក្រីក្រដែលងាយរងគ្រោះឱ្យមានសមភាពសមធម៌ យេនឌ័រធ្វើឱ្យប្រជាពលរដ្ឋមានជីវភាពរស់នៅកាន់តែល្អប្រសើរឡើង កាត់បន្ថយនូវអត្តុល្យភាពរវាងជនបទ និងទីប្រជុំជន។ ដើម្បីសម្រេចឱ្យបាននូវទស្សនៈគោលនយោបាយដូចខាងលើនេះ គ្រប់ស្ថាប័នទាំងអស់ត្រូវយកចិត្តដាក់ខិតខំជម្រុញការអនុវត្តឱ្យបានទៅលើវិស័យសំខាន់ៗជាច្រើន ដូចខាងក្រោមនេះ :

## ១.ផ្នែកសេដ្ឋកិច្ច

### ១.១ វិស័យកសិកម្ម

ពង្រឹង និងពង្រីកវិស័យកសិកម្មឱ្យមានការរីកចម្រើនបន្ថែមទៀត ដោយពង្រីកផ្ទៃដីបង្កបង្កើនផលឱ្យបាន ៩០,០០០ហិកតា ទិន្នផលជាមធ្យមទូទៅ៣.២តោន/១ហិកតា ដោយបញ្ចូលបច្ចេកវិទ្យាកសិកម្មទំនើបកែប្រែប្រព័ន្ធធារាសាស្ត្រ បង្កើនផ្ទៃដីស្រោចស្រព ពង្រីកផ្ទៃដីដំណាំស្រូវតាមរយៈការធ្វើប្រពលវប្បកម្មដំណាំស្រូវ ដើម្បីបង្កើន ទិន្នផលផលិតកម្មដំណាំស្រូវឱ្យប្រជាពលរដ្ឋមាននិរន្តរភាពស្បៀងអាហារហូបចុកឱ្យបានគ្រប់គ្រាន់ និងកែច្នៃជាអង្ករ សម្រាប់ធ្វើការនាំចេញទៅក្រៅខេត្ត ស្របតាមគោលនយោបាយនាំអង្ករឱ្យបាន១លានតោននៅឆ្នាំ២០១៥ របស់រាជរដ្ឋាភិបាល។ ជាពិសេសក្រៅពីការងារផលិតកម្មដំណាំស្រូវ គឺការយកចិត្តទុកដាក់លើការចិញ្ចឹមសត្វគ្រប់ប្រភេទ សម្រាប់បម្រើជីវភាពរស់នៅ ធ្វើជាកម្លាំងអូសទាញ និងបង្កើនប្រាក់ចំណូលបន្ថែម។ ទន្ទឹមនឹងនេះ ការថែរក្សា ធនធានជលផល ពង្រីកវារីវប្បកម្ម លក្ខណៈគ្រួសារឱ្យធ្វើយ៉ាងណាបានគ្រប់ភូមិ ឃុំ ដើម្បីធានាឱ្យបាននូវនិរន្តរភាព ធនធានធម្មជាតិនៅក្នុងខេត្ត ជាពិសេសការពារព្រៃលិចទឹកតាមតំបន់ដងស្ទឹង និងតំបន់ស្រះជំរកត្រីធម្មជាតិតាមរយៈ ការបង្កើតជាសហគមន៍ការពារស្រះជំរកត្រី និងព្រៃឈើបម្រុងទុកជាសាធារណៈរបស់រដ្ឋ ធ្វើយ៉ាងណាឱ្យបាន៦០% ស្របតាមគោលនយោបាយថ្នាក់ជាតិ ។

### ១.២ ធនធានទឹក និងឧតុនិយម

ស្រមតាមគោលនយោបាយថ្នាក់ជាតិ បន្តជម្រុញការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក និងការអនុវត្ត អនុត្តរភាពប្រព័ន្ធធារាសាស្ត្រតាមរយៈការកសាង និងស្តារប្រព័ន្ធធារាសាស្ត្រដែលមានស្រាប់ ដើម្បីឆ្លើយតបទៅ និង តម្រូវការទឹកបន្ទាន់សម្រាប់ការងារកសិកម្ម គ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត។ ផ្តល់អាទិភាពដល់ ការងារស្តារ និងសាងសង់អាងតំកល់ទឹក ស្រះទឹក ប្រឡាយនាំទឹក និងប្រព័ន្ធដោះទឹក ដើម្បីធានាដល់ការផ្គត់ផ្គង់ទឹកដល់ផ្ទៃដីបង្កបង្កើនផល មច្ឆវប្បកម្ម និងជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ និងសត្វពាហនៈ។ ជម្រុញការរៀបចំច្បាប់បទប្បញ្ញត្តិ និងចីរភាពទឹក។ គ្រប់គ្រងព័ត៌មាន និងផ្សព្វផ្សាយអំពីច្បាប់ស្តីពីធនធានទឹក និងឧតុនិយម។ ធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងរដ្ឋបាល និងការអភិវឌ្ឍធនធានមនុស្ស។ បង្កើតសហគមន៍កសិករប្រើប្រាស់ទឹក ដើម្បីជម្រុញការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការគ្រប់គ្រង ថែរក្សាប្រភពទឹក និងប្រព័ន្ធធារាសាស្ត្រឱ្យមាននិរន្តរភាព ដើម្បីចូលរួមចំណែកការបន្ថយភាពក្រីក្រនៅជនបទ។ បន្តសហការ និងស្វែងរកដៃគូអភិវឌ្ឍន៍សង្គមស៊ីវិលដើម្បីជួយគាំទ្រលើវិស័យធនធានទឹក។ ជម្រុញការអភិវឌ្ឍកសិកម្មតាមរយៈការបន្តតាមដានកំរិតទឹកភ្លៀង និងកំរិតទឹក ស្ទឹងប្រចាំឆ្នាំ ដើម្បីត្រៀមបង្ការគ្រោះមហន្តរាយធម្មជាតិ។

### ១.៣ ឧស្សាហកម្មរ៉ែ និងថាមពល

យកចិត្តទុកដាក់ពង្រីក និងគ្រប់គ្រងឱ្យបានល្អនូវមូលដ្ឋានសិប្បកម្ម អាជីវកម្មនៅក្នុងខេត្ត ដើម្បីគាំទ្រដល់ការកែឆ្នៃ កសិផលសម្រាប់ហូបចុក នាំចេញ និងកែឆ្នៃ គ្រប់គ្រងធ្វើអាជីវកម្មធនធានរ៉ែសម្រាប់បង្កើនចំណូលក្នុងខេត្ត។ ជម្រុញកិច្ចសហការជាមួយក្រុមហ៊ុន ឬវិស័យឯកជនលើការងារសិប្បកម្មដោយធ្វើការផ្សព្វផ្សាយ ច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រសហគ្រាសឧស្សាហកម្មសិប្បកម្មធុនតូចនិងមធ្យម ច្បាប់ស្តីពីការធ្វើអាជីវកម្ម ធនធានរ៉ែ និងច្បាប់ស្តីពីថាមពលអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជាឱ្យបានទូលំទូលាយ។ យកចិត្តទុកដាក់ និងពង្រីកការផ្គត់ផ្គង់ទឹកស្អាតជូនប្រជាពលរដ្ឋឱ្យបានជាអតិបរមាតាមរយៈការស្វែងរកដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន។ បង្កើនការផ្គត់ផ្គង់អគ្គិសនីឱ្យបានគ្រប់ទីប្រជុំជន និងជនបទដែលមានតម្លៃសមស្របទៅតាមជីវភាពរស់នៅបច្ចុប្បន្ន។ ជម្រុញឱ្យមានការចូលរួមវិនិយោគពីផ្នែកឯកជនក្នុងវិស័យថាមពលរួមមានការផលិតការបញ្ជូននិងការចែកចាយជាដើម។

### ១.៤ សាធារណការ និងដឹកជញ្ជូន

បន្តការអភិវឌ្ឍវិស័យសាធារណការ និងដឹកជញ្ជូន តាមរយៈការផ្សព្វផ្សាយអំពីការប្រើប្រាស់ផ្លូវថ្នល់ និងច្បាប់ចរាចរផ្លូវគោក ការសាងសង់ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ ជាពិសេសផ្លូវដែលតភ្ជាប់ពីទីប្រជុំជនទៅជនបទសម្រាប់ផ្សារភ្ជាប់សេដ្ឋកិច្ចជនបទនិងទីផ្សារ ដើម្បីបង្កើនជីវភាពរស់នៅរបស់ប្រជាពលរដ្ឋធ្វើជាផ្លូវយុទ្ធសាស្ត្រសម្រាប់ចរាចរសេដ្ឋកិច្ចអន្តរជាតិ។

### ១.៥ គមនាគមន៍ និងទូរគមនាគមន៍

ផ្អែកតាមគោលនយោបាយថ្នាក់ជាតិ ពង្រីកសេវាកម្មប្រៃសណីយ៍ និងកាត់បន្ថយថ្លៃដោយធ្វើការអភិវឌ្ឍ

និងផ្តល់ព័ត៌មាន ស្តីពីកាលានុវត្តភាពនៃការវិនិយោគដល់វិនិយោគិន ទាក់ទងនឹងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ។ ពង្រីកបណ្តាញទូរគមនាគមន៍គ្រប់ប្រភេទសម្រាប់ទំនាក់ទំនងពាណិជ្ជកម្ម ដើម្បីបម្រើផលប្រយោជន៍សេដ្ឋកិច្ចខេត្ត។

**១.៦ ពាណិជ្ជកម្ម**

បង្កើនការគ្រប់គ្រង និងអភិវឌ្ឍន៍ទីផ្សារ រៀបចំពិព័ណ៌ផលិតផលពាណិជ្ជកម្មប្រចាំឆ្នាំ ដើម្បីស្វែងរកទីផ្សារផលិតផល បង្កើនបរិមាណ គុណភាពផលិតផល កសិផល សិប្បកម្មកែច្នៃដើម្បីនាំចេញ ផ្សព្វផ្សាយច្បាប់ ផ្តល់ព័ត៌មានពាណិជ្ជកម្មតំលៃលើទីផ្សារតាមប្រព័ន្ធព័ត៌មានទីផ្សារអេឡិចត្រូនិច (EMCS) ផ្តល់គោលនយោបាយបើកទូលាយទីផ្សារដល់វិនិយោគ ធុរៈកិច្ចអនុញ្ញាតផ្តល់សេវាដល់មូលដ្ឋានការធ្វើអាជីវកម្មសេវាកម្ម ពង្រឹងប្រសិទ្ធិភាពនៃការត្រួតពិនិត្យទីផ្សារ ដើម្បីការពារសុខភាព និងសុខុមាលភាពអ្នកប្រើប្រាស់។

**១.៧ ទេសចរណ៍**

ពង្រីក និងពង្រឹងការអភិវឌ្ឍន៍ផលិតផលទេសចរណ៍នៅក្នុងខេត្ត តាមរយៈដៃគូអភិវឌ្ឍន៍នានា និងការរៀបចំសហគមន៍ទេសចរណ៍មូលដ្ឋាន ដើម្បីធ្វើឱ្យខេត្តក្លាយជាគោលដៅទាក់ទាញទេសចរ ។ ជម្រុញការផ្សព្វផ្សាយពីផលិតផលទេសចរណ៍ សិក្សាទីផ្សារទេសចរណ៍ ជម្រុញសកម្មភាពចលនាប្រឡងប្រណាំង ទីក្រុងស្អាត រមណីយដ្ឋានស្អាតសេវាល្អ។ សហការជាមួយសមត្ថកិច្ចពាក់ព័ន្ធដើម្បីធានាបានសន្តិសុខសុវត្ថិភាពជូនភ្ញៀវទេសចរ លើកស្ទួយតម្លៃនៃវប្បធម៌ប្រពៃណីជាតិ និងការគ្រប់គ្រងអភិវឌ្ឍន៍លើប្រភពធនធានប្រកបដោយនិរន្តរភាព ស្របតាមគោលនយោបាយជាតិលើវិស័យទេសចរណ៍ ផ្តល់ឱកាសការងារធ្វើដល់ប្រជាពលរដ្ឋដោយផ្ទាល់ និងប្រយោល ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈវិស័យទេសចរណ៍ ។

**១.៨ វិស័យឯកជន**

យកចិត្តទុដាក់បង្កើនការទំនាក់ទំនង និងសហប្រតិបត្តិការជាមួយវិស័យឯកជន សង្គមស៊ីវិលដើម្បីលើកកម្ពស់ការវិនិយោគគ្រប់វិស័យក្នុងខេត្ត សំដៅរួមចំណែកក្នុងការអភិវឌ្ឍន៍មូលដ្ឋានប្រកបដោយវឌ្ឍនភាព និងបង្កើតឱកាសការងារសម្រាប់ប្រជាពលរដ្ឋមូលដ្ឋាន ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។

## ២.ផ្នែកសង្គមកិច្ច

**២.១ អប់រំយុវជន និងកីឡា**

ស្របតាមគោលនយោបាយជាយុទ្ធសាស្ត្ររបស់ផែនការយុទ្ធសាស្ត្រជាតិ រួមមានការបង្កើនសមធម៌នៃការចូលរៀន ដោយយកចិត្តទុកដាក់បង្កើនចំនួនសាលារៀន ចាប់ពីសាលាមត្តេយ្យសិក្សា សាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ និងជម្រុញកុមារគ្រប់អាយុឱ្យបានចូលរៀនគ្រប់ៗគ្នា ពិសេសកុមារតូច។ ការកែលម្អគុណភាព និងប្រសិទ្ធភាពសេវាអប់រំដោយយកចិត្តទុកដាក់លើវឌ្ឍនភាពសំខាន់ៗលើកម្មវិធីមួយចំនួនដូចជាកម្មវិធីសាលាកុមារមេត្រី កម្មវិធីសិក្សា និងការវាយតម្លៃសិក្សា និងត្រូវមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ជាពិសេសលើការអភិវឌ្ឍន៍កុមារតូចៗ ការកាត់បន្ថយអត្រាបោះបង់ការសិក្សា។ ទន្ទឹមនេះដែរខេត្ត ជម្រុញការយកចិត្តទុកដាក់ពង្រីកហេដ្ឋារចនាសម្ព័ន្ធឱ្យមានភាពងាយស្រួល អនុគ្រោះដល់សិស្សានុសិស្សក្រីក្រនៅ ជនបទ ពង្រឹងគុណភាព

វិស័យអប់រំសម្រាប់យើងទាំងអស់គ្នា ផ្តល់សមធម៌ក្នុងការអប់រំធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋម្នាក់ៗអាចបញ្ចប់ការអប់រំមូលដ្ឋានរយៈពេល៩ឆ្នាំស្របទៅតាមគោលដៅទី៣នៃសហវត្សរ៍កម្ពុជា ផ្តល់បច្ចេកទេសវិជ្ជាជីវៈ និងលុបបំបាត់អនក្ខរភាព យកចិត្តទុកដាក់លើការអភិវឌ្ឍន៍ធនធានមនុស្ស។

## ២.២ សុខាភិបាល

ផ្អែកលើផែនការយុទ្ធសាស្ត្រជាតិក្នុងវិស័យសុខាភិបាល លើកកំពស់សុខភាពបន្តពូជ មាតា ទារក និងកុមារ យកចិត្តទុកដាក់បង្ការទប់ស្កាត់ជម្ងឺឆ្លង និងបញ្ហាសុខភាពដទៃទៀត។ លើសពីនេះទៀត លើកកំពស់ការគ្រប់គ្រងសីលធម៌វិជ្ជាជីវៈ ពង្រឹងគុណភាពសុខាភិបាល ផ្តល់សេវាសុខភាពប្រកបដោយសមធម៌ដល់ ប្រជាពលរដ្ឋទូទៅ ជាពិសេសជនងាយរងគ្រោះ ជនក្រីក្រ ស្ត្រី និងកុមារ។ កាត់បន្ថយអត្រាមរណៈភាពមាតាពេលសំរាលនិងអត្រាមរណៈភាពកុមារដោយជំរុញឱ្យទទួលយកសេវាសំរាលកូនដោយឆ្មបពេទ្យ ។បន្តការចាក់វ៉ាក់សាំងការពារជំងឺ៨មុខដល់កុមារ ការពារការរីករាលដាលនៃមេរោគអេដស៍ ជំងឺអេដស៍ ផ្សព្វផ្សាយពីសុខភាពអនាម័យ អប់រំណែនាំពីវិធានការពារសុខភាព និងជំរុញប្រជាពលរដ្ឋ ដែលរស់នៅជនបទឱ្យមានទំលាប់ប្រើប្រាស់ទឹកស្អាត និងបង្គន់អនាម័យឱ្យបានគ្រប់គ្រួសារ។ ជាងនេះទៀត បន្តជម្រុញការអភិវឌ្ឍមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព តាមបណ្តោយព្រំដែន ដើម្បីពង្រឹងសុវត្ថិភាពសុខភាពប្រជាពលរដ្ឋ។

## ២.៣ យេនឌ័រ

យកចិត្តទុកដាក់លើកកំពស់សមភាព សមធម៌យេនឌ័រ ដោយបង្កើនជីវភាពរស់នៅដល់ស្ត្រី ការថែទាំសុខភាព ផ្តល់ការអប់រំចំណេះដឹងជំនាញវិជ្ជាជីវៈដល់ស្ត្រី កាត់បន្ថយអំពើហិង្សាក្នុងគ្រួសារ ការជួញដូរស្ត្រី និងកុមារ ទប់ស្កាត់ការចាប់រំលោភផ្លូវភេទ អប់រំពីការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ជួយការពារផ្តល់អនុសាសន៍ផ្នែកផ្លូវច្បាប់ដល់ស្ត្រី ជម្រុញលើកទឹកចិត្តឱ្យស្ត្រីមានសេចក្តីក្លាហាន និងមានសមត្ថភាពចូលរួមក្នុង ការងារអភិវឌ្ឍន៍សង្គម និង ធ្វើសេចក្តីសំរេចចិត្តឱ្យបានច្រើនថែមទៀតនៅគ្រប់ស្ថាប័ន និងគ្រប់មូលដ្ឋាននៅជនបទ។

## ២.៤ ភាពក្រីក្រ

ជម្រុញកាត់បន្ថយនូវភាពក្រីក្រឱ្យបានច្រើនជាអតិបរមាក្នុងមួយឆ្នាំៗ ដោយយកចិត្តទុកដាក់ដល់ជនងាយរងគ្រោះមាន ស្ត្រីមេម៉ាយ ជនពិការ កុមារកំព្រា ចាស់ជរាគ្មានទីពឹង និងអ្នកផ្ទុកមេរោគអេដស៍។ ផ្តល់ដីសម្បទានសង្គមកិច្ចដល់អ្នកគ្មានដីសំរាប់សាងសង់លំនៅដ្ឋាន និងកសិកម្ម ផ្តល់ផលប្រយោជន៍ពីការអភិវឌ្ឍន៍ដោយផ្តល់ប័ណ្ណសមធម៌ដើម្បីទទួលបានសេវាផ្សេងៗជាពិសេសសេវាថែទាំសុខភាព និងសេវាអប់រំសំរាប់គ្រួសារ។ ធ្វើការបណ្តុះ-បណ្តាលវិជ្ជាជីវៈ និងបង្កើតមុខរបរ ដល់ជនក្រីក្រ។

## ២.៥ សាសនា

លើកកម្ពស់ការគោរពជំនឿសាសនា គ្រប់ប្រភេទដោយស្ម័គ្រចិត្ត និងយកចិត្តទុកដាក់គ្រប់គ្រង និងអភិវឌ្ឍន៍ផ្តល់សេវាសាសនាប្រកបដោយសីលធម៌ និងគុណធម៌ខ្ពស់ ជាពិសេសព្រះពុទ្ធសាសនាដែលជាសាសនារបស់ជាតិ។

### ២.៦ ស្ថានភាពអន្តោប្រវេសន៍

បង្កើនភាពជាដៃគូរក្នុងការវិនិយោគនៅក្នុងខេត្តឱ្យបានច្រើនថែមទៀត ដើម្បីពង្រីកមុខរបរឱ្យប្រជាជនធ្វើឱ្យបានច្រើន កាត់បន្ថយការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។

## ៣.ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិបរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ៣.១ ការគ្រប់គ្រងដីធ្លី

ពង្រឹងការគ្រប់គ្រង និងបែងចែកការប្រើប្រាស់ដីធ្លី ដោយជំរុញការបោះព្រំប្រទល់ព្រៃបំរុងទុករបស់រដ្ឋ ការរៀបចំដែននេសាទ ផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីជាប្រព័ន្ធដល់ប្រជាពលរដ្ឋឱ្យបានគ្រប់គ្រួសារ និងអប់រំផ្សព្វផ្សាយអំពីច្បាប់ និងលិខិតបទដ្ឋានគតិយុតិដល់ប្រជាពលរដ្ឋ ដើម្បីកាត់បន្ថយទំនាស់ដីធ្លី សំដៅបង្កើតកំណើនសេដ្ឋកិច្ចគ្រួសារ និងសហគមន៍។

### ៣.២ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន

ពង្រឹងការគ្រប់គ្រង និងថែរក្សា ការពារធនធានធម្មជាតិ ធនធានរ៉ែ ព្រៃឈើ សត្វព្រៃ ធនធានជលផល ព្រៃលិចទឹក ការស្តារបឹងធម្មជាតិឱ្យបានគង់វង្ស ធានានូវការប្រើប្រាស់ប្រកបដោយចីរភាព និងកាត់បន្ថយការបំផ្លិចបំផ្លាញធនធានធម្មជាតិ និងការបំពុលបរិស្ថានឱ្យបានជាអតិរមាតាមរយៈការអនុវត្តច្បាប់ស្តីពីព្រៃឈើ និងការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យជួយថែរក្សាព្រៃឈើ និងដាំដើមឈើឡើងវិញ។ គ្រប់គ្រង និងថែរក្សានិរន្តរភាព បរិស្ថាន តាមរយៈការផ្សព្វផ្សាយអំពីផលប៉ះពាល់បរិស្ថានដែលបណ្តាលមកពីការប្រើប្រាស់ថ្នាំពុលកសិកម្ម ការចោល សម្រាម ឬកាកសំណល់រឹងរាវដោយគ្មានសណ្តាប់ធ្នាប់ និងការប្រើប្រាស់បង្គន់អនាម័យ។

### ៣.៣ គ្រោះមហន្តរាយ និងការប្រែប្រួលធាតុអាកាស

ធ្វើការតាមដាន និងសិក្សាអំពីស្ថានភាពនៃគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ដើម្បីចាត់វិធានការធ្វើផែនការត្រៀមបង្ការ ត្រៀមបំរុងនូវទីទួលសុវត្ថិភាព ថវិកា សំភារៈ ស្បៀងអាហារ មធ្យោបាយដឹកជញ្ជូន ដើម្បីជួយសង្គ្រោះឱ្យបានទាន់ពេលវេលាដល់ជនរងគ្រោះដោយគ្រោះមហន្តរាយ។ គ្រប់គ្រងព្រៃឈើឱ្យមាននិរន្តរភាព ដើម្បីទប់ទល់នឹងគ្រោះធម្មជាតិពីការប្រែប្រួលអាកាសធាតុ ជាពិសេសគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ដែលតែងតែកើតមាននៅតាមដងស្ទឹងនានា និងតំបន់ទំនាប។ ធ្វើផែនការបញ្ចៀសទឹកជំនន់ កាត់បន្ថយការខូចខាតដល់ភោគផលដំណាំទ្រព្យសម្បត្តិ ផ្ទះសំបែងរបស់ប្រជាពលរដ្ឋ ។

## ៤.ការគ្រប់គ្រងរដ្ឋបាលនិងសន្តិសុខសណ្តាប់ធ្នាប់សង្គម

លើកកំពស់ការគ្រប់គ្រងរដ្ឋបាលតាមរយៈអភិបាលកិច្ចល្អនៅគ្រប់ថ្នាក់រដ្ឋបាលខេត្ត ដើម្បីកាត់បន្ថយពេលវេលាពិនិត្យឯកសារ និងចំណាយរត់ការក្រៅផ្លូវច្បាប់។ បង្កើនការគ្រប់គ្រងកំណត់ព្រំប្រទល់រដ្ឋបាល ឱ្យបានច្បាស់ កំណត់បង្កើតភូមិថ្មីស្របតាមផ្លូវច្បាប់ធ្វើការរៀបចំប្លង់គោលឱ្យបានត្រឹមត្រូវ និងជំរុញការចុះបញ្ជីអត្រានុកូលដ្ឋាន ធ្វើអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋប្រើប្រាស់បានគ្រប់ៗគ្នា។

លើកកំពស់ការអនុវត្តន៍គោលនយោបាយភូមិ ឃុំមានសុវត្ថិភាព ដើម្បីលប់បំបាត់ការជួញដូរគ្រឿងញៀន អំពើចោរកម្ម អំពើហឹង្សា ការជួញដូរមនុស្ស ការចាប់រំលោភផ្លូវភេទ ល្បែងស៊ីសង ក្មេងទំនើង បទល្មើសផ្សេងៗ និងជំរុញការគោរពការអនុវត្តន៏ច្បាប់ចរាចរ ។

**ប្រការ ៦..**

ដំណើរការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ត្រូវផ្តល់ឱកាសឱ្យបានពេញលេញដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដើម្បីចូលរួមនៅក្នុងដំណើរការទាំងមូលរួមមាន គណៈអភិបាលខេត្ត មន្ទីរ អង្គភាពជំនាញជុំវិញខេត្ត, ទីចាត់ការចំណុះសាលាខេត្ត, សាលាក្រុង-ស្រុក, ក្រុមប្រឹក្សាឃុំ-សង្កាត់, អង្គការ សង្គមស៊ីវិល, វិស័យ-ឯកជន ជាពិសេសក្រុមហ៊ុនឯកជននានា សហគ្រាសធុនតូច និងមធ្យម, ប្រជាពលរដ្ឋ, ក្រុមតំណាងផលប្រយោជន៍ , ក្រុមជនងាយរងគ្រោះ និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

**ប្រការ ៧..**

គណៈអភិបាលខេត្ត, នាយករដ្ឋបាល នាយកទីចាត់ការទាំង ៥ ចំណុះរចនាសម្ព័ន្ធសាលាខេត្ត, លោកអភិបាលក្រុង-ស្រុក និងលោក លោកស្រីប្រធានមន្ទីរ អង្គភាពពាក់ព័ន្ធទាំងអស់ ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ព្រះវិហារ ថ្ងៃទី ១១ ខែមេសា ឆ្នាំ២០១១

**ជ.ក្រុមប្រឹក្សាខេត្ត**

**ប្រធាន**

**ឡុង សុវណ្ណ**

*ចម្លងជូន :*

- ក្រសួងមហាផ្ទៃ
- ក្រសួងផែនការ
- លេខាធិការដ្ឋាន (គ.ជ.អ.ប)

**" ដើម្បីជូនជ្រាប "**

- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារក្រុមប្រឹក្សាខេត្ត
- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត
- ក្រុមការងារកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ដូចក្នុងប្រការ៧

**" ដើម្បីមុខការ និងអនុវត្ត "**

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តព្រះវិហារ

លេខ : ០០៣ លផ/ក្រប្រ/ទផវិ

## ប្រតិទិនការងារសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត២០១៣-២០១៥

| ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | | |
|---|---|---|---|---|
| **ល.រ** | **ជំហាន/សកម្មភាព** | **កាលបរិច្ឆេទ** | **ទីកន្លែង** | **អ្នកទទួលខុសត្រូវ** |
| **ជំហានទី១: ការរៀបចំបញ្ចើតគម្រោងអាទិភាពសម្រាប់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត** | | | | |
| ១.១ | ប្រជុំអនុម័តប្រតិទិនការងារសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ២០១៣-២០១៥ | ៣១/សីហា/២០១២ | សាលាខេត្ត | ក្រុមប្រឹក្សាខេត្ត |
| | ប្រជុំផ្សព្វផ្សាយលិខិត ០៧៧ សជណ និងបណ្តុះបណ្តាលស្តីពីការកសាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិលខេត្ត ២០១៣-២០១៥ | ០៦/កញ្ញា/២០១២ | សាលាខេត្ត | ក្រុមការងារកសាងផែនការ (ក.ក.ផ) |
| | ផ្សព្វផ្សាយប្រតិទិនការងារសម្រាប់ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | | | |
| **ជំហានទី២: ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល** | | | | |
| ២.១ | ការធ្វើបច្ចុប្បន្នភាពស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច (ជំពូក១) | ១០-២១/កញ្ញា/២០១២ | សាលាខេត្ត | ក្រុមការងារកសាងផែនការ(ក្រុមតូច) |
| ២.២ | ការធ្វើបច្ចុប្បន្នភាពគម្រោងនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល (តារាង ២.១ តារាង២.២ តារាង២.៣ និងតារាង២.៤ | ១០-២១/កញ្ញា/២០១២ | សាលាខេត្ត | ក្រុមការងារកសាងផែនការ(ក្រុមតូច) |
| | ដាក់ជូនសំណើគម្រោងពីក្រុង-ស្រុក មន្ទីរ និងអង្គភាពពាក់ព័ន្ធ | ១០-១៤/កញ្ញា/២០១២ | សាលាខេត្ត | ក.ក.ផ (ក្រុមតូច) ក្រុង-ស្រុក មន្ទីរ និងអង្គភាពពាក់ព័ន្ធ |
| ២.៣ | ការប្រជុំពិនិត្យសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ២៧/កញ្ញា/២០១២ | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធនានា |
| ២.៤ | បណ្តុះបណ្តាលស្តីពីការរៀបចំវេទិកាស្តីពីកម្មវិធីវិនិយោគរាជធានី ខេត្ត និងការរៀបចំសិក្ខាសាលាសមាហរណកម្មថ្នាក់ក្រុង ស្រុក ខណ្ឌ | ០៣/តុលា/២០១២ | | ក្រុមការងារកសាងផែនការ (ក.ក.ផ) |
| ២.៥ | ការរៀបចំសិក្ខាសាលាសមាហរណកម្មនៃកម្មវិធីវិនិយោគខេត្ត (វេទិកាពិគ្រោះយោបល់កម្មវិធីវិនិយោគខេត្ត) | ០៩/តុលា/២០១២ | សាលាខេត្ត | ក្រុមការងារ/អ្នកពាក់ព័ន្ធនានា |
| ២.៦ | ការជ្រើសរើសគម្រោងសម្រាប់ប្រើប្រាស់ថវិកាវិនិយោគខេត្ត ក្រុង-ស្រុក | ១០-១២/តុលា/២០១២ | សាលាខេត្ត | ក្រុមការងារកសាងផែនការ(ក្រុមតូច) |
| ២.៧ | ការរៀបចំបញ្ចប់សេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ១៣-២៦/តុលា/២០១២ | សាលាខេត្ត | ក្រុមការងារកសាងផែនការ(ក្រុមតូច) |

| | | | | |
|---|---|---|---|---|
| ២.៨ | ការពិនិត្យនិងផ្តល់យោបល់របស់គណៈអភិបាលខេត្ត | ០៦/វិច្ឆិកា/២០១២ | សាលាខេត្ត | គណៈអភិបាលខេត្ត |
| ២.៩ | ការពិនិត្យនិងផ្តល់យោបល់របស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត | ០៨/វិច្ឆិកា/២០១២ | សាលាខេត្ត | គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសខេត្ត |
| **ជំហានទី៣: ការអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត** | | | | |
| ៣.១ | ការងារត្រៀមសម្រាប់ការប្រជុំអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត<br>រៀបចំ សេចក្តីថ្លែងហេតុ បង្ហាញអំពីមូលដ្ឋានគតិយុត្ត ដែលតម្រូវឱ្យមានសម្រាប់ ការកសាងកម្មវិធីវិនិយោគ ទម្រង់កម្មវិធីវិនិយោគ ដំណើរការរៀបចំកម្មវិធីវិនិយោគ ចំនួនគម្រោង និងថវិកានៃកម្មវិធីវិនិយោគតាមវិស័យ នីមួយ១ | ១២-១៦/វិច្ឆិកា/២០១២ | សាលាខេត្ត | គណៈអភិបាល/ក្រុមការងារ |
| ៣.២ | **ការងារក្នុងពេលប្រជុំអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត:** -ប្រជុំពិនិត្យពិភាក្សា និងអនុម័តលើសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត | ២១/វិច្ឆិកា/២០១២ | សាលាខេត្ត | ក្រុមប្រឹក្សាខេត្ត |
| ៣.៣ | **ការងារក្រោយពេលប្រជុំអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត:** -ធ្វើការកែសម្រួល និងដាក់កម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្ត ជូនប្រធានក្រុមប្រឹក្សា ចុះហត្ថលេខានិងរៀបចំសេចក្តីសម្រេច ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីវិនិយោគ | ២២-២៣/វិច្ឆិកា/២០១២ | សាលាខេត្ត | គណៈអភិបាល |
| | បោះពុម្ព និង ផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគ | ៣០/វិច្ឆិកា/២០១២ | សាលាខេត្ត | ក្រុមការងារ (ក្រុមតូច) |

ប្រតិទិនការងារកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលខេត្តខាងលើត្រូវបានក្រុមប្រឹក្សាខេត្តព្រះវិហារ អាណត្តិទី ១ អនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី ៤០ នាថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០១២។

ព្រះវិហារថ្ងៃទី31 ខែសីហា ឆ្នាំ២០១២

**ជ.ក្រុមប្រឹក្សាខេត្ត**

**ប្រធាន**

**ឡុង សុវណ្ណ**